ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារណែនាំ

# ក្រុមសាលាមធ្យមសិក្សា

# Secondary School Cluster Guidelines

រៀបរៀងដោយ

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ឧបត្ថម្ភដោយគម្រោង ESDP III

ឆ្នាំ ២០១៧

## ១-គោលបំណង

ការអភិវឌ្ឍកម្រងសាលារៀន ជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់វិស័យអប់រំ ពិសេសនៅកម្រិតអប់រំមូលដ្ឋាន ដោយមានគោលបំណងជាសារវន្តដូចតទៅ៖

-បម្រើគោលដៅអប់រំសម្រាប់ទាំងអស់គ្នា

-លើកកម្ពស់គុណភាពនៅកម្រិតអប់រំមូលដ្ឋាន

-លើកកម្ពស់គុណភាពបង្រៀន និងរៀន ឱ្យមានភាពប្រហាក់ប្រហែលគ្នារវាងសាលារៀន នៅទីប្រជុំជន ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក

-ប្រមូលកុមារដល់វ័យសិក្សាឱ្យចូលរៀនជាអតិបរិមា ប្រកបដោយសមធម៌ និងបង្កលក្ខណៈសម្បត្តិឱ្យពួកគេអាចបន្តការសិក្សារបស់ខ្លួនរហូតចប់មធ្យមសិក្សាបឋមភូមិ ប្រកបដោយគុណភាព

-ចែករំលែកធនធានមនុស្ស សម្ភារៈ និងថវិកា ដើម្បីឱ្យមានការអភិវឌ្ឍព្រមៗគ្នាដោយស្មើភាព

-ចលនាសហគមន៍ ឱ្យចូលរួមក្នុងវិស័យអប់រំបានព្រមគ្នា ប្រកបដោយការទទួលខុសត្រូវ និងក្នុងភាពជាម្ចាស់

-ប្រើប្រាស់ធនធានមនុស្ស សម្ភារៈ និងថវិកា ឱ្យអស់លទ្ធភាពក្នុងទិសដៅប្រែក្លាយកម្រងសាលារៀនជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ តាមរយៈការប្រើប្រាស់ធនធានរបស់សហគមន៍ ដើម្បីអភិវឌ្ឍកម្រងសាលារៀន។

## ២.បញ្ញត្តិកម្រងសាលារៀន

### ២.១.កម្រងសាលារៀន

កម្រងសាលារៀន ជាក្រុមសាលារៀនក្នុងក្រុង ស្រុក ខណ្ឌ មួយដែលបានចងក្រងឡើងក្នុងចំណោមសាលារៀនដែលស្ថិតនៅជិតៗគ្នា និងអាចទាក់ទងគ្នាទៅវិញទៅមកបានងាយស្រួល។ ដូចនេះកម្រងសាលារៀនគឺជាការប្រមូលផ្តុំគ្រប់ធនធាន មាននាយក នាយិកា គ្រូបង្រៀន សហគមន៍ សម្ភារបរិក្ខារ ថវិកា ដើម្បីជួយគ្នាទៅវិញទៅមក ធ្វើឱ្យសម្រេចការពង្រីកបរិមាណ និងពង្រឹងគុណភាពលើគ្រប់សមាសភាគ នៃកម្មវិធីសាលាកុមារមេត្រី និងគ្រប់ផែនការនៃការអបរំ។

កម្រងសាលាមធ្យមសិក្សាមានសាលាបង្គោលមួយ និងសាលាសម្ព័ន្ធមួយចំនួនតាមស្ថានភាពជាក់ស្តែង។ ចំពោះកម្រងសាលារៀននៅទីប្រជុំជន ដែលសាលាបង្គោលមានចំនួនថ្នាក់លើសពី ២០ ចាំបាច់ត្រូវមានសាលាសម្ព័ន្ធយ៉ាងហោចណាស់ក៏មួយដែរ។ ដោយឡែកនៅតំបន់ផ្សេងទៀតកម្រងសាលារៀនអាចរៀបចំតាមភាពទន់ភ្លន់របស់មូលដ្ឋាន។

កម្រងសាលារៀន ត្រូវបានដឹកនាំដោយគណៈកម្មការកម្រងមូលដ្ឋានមួយ ដែលហៅថា គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន។

#### ក.សាលាបង្គោល

សាលាបង្គោល ជាទូទៅជាសាលារៀនដែលមានទីតាំងសមរម្យ និងមានបន្ទប់សម្រាប់រៀបចំទីចាត់ការកម្រងសាលា មានមណ្ឌលធនធាន រោងជាង បណ្ណាល័យ និងសម្បូរធនធានមនុស្ស ដែលមានលក្ខណៈងាយស្រួលក្នុងការទាក់ទងគ្រប់យ៉ាងជាមួយសាលាសម្ព័ន្ធ។

ជាទូទៅសាលាបង្គោល ជាកន្លែងសម្រាប់ប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មការ និងអនុគណៈកម្មការ អភិវឌ្ឍន៍កម្រងសាលារៀនមធ្យមសិក្សា។

ប្រសិនបើកម្រងពុំទាន់មានទីចាត់ការទេ ប្រធានកម្រងអាចប្រើប្រាស់ទីចាត់ការសាលាបង្គោលជាបណ្ដោះអាសន្នបាន ដោយខិតខំយ៉ាងណាធ្វើឱ្យមានស្វ័យភាពដោយខ្លួនឯង។

សាលាបង្គោលក៏ដូចជាសាលាសម្ព័ន្ធដែរ មាននាយក នាយិការបស់ខ្លួន ទីចាត់ការ និងរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងសាលាផ្ទាល់។ សាលាអនុវត្តជាសាលាសម្ព័ន្ធ នៃកម្រងសាលាណាមួយ តែមិនអាចជាសាលាបង្គោលទេ។ សាលាបង្គោលអាចជាវិទ្យាល័យ ឬអនុវិទ្យាល័យដែលមានលក្ខណៈសម្បត្តិសមស្របជាងគេ។

**ខ- សាលាសម្ព័ន្ធ**

សាលាសម្ព័ន្ធ ជាសាលារៀនសមាជិកនៃកម្រងសាលារៀន។ សាលាសម្ព័ន្ធមួយចំនួនរួមគ្នាបង្កើតបានជាកម្រងសាលារៀនមួយ។

**កម្រងសាលាមធ្យមសិក្សា**




## ២.២.ប្រភេទកម្រងសាលាមធ្យមសិក្សា

**ក.កម្រងសាលាទីប្រជុំជន**

ជាកម្រងនៅក្នុងតំបន់ដែលមានប្រជាជនច្រើន (ក្នុងទីក្រុង <u>ទីរួមខេត្ត</u> និងទីប្រជុំជនស្រុកធំៗ) និងមានសាលារៀនធំៗ (មានន័យថា មានសាលាសម្ព័ន្ធ ២ ឬ ៣ ក្នុងកម្រងនីមួយៗ) ។ កម្រងទីប្រជុំជនភាគច្រើនសាលាសម្ព័ន្ធជាសាលារៀនធំដែលមានថ្នាក់ច្រើនជាង ២០ ថ្នាក់ឡើងទៅ ។

**កម្រងទីប្រជុំជន**



**កំណត់សម្គាល់៖**

ការប្រជុំផ្សេងៗ ដែលទាក់ទងទៅនឹងការបង្កើនគុណភាពនៃការគ្រប់គ្រងសាលារៀន និងបំប៉នគ្រូបង្រៀនជាដើម ត្រូវធ្វើឡើងនៅសាលាបង្គោល ឬសាលាសម្ព័ន្ធណាមួយ។ សាលារៀនធំអាចធ្វើការប្រជុំនៅតាមសាលារៀងៗខ្លួន បើមានបញ្ហាសំខាន់ណាមួយលំបាកដោះស្រាយគប្បីអញ្ជើញក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT បើមាន) មកជួយ ។ ចំពោះសាលារៀនតូច គប្បីធ្វើការប្រជុំនៅតាមសាលាបង្គោល។

**ខ- កម្រងធម្មតា ឬកម្រងទូទៅ**

ជាកម្រងសាលារៀនមួយជាទូទៅមានពី ៣-៦ សាលារៀន និងមានទីតាំងជិតៗគ្នា ហើយធម្មតាមានភាពងាយស្រួលកោះប្រជុំបុគ្គលិក និងប្រើប្រាស់ជារួមនូវធនធាន ជំនាញ និងបទពិសោធ។ ចំពោះសាលាសម្ព័ន្ធក្នុងកម្រង ត្រូវមានចម្ងាយយ៉ាងឆ្ងាយប្រហែល ១០ គីឡូម៉ែត្រ ពីទីតាំងសាលាបង្គោល ឬអាចធ្វើដំណើរកន្លះម៉ោងដោយម៉ូតូពីសាលាសម្ព័ន្ធទៅសាលាបង្គោល។

**កម្រងធម្មតា**




**កំណត់សម្គាល់៖**

ការរៀបចំកម្រងធម្មតា (កម្រងទូទៅ) ដើម្បីឱ្យនាយកសាលារៀន-គ្រូបង្រៀន និងតំណាងសហគមន៍មកពីគ្រប់សាលារៀនក្នុងកម្រងអាចជួបប្រជុំគ្នាបានងាយស្រួល និងទៀងទាត់ ។

**គ- កម្រងជនបទ**

មានលក្ខណៈប្រហាក់ប្រហែលនឹងកម្រងធម្មតា ប៉ុន្តែខុសគ្នាត្រង់មានសាលារៀន ១ ឬ ២ ក្នុងកម្រងនោះមានចម្ងាយលើសពី ១០ គីឡូម៉ែត្រពីសាលាបង្គោល និងរួមបញ្ចូលទាំងសាលាសម្ព័ន្ធខ្លះ ដែលជាសាលាដាច់ស្រយាល ឬសាលាស្ថិតក្នុងតំបន់ជួបការលំបាកផង ។ កម្រងប្រភេទនេះមានការលំបាកក្នុងការគ្រប់គ្រង

ការផ្លាស់ប្តូរបទពិសោធ ការប្រជុំផ្សេងៗ រួមទាំងការបំប៉នគ្រូបង្រៀន ពិសេសសម្រាប់សាលារៀនដែលនៅឆ្ងាយៗ ។ ក្នុងករណីនេះ ប្រធានកម្រងគប្បីប្រមូលផ្តុំសាលារៀនឆ្ងាយៗ (ចំនួន ២ ឬ ៣ ក្នុងកម្រង) ដើម្បីធ្វើសកម្មភាពជាមួយគ្នាដូចជាការប្រជុំ ឬការបំប៉នផ្សេងៗ។ តែប្រសិនបើមានសាលារៀនមួយចំនួននៅឆ្ងាយដាច់ស្រយាលពេកនោះ ត្រូវចាត់តាំងនាយកសាលា ឬគ្រូដែលមានបទពិសោធខ្ពស់ជាងគេនៃសាលារៀននោះឱ្យមកចូលរួមប្រជុំ បំប៉ន ឬសិក្ខាសាលានៅឯសាលាបង្គោលក្នុងកម្រង រួចយកទៅបំប៉នបន្តដល់បុគ្គលិកតាមសាលារៀនរបស់ខ្លួនវិញ។

**កម្រងជនបទ**




**កំណត់សម្គាល់៖**

ប្រធានកម្រងជនបទ ត្រូវស្វែងយល់ឱ្យបានច្បាស់លាស់អំពីស្ថានភាព និងតម្រូវការនៃសាលាសម្ព័ន្ធនីមួយៗ ពិសេសចំពោះសាលារៀនដែលនៅឆ្ងាយៗ ឬក្នុងតំបន់ដាច់ស្រយាល ដើម្បីកំណត់ផែនការ និងយុទ្ធសាស្ត្រអនុវត្តន៍ឱ្យបានសមស្របតាមករណីដូចបានលើកឡើងខាងលើ។

## ៣.អត្ថប្រយោជន៍កម្រងសាលារៀន

ក្រៅពីគោលបំណងខាងលើ ការបង្កើតកម្រងសាលារៀនបានបម្រើអត្ថប្រយោជន៍ពិសេសៗ ៤ យ៉ាងគឺ៖

### ៣.១.ផ្នែករដ្ឋបាល

កម្រងសាលារៀន បង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងរបស់សាលាសម្ព័ន្ធឱ្យមានដំណើរការល្អប្រសើរ។

**ឧទាហរណ៍**

- អាចចងក្រងឯកសារ និងគ្រប់គ្រងស្ថិតិ ទិន្នន័យ/ព័ត៌មានកុមារ ប្រជាពលរដ្ឋ អក្ខរជន អនក្ខរជន សាលារៀន ថ្នាក់រៀន គ្រូ សិស្ស បានច្បាស់លាស់ ដើម្បីយកទៅកសាងផែនការអភិវឌ្ឍន៍សាលារៀនតាមឆ្នាំសិក្សា
- អាចដោះស្រាយបញ្ហាកង្វះគ្រូ តាមរយៈចលនាគ្រូបង្រៀនពីសាលារៀនដែលសល់គ្រូឱ្យទៅជួយបង្រៀនសាលារៀនដែលខ្វះគ្រូ តាមបែបទន់ភ្លន់ ដូចជាការបង្រៀននៅសាលាផ្សេងទៀតដោយគិតជារបបម៉ោងបន្ថែម
- អាចរៀបចំការប្រជុំបូកសរុប កែលម្អ និងវាយតម្លៃផែនការអភិវឌ្ឍន៍របស់សាលាសម្ព័ន្ធឱ្យមានដំណើរការប្រែប្រួល និងរីកចម្រើនព្រមគ្នា
- អាចធ្វើការប្រជុំផ្លាស់ប្តូរបទពិសោធលើការងារគ្រប់គ្រង ពីសាលាសម្ព័ន្ធមួយទៅសាលាសម្ព័ន្ធមួយទៀត ដើម្បីយកទៅអនុវត្តនៅតាមមូលដ្ឋានរៀងខ្លួនឱ្យមានប្រសិទ្ធភាព
- អាចធ្វើជាមជ្ឈមណ្ឌលបន្តផ្សព្វផ្សាយ និងពង្រឹងការអនុវត្តសេចក្តីណែនាំនានា របស់ក្រសួង អប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធនានា
- ជាកន្លែងសម្របសម្រួលការងារ និងផ្សារភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ឱ្យកាន់តែជិតគ្នាដូចជាការសម្របសម្រួលថវិកា និងការបញ្ជូនរបាយការណ៍នានាបានត្រឹមត្រូវ និងមានប្រសិទ្ធភាព
- បង្កើនចរន្តបញ្ជូនរបាយការណ៍ និងវាយតម្លៃលទ្ធផលសិក្សាតាមឆមាស ឬឆ្នាំ បានកាន់តែមានលក្ខណៈច្បាស់លាស់ និងទាន់ពេលវេលា។

### ៣.២.ផ្នែកគរុកោសល្យ

កម្រងសាលារៀន បង្កលក្ខណៈងាយស្រួលក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។

**ឧទាហរណ៍**

- អាចប្រមូលផ្តុំគ្រូមកបំប៉នសមត្ថភាពបច្ចេកទេសគរុកោសល្យ ឱ្យមានប្រសិទ្ធភាពប្រហាក់ប្រហែលគ្នា ពិសេសជួយគ្នាទៅវិញទៅមក លើវិធីសាស្ត្រនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី ការប្រើប្រាស់កម្មវិធីសៀវភៅសិក្សាគោល និងឯកសារនានា
- ប្រើប្រាស់ទីតាំងសម្រាប់ធ្វើការប្រជុំបច្ចេកទេស ការប្រជុំដកពិសោធ ជួយសិស្សរៀនយឺត ធ្វើថ្នាក់និទស្សន៍ ឬថ្នាក់បង្ហាញនៅតាមសប្តាហ៍ ឬខែ ដោយយកតាមគំរូរបស់សាលារៀនល្អ និងគ្រូបង្រៀនល្អ
- អាចរៀបចំកម្មវិធីសិក្សានៅតាមកម្រិតថ្នាក់ និងមុខវិជ្ជានីមួយៗឱ្យមានការឯកភាពគ្នា និងសមស្របតាមស្ថានភាព និងតម្រូវការរបស់កម្រង

- អាចប្រើប្រាស់ឯកសារ និងវាយតម្លៃលទ្ធផលតេស្តរបស់សិស្សដើម្បីពិនិត្យការរីកចម្រើន និងពង្រឹងគុណភាពសិក្សានៅក្នុងកម្រងឱ្យមានលក្ខណៈប្រហាក់ប្រហែលគ្នា

- អាចរៀបចំកម្មវិធីអប់រំបំណិនជីវិត (វិជ្ជាមេផ្ទះ កីឡា សិល្បៈ កសិកម្ម រោងជាង បណ្ណាល័យ...) ឱ្យស្របទៅនឹងតម្រូវការរបស់មូលដ្ឋាន

- អាចប្រើប្រាស់ទីតាំងធ្វើជាកន្លែងប្រមូលផ្តុំ ស្រាវជ្រាវ ផលិត ប្រើប្រាស់សម្ភារឧបទេស និងបង្វិលចែកឱ្យប្រើប្រាស់បានគ្រប់គ្នា ក្នុងករណីដែលសម្ភារៈនោះមានចំនួនមិនគ្រប់គ្រាន់

- អាចជួយនាយកសាលារៀន និងគ្រូបង្រៀនលើការងារគ្រប់គ្រង និងបច្ចេកទេសទាន់ពេលវេលាតាមរយៈក្រុមអធិការកិច្ចរបស់កម្រង និងរបស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ DTMT3 ។

## ៣.៣.ផ្នែកសេដ្ឋកិច្ច

កម្រងសាលារៀនបង្កលក្ខណៈងាយស្រួលក្នុងការសន្សំសំចៃថវិកា ការចែករំលែក និងប្រើប្រាស់ធនធានសម្ភារៈរួមគ្នានៅក្នុងកម្រង តាមរយៈការបង្កើតកញ្ចប់ថវិកាកម្រងមធ្យមសិក្សា។

**ឧទាហរណ៍**

- អាចសហការ និងប្រមូលថវិកាទិញឧបករណ៍ដែលមានតម្លៃខ្ពស់ដូចជាកុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថតចម្លង . . . យកមកចែករំលែកគ្នាប្រើប្រាស់ទៅតាមលទ្ធភាព

- អាចផ្លាស់ប្តូរវេនគ្នាប្រើប្រាស់សម្ភារៈ ឬឧបករណ៍ដែលមានចំនួនតិច ដូចជាសៀវភៅសិក្សាវចនានុក្រម សម្ភារៈកីឡា សម្ភារឧបទេស សម្ភារៈកសិកម្ម។ល។ ទៅតាមតម្រូវការ។ ការធ្វើរបៀបនេះអាចសន្សំសំចៃថវិកា សម្រាប់យកទៅប្រើការលើផ្នែក ឬសំណូមពរផ្សេងៗទៀត ដែលបម្រើឱ្យការបង្រៀន និងរៀន។

## ៣.៤.ផ្នែកសហគមន៍

ដំណើរការអភិវឌ្ឍន៍កម្រងសាលារៀន អាចទទួលបានជោគជ័យ អាស្រ័យដោយមានការចូលរួម និងមានជំនឿពីសហគមន៍ ។ តាមរយៈនេះ សហគមន៍អាចប្រើប្រាស់កម្រងសាលារៀនដើម្បីអភិវឌ្ឍសហគមន៍របស់ខ្លួនក៏ដូចជាសាលារៀនរបស់ខ្លួនដែរ។

**ឧទាហរណ៍**

-សហគមន៍អាចរៀបចំការប្រជុំផ្លាស់ប្តូរបទពិសោធ និងរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងការចូលរួមអភិវឌ្ឍវិស័យអប់រំ

-អាចចូលរួមប្រកួតប្រជែងចលនាសហគមន៍ល្អ ក្នុងការអភិវឌ្ឍសាលារៀន លើគ្រប់សកម្មភាពអប់រំដូចជាការប្រមូលកុមារចូលរៀន ការការពារ និងកសាងសាលារៀន ការកសាងផែនការ និងអភិវឌ្ឍសាលារៀន ការជួយកុមារក្រីក្រជួបការលំបាក ការជួយគ្រូបង្រៀន ការអប់រំកូនចៅ ការរកដំណោះស្រាយលើការលំបាកផ្សេងៗ

-អាចប្រើប្រាស់កម្រងសាលារៀន ធ្វើយុទ្ធនាការផ្សព្វផ្សាយគ្រប់សកម្មភាព ដើម្បីអប់រំដល់សមាជិកសហគមន៍អំពីតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការជួយដល់សាលារៀន ដូចជាការថែទាំ ការពារ ការជួសជុលតាមរយៈកម្លាំងស្មារតី សម្ភារៈ និងថវិកា

-អាចចូលរួមធ្វើអន្តរាគមន៍ និងផ្តល់ការអប់រំដល់កូនចៅ និងគ្រួសារសិស្ស អំពីសារៈប្រយោជន៍នៃការអប់រំ និងការផ្តល់ការអប់រំបំណិនជីវិតដល់ពួកគេទាំងនោះ

-អាចស្វែងយល់អំពីលទ្ធផលនៃការសិក្សារបស់សិស្សក្នុងកម្រង និងបញ្ហាប្រឈមដែលពាក់ព័ន្ធនានា ដើម្បីជំរុញមាតាបិតាឱ្យចូលរួមអប់រំកូនចៅ និងផ្តល់លទ្ធភាពឱ្យពួកគេបានចូលរៀន និងខិតខំរៀនសូត្រគ្រប់គ្នា

-អាចប្រើប្រាស់កម្រងសាលារៀន ដើម្បីផ្សព្វផ្សាយផលិតផលនានា ក្នុងសហគមន៍ដោយរៀបចំពិព័រណ៍ប្រចាំឆ្នាំ ដែលរៀបចំឡើងដោយគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន

-អាចជួយសាលារៀនក្នុងការសម្របសម្រួលកម្មវិធីសិក្សា និងបំណិនជីវិតឱ្យស្របតាមសំណូមពររបស់សហគមន៍ និងមូលដ្ឋាន

-អាចប្រើប្រាស់វេទិកាសាលារៀន ដើម្បីផ្សព្វផ្សាយ និងបំផុសសហគមន៍ឱ្យយល់ពីគោលការណ៍នានា ដែលសហគមន៍ត្រូវបំពេញដើម្បីអភិវឌ្ឍសាលារៀនតាមទិសស្លោក "សាលារៀនដើម្បីសហគមន៍ សហគមន៍ដើម្បីសាលារៀន" សំដៅប្រែក្លាយពាក្យស្លោកទាំងនេះឱ្យទៅជាការអនុវត្ត និងបង្កើតសមិទ្ធផលជាក់ស្តែងសម្រាប់សង្គមជាតិ ។

## ៤.យុទ្ធសាស្ត្រអភិវឌ្ឍកម្រងសាលារៀនតាមកម្មវិធីសាលាកុមារមេត្រី

កម្រងសាលារៀន គឺជាយន្តការមួយដែលជួយសម្របសម្រួលការងាររវាងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន ដើម្បីឱ្យដំណើរការអភិវឌ្ឍន៍របស់សាលារៀនប្រព្រឹត្តិទៅប្រកបដោយជោគជ័យ។ កម្រងសាលារៀនមួយ មានដំណើរការបានអាស្រ័យដោយកត្តា ជាច្រើនដូចជាធនធានផ្ទាល់ ការទទួលខុសត្រូវចំពោះភារកិច្ចប្រកបដោយគណនេយ្យភាព និងតម្លាភាព ដើម្បីទទួលបានទំនុកចិត្តពីសាលារៀន និងសហគមន៍។ គោលការណ៍យុទ្ធសាស្ត្រដែលត្រូវអនុវត្តចាំបាច់នោះ គឺត្រូវធានាធ្វើឱ្យសម្រេចនូវសមាសភាគទាំង ៦ នៃកម្មវិធីសាលាកុមារមេត្រីគឺៈ

### ៤.១.កុមារទាំងអស់ត្រូវបានចូលរៀន

-រៀបចំផែនការអភិវឌ្ឍន៍កម្រងសាលារៀនដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងកម្រង

-រៀបចំយុទ្ធនាការផ្សព្វផ្សាយគ្រប់រូបភាព (ប័ណ្ណព័ត៌មាន កាសែត វិទ្យុ ទូរទស្សន៍...) ដើម្បីប្រមូលកុមារនៅតាមមូលដ្ឋានមកចុះឈ្មោះចូលរៀន

-រៀបចំផែនទីសិក្សានៅតាមសាលាដោយសហការជាមួយអ្នកពាក់ព័ន្ធដែលនៅតាមភូមិចំណុះ

-កំណត់អត្តសញ្ញាណ និងផ្តល់លទ្ធភាពដល់កុមារដែលមានតម្រូវការពិសេសបានចូលរៀន។

### ៤.២.ការសិក្សាប្រកបដោយប្រសិទ្ធភាព

-រៀបចំបំប៉ននាយក និងបុគ្គលិករបស់សាលារៀនលើការងារបច្ចេកទេសតាមផែនការកំណត់

-រៀបចំប្រជុំទៀងទាត់ជាមួយនាយកសាលាក្នុងកម្រងដើម្បីផ្លាស់ប្តូរបទពិសោធ ពិភាក្សារកដំណោះស្រាយបញ្ហាប្រឈមនានាដែលកំពុងកើតមាន

-ពង្រឹងការអនុវត្តប្រតិទិន និងម៉ោងសិក្សាតាមរយៈការពិនិត្យតាមដាន និងកែលម្អជាប្រចាំ

-ជំរុញការប្រជុំបច្ចេកទេស ឱ្យបានទៀងទាត់ដោយកំណត់ច្បាស់លាស់នូវប្រធានបទ របៀបវារៈប្រជុំ និងសកម្មភាពការងារដែលត្រូវអនុវត្តក្នុងសប្តាហ៍ និងខែនីមួយៗ

-ជំរុញសកម្មភាពបង្រៀន និងរៀន តាមគោលវិធីសិស្សមជ្ឈមណ្ឌលដោយរៀបចំឱ្យមានការងារក្រុម ការងារដៃគូ ការងារបុគ្គលនៅរាល់ម៉ោងសិក្សាទាំងក្នុង និងក្រៅថ្នាក់រៀន

-ជំរុញការស្រាវជ្រាវរបស់កុមារ និងការប្រមូលព័ត៌មាន ពីគ្រប់មជ្ឈដ្ឋាន សហគមន៍ ស្ថាប័នរដ្ឋ ឯកជន រមណីយដ្ឋាននានា ដើម្បីបំពេញបន្ថែមលើសមត្ថភាពមូលដ្ឋានរបស់សិស្ស

-ជំរុញសកម្មភាពបណ្ណាល័យ ឱ្យមានដំណើរការល្អសម្រាប់ការអាន ការគូរ ឬការផលិត

-បង្កឱកាសឱ្យគ្រូបង្រៀនបានរៀនសូត្របទពិសោធពីគ្នា និងជួយគ្នាទៅវិញទៅមក

-លើកកម្ពស់តួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀន ដើម្បីឱ្យពួកគេមានឱកាសកសាងស្នាដៃក្នុងការងារល្អ

-ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននៅតាមសាលារៀន ដើម្បីក្លាយជាគំរូសម្រាប់កុមារជំនាន់ក្រោយ

-លើកទឹកចិត្តគ្រូឱ្យមានការស្រាវជ្រាវ និងរៀនសូត្របន្ថែមក្រៅម៉ោងសិក្សា

-សម្របសម្រួលកម្មវិធីសិក្សា និងអប់រំបំណិនជីវិតជាមួយសហគមន៍ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន និងសហគមន៍

-ពង្រឹងការរៀបចំ និងប្រើប្រាស់កិច្ចតែងការ និងសម្ភារឧបទេសគ្រប់សកម្មភាពបង្រៀន និងរៀន

-ជំរុញការអនុវត្តគោលការណ៍វាយតម្លៃលទ្ធផលសិក្សារបស់សិស្សឱ្យបានត្រឹមត្រូវ ដែលអាចធានាបាននូវគុណភាព និងយុត្តិធម៌

-រៀបចំឱ្យមានទស្សនកិច្ចសិក្សាដកស្រង់បទពិសោធរវាងសាលាសម្ព័ន្ធ និងសាលាសម្ព័ន្ធ ឬកម្រង និងកម្រង

-រៀបចំធ្វើថ្នាក់បង្ហាញ និងថ្នាក់និទស្សន៍ជូនគ្រូបង្រៀនឱ្យបានទៀងទាត់

-ជំរុញការជួយសិស្សរៀនយឺតឱ្យបានជាប្រចាំទាំងក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សាដើម្បីធានាការកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា

-ជំរុញសកម្មភាព និងដំណើរការរោងជាង ដើម្បីផ្តល់លទ្ធភាពដល់សិស្សចូលរួមក្នុងការផលិតសម្ភារឧបទេសសម្រាប់យកមកប្រើប្រាស់ក្នុងសកម្មភាពបង្រៀន និងរៀន

-ជំរុញសកម្មភាពអប់រំបំណិនជីវិត ឱ្យបានគ្រប់សាលារៀន និងថ្នាក់រៀន។

## ៤.៣.សុខភាព សុវត្ថិភាព និងការការពារកុមារ

-ធានាផ្តល់ និងបង្កើនទម្លាប់ប្រើប្រាស់ទឹកស្អាត បង្គន់អនាម័យដល់កុមារា កុមារី កុមារពិការ

-ទម្លាប់អនុវត្តអនាម័យ ៣ប្រការ ផឹកស្អាត ហូបស្អាត និងរស់នៅស្អាតឱ្យបានជាប្រចាំដោយរៀបចំឱ្យមានធុងចម្រោះទឹក ធុងសំរាម និងធ្វើការបោសសម្អាតសាលារៀន ថ្នាក់រៀនរាល់ថ្ងៃសិក្សា

-លុបបំបាត់រាល់ការរើសអើង (វណ្ណៈ ជំនឿ ជាតិសាសន៍ ជីវភាព...) នៅក្នុងសាលារៀន

-លុបបំបាត់អំពើហិង្សា (ផ្លូវចិត្ត ផ្លូវកាយ) នៅក្នុងសាលារៀន

-រៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តឱ្យបានល្អចៀសវាងគ្រោះថ្នាក់ចំពោះសិស្ស

-អប់រំអំពីគ្រោះថ្នាក់ សុវត្ថិភាពចរាចរ និងការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ។

## ៤.៤.ការឆ្លើយតបទៅនឹងយេនឌ័រ

-រៀបចំក្រុមពិគ្រោះយោបល់/អ្នកផ្តល់ប្រឹក្សានៅតាមសាលារៀន ដើម្បីជួយគាំទ្រកុមារីលើផ្នែកសុខភាព

-រៀបចំគោលការណ៍ និងកម្មវិធីជួយគាំទ្រកុមារីដើម្បីអាចបន្តនិងបញ្ចប់ការសិក្សាដល់កម្រិតអប់រំមូលដ្ឋាន

-រៀបចំឱ្យមានសមភាពរវាងកុមារា និងកុមារី រវាងបុគ្គលិកស្រី និងប្រុស ក្នុងការទទួលខុសត្រូវគ្រប់ផ្នែកការងារនៅតាមសាលារៀន។

## ៤.៥.ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍

-ជំរុញ និងផ្តល់ឱកាសឱ្យសហគមន៍ មាតាបិតាសិស្សចូលរួមក្នុងការកសាង តាមដាន និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន

-ផ្សព្វផ្សាយ និងចលនាសហគមន៍ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់ជំនួយ សប្បុរសជនឱ្យយល់ដឹងពីកម្មវិធីសាលាកុមារមេត្រី និងសេចក្តីណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា

-ផ្តល់ឱកាសឱ្យសហគមន៍ អ្នកមានបទពិសោធចូលរួមផ្សព្វផ្សាយ និងអប់រំសិស្សពាក់ពន្ធ័នឹងវប្បធម៌ អរិយធម៌ សង្គមកិច្ច និងកម្មវិធីអប់រំបំណិនជីវិតនៅតាមសាលារៀន

-សហការជាមួយអាជ្ញាធរដែនដី និងសហគមន៍ទប់ស្កាត់រាល់បាតុភាពមិនប្រក្រតីនៅតាមសាលារៀន

-ចលនាសហគមន៍ អាជ្ញាធរ សប្បុរសជន និងអ្នកផ្តល់ជំនួយពីខាងក្រៅឱ្យជួយអភិវឌ្ឍសាលារៀន និងមានស្មារតីទទួលខុសត្រូវក្នុងភាពជាម្ចាស់

-ជំរុញក្រុមប្រឹក្សាកុមារ ឱ្យចូលរួមគ្រប់សកម្មភាពរបស់សាលារៀន និងសកម្មភាពសង្គម

-ផ្តល់ឱកាសឱ្យសហគមន៍ប្រើប្រាស់សាលារៀនធ្វើជាវេទិកា និងយុទ្ធនាការនានាសម្រាប់គាំទ្រការងារអប់រំនៅក្នុងមូលដ្ឋាន

-ជំរុញ និងលើកទឹកចិត្តឱ្យមានវេទិកា ឬសមាជដើម្បីឱ្យសិស្សានុសិស្សមានឱកាសផ្តល់មតិយោបល់ចូលរួមអភិវឌ្ឍសាលារៀនស្របតាមតម្រូវការរបស់ពួកគេ

-ជំរុញការអនុវត្តចលនាបីល្អរបស់កុមារ "កូនល្អ សិស្សល្អ និងមិត្តល្អ" ឱ្យបានសកម្មផុសផុល។

## ៤.៦.ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ

-ពង្រឹងការអនុវត្តគោលនយោបាយ និងសេចក្តីណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានប្រសិទ្ធភាព

-ពង្រឹងការអនុវត្តកម្មវិធីសិក្សា កម្មវិធីអប់រំបំណិនជីវិតឱ្យបានសមស្រប និងឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន

-ពង្រឹងការអនុវត្តប្រតិទិន និងម៉ោងសិក្សាឱ្យបានម៉ត់ចត់ ដើម្បីធានាលទ្ធផលសិក្សាប្រកបដោយគុណភាពនៅគ្រប់សាលារៀន និងឆ្នាំសិក្សានីមួយៗ

-ជំរុញការអនុវត្តវិធីសាស្រ្ត និងគោលវិធីសិស្សមជ្ឈមណ្ឌល នៅក្នុងសកម្មភាពបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់

-ពង្រឹងការអនុវត្តប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈឱ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់

-ជួយសម្របសម្រួលការគ្រប់គ្រងប្រើប្រាស់ថវិកាតាមកម្មវិធី និងថវិកាគម្រោងនានារបស់កម្រងសាលារៀនប្រកបដោយតម្លាភាព។

## ៥.គោលការណ៍រៀបចំ និងគ្រប់គ្រងកម្រងសាលារៀន

### ៥.១.ការរៀបចំកម្រងសាលារៀន

ការរៀបចំកម្រងសាលារៀនគប្បីអនុវត្តតាមយុទ្ធវិធីដូចខាងក្រោម៖

-ចងក្រងជាដំបូងកម្រងនៅតាមទីប្រជុំជន និងកម្រងធម្មតា ឬកម្រងទូទៅ ចំពោះសាលារៀនទាំងឡាយដែលមានលក្ខណៈងាយស្រួលក្នុងការប្រមូលផ្តុំ និងអាចទាក់ទងគ្នាទៅវិញទៅមកបានឆាប់រហ័ស

-ចាប់ផ្តើមដំណើរការអនុវត្តកម្រងសាលារៀនដោយខ្លួនឯង ដោយពុំរង់ចាំជំនួយទ្រទ្រង់ពីខាងក្រៅ

-រៀបចំចាត់ចែងឱ្យមានថវិកាសម្រាប់ដំណើរការកម្រងជាបណ្តើរៗ និងប្រើប្រាស់ទៅតាមអាទិភាពនៃសកម្មភាព

-គប្បីប្រគល់ភារកិច្ចទៅឱ្យកម្រង ដែលនៅជិតជាអ្នកទទួលខុសត្រូវជួយដល់សាលារៀនណាដែលនៅដាច់ឆ្ងាយពីគេ ហើយមិនទាន់បានបញ្ចូលក្នុងកម្រងណាមួយនៅឡើយ

-សហការជាមួយដៃគូអភិវឌ្ឍន៍ (អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល) ដែលកំពុងជួយទ្រទ្រង់កម្រងសាលាណាមួយឱ្យជួយពង្រីកការទ្រទ្រង់ទៅកម្រងសាលាផ្សេងទៀតដែលនៅក្បែរគ្នា

-ចលនា និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានដែលបានមកពីប្រភពផ្សេងៗ ដើម្បីអនុវត្តកម្មវិធីនានារបស់កម្រងសាលារៀន ប្រកបដោយគុណភាព តម្លាភាព និងនិរន្តរភាព

-អំពាវនាវដល់ដៃគូអភិវឌ្ឍន៍ (អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល) ឱ្យជួយគាំទ្រគ្រប់មធ្យោបាយ និងលទ្ធភាពដើម្បីធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍របស់កម្រងសាលារៀន។

### ៥.២.ជំហាន នៃការរៀបចំកម្រងសាលារៀន

កម្រងសាលារៀនទាមទារឱ្យមានការទទួលខុសត្រូវជាប្រព័ន្ធពីថ្នាក់ក្រសួង មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ រហូតដល់មូលដ្ឋាន។ ជាគោលការណ៍ចាំបាច់ត្រូវបង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ជាមុនដើម្បីដឹកនាំរៀបចំកម្រងសាលារៀនមូលដ្ឋាន។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវបង្កើត និងអភិវឌ្ឍកម្រងសាលារៀននៅក្នុងតំបន់គ្រប់គ្រងរបស់ខ្លួនដោយមានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ ត្រូវផ្តល់ការបំប៉នចាំបាច់ និងតាមដានវាយតម្លៃសកម្មភាពការងារអភិវឌ្ឍន៍កម្រងសាលារៀនទូទាំងប្រទេស។ ការបង្កើតកម្រងសាលារៀន ត្រូវអនុវត្តតាមជំហាន និងសកម្មភាពដូចតទៅ៖

-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនទីសិក្សាគ្រប់សាលា មធ្យមសិក្សាប្រមូល និងវិភាគទិន្នន័យសាលារៀន កំណត់ទីតាំងកណ្តាលរបស់កម្រងនីមួយៗ ដែលជាទូទៅមានភាពងាយស្រួលជាងគេ និងមានធនធានមនុស្សសមស្របធ្វើជាសាលាបង្គោល

-ផ្អែកលើផែនទីសិក្សា ទិន្នន័យព័ត៌មានរបស់សាលារៀន ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ក្រុមសាលាមធ្យមសិក្សានៅតាមកម្រងនីមួយៗ រួចអញ្ជើញនាយកសាលាមធ្យមសិក្សា និងតំណាងគណៈកម្មការទ្រទ្រង់សាលាគ្រប់សាលា ក្នុងកម្រងមកចូលរួមរៀនសូត្រឱ្យយល់ពីប្រព័ន្ធ និងតួនាទីរបស់កម្រងសាលារៀន។ បញ្ជីក្រុមសាលារៀនតាមកម្រងគប្បីផ្សព្វផ្សាយឱ្យបានមុនពេលបើកសិក្ខាសាលាដើម្បីងាយស្រួលក្នុងការចាត់ចែងការងារផ្សេងៗ

-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ អញ្ជើញនាយកសាលាមធ្យមសិក្សាទាំងអស់មកប្រជុំពិភាក្សាកែសម្រួលការរៀបចំក្រុមសាលារៀនសម្រេចចុងក្រោយ ប្រសិនបើមានការប្រែប្រួល

-បញ្ជីរៀបចំក្រុមសាលារៀន ត្រូវឆ្លងយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ ពេលទទួលការឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន

-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចេញលិខិតបង្គាប់ការចាត់តាំងកម្រងសាលាមធ្យមសិក្សាក្នុងខេត្ត រួចចម្លងជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា អង្គការជាតិ និងអន្តរជាតិ ដែលបំពេញភារកិច្ច នៅក្នុងរាជធានី ខេត្ត ជាព័ត៌មាន

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ (ក្រសួងអប់រំ យុវជន និងកីឡា)ត្រូវប្រមូលទិន្នន័យព័ត៌មានពីកម្រងសាលារៀនទាំងអស់ ក្នុងទូទាំងប្រទេស រួចចងក្រង និងផ្ញើជូននាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធជាព័ត៌មាន។

## ៥.៣.លក្ខខណ្ឌសម្រាប់អភិវឌ្ឍកម្រងសាលារៀន

អភិវឌ្ឍកម្រងសាលារៀន គឺអភិវឌ្ឍគ្រប់ការងាររបស់សាលារៀនសំដៅជួយកុមារឱ្យរៀនសូត្របានល្អប្រកបដោយគុណភាពសម្រាប់ធ្វើជាធនធានរបស់សហគមន៍ ដើម្បីអភិវឌ្ឍសហគមន៍ទៅអនាគត។ ការជួយកុមារក្នុងសាលារៀន ត្រូវផ្សារភ្ជាប់ទៅនឹងការងាររបស់គណៈកម្មការនានាក្នុងសាលារៀន នាយកសាលា គ្រូបង្រៀន ឱ្យបំពេញការងារប្រកបដោយប្រសិទ្ធភាពដោយធ្វើឱ្យគ្រប់គ្នាយល់ថា គ្រូបង្រៀនល្អនាំឱ្យសាលារៀនល្អ ហើយសាលារៀនល្អនាំឱ្យកម្រងសាលារៀនល្អ។

លក្ខខណ្ឌសំខាន់ៗសម្រាប់អភិវឌ្ឍន៍កម្រងសាលារៀនមានៈ

### ក.លក្ខខណ្ឌកម្រិតមូលដ្ឋាន

ចំពោះកម្រងបង្កើតថ្មី នៅខ្វះហេដ្ឋារចនាសម្ព័ន្ធច្រើនក៏អាចចាប់ផ្តើមអភិវឌ្ឍបានដែរ ដោយគោរពលក្ខខណ្ឌចម្បងៗៈ

- **រដ្ឋបាល**

-កំណត់ និងជ្រើសរើសសាលាបង្គោល

-បង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលា

-បង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលា

-រៀបចំក្រុមបច្ចេកទេសកម្រងតាមមុខវិជ្ជា

-កសាងផែនការអភិវឌ្ឍន៍ និងផែនការសកម្មភាព។

### ខ.លក្ខខណ្ឌកម្រិតមធ្យម

នៅពេលដំណើរការលក្ខខណ្ឌកម្រងកម្រិតមូលដ្ឋានមានលំនឹងហើយ គ្រប់សាលាសម្ព័ន្ធក្នុងកម្រងត្រូវពង្រីកសកម្មភាព បន្ថែមទៀតតាមលទ្ធភាពជាក់ស្តែង និងពង្រឹងគុណភាពការងារគ្រប់ផ្នែកជាបណ្តើរៗ តាមរយៈស្វ័យវាយតម្លៃ និងស្វ័យកែលម្អដើម្បីធ្វើឱ្យសម្រេចលក្ខខណ្ឌមួយចំនួនទៀតដូចខាងក្រោមៈ

- **រដ្ឋបាល**

-បង្កើត និងដំណើរការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀន

-រៀបចំបង្កើតរចនាសម្ព័ន្ធតាមផ្នែកឱ្យទទួលខុសត្រូវតាមតួនាទី និងភារកិច្ចរបស់អនុគណៈកម្មការនីមួយៗ
-រៀបចំមជ្ឈមណ្ឌលធនធាន ទីចាត់ការកម្រងសាលារៀន និងចាត់តាំងអ្នកទទួលខុសត្រូវច្បាស់លាស់
-រៀបចំបណ្ណាល័យនៅតាមសាលាបង្គោល និងសាលាសម្ព័ន្ធ
-ចាត់តាំងសកម្មភាពរោងជាង និងអ្នកទទួលខុសត្រូវ
-អនុវត្តបែបបទប្រជុំការងារតាមផែនការដោយចាត់តាំងការអនុវត្តការតាមដាន និងវាយតម្លៃច្បាស់លាស់
-កសាងផែនការអភិវឌ្ឍន៍កម្រងសាលារៀន ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធីសាលាកុមារមេត្រីជាបណ្តើរៗ

- **បច្ចេកទេស**

-ពង្រឹងប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាលើការងាររដ្ឋបាល និងបច្ចេកទេស
-ចាត់តាំងគ្រូដែលមានបទពិសោធបង្រៀនល្អ នៅក្នុងកម្រងធ្វើថ្នាក់និទស្សន៍ ឬថ្នាក់បង្ហាញដោយជ្រើសរើសថ្ងៃណាមួយក្នុងខែ
-រៀបចំក្រុមអធិការកិច្ច និងអនុវត្តការងារអធិការកិច្ចក្នុងកម្រង ដោយសហការជាមួយក្រុម DTMT3
-ផលិតសម្ភារឧបទេសបម្រើការបង្រៀន និងរៀន
-រៀបចំកម្មវិធីអប់រំបំណិនជីវិតងាយៗតាមមូលដ្ឋាន ដោយសហការជាមួយសហគមន៍
-ពង្រឹងការអនុវត្តសកម្មភាពបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល
-រៀបចំដំណើរការថ្នាក់កុមារមេត្រីគ្រប់កម្រិតថ្នាក់តាមសាលាបង្គោល និងសាលាសម្ព័ន្ធ
-រៀបចំឱ្យមានដំណើរការពិសោធមុខវិជ្ជាវិទ្យាសាស្ត្រ ក្លិបគណិតវិទ្យា និងក្លិបវិទ្យាសាស្ត្រ ។

- **សហគមន៍**

-ចលនាសហគមន៍ឱ្យចូលរួមកសាង  និងអនុវត្តផែនការអភិវឌ្ឍន៍កម្រងសាលារៀន និងសាលារៀន
-សហការជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ឱ្យចូលរួមការពារថែរក្សាទ្រព្យសម្បត្តិសាលារៀន និងទប់ស្កាត់បាតុភាពមិនប្រក្រតី
-ជំរុញមាតាបិតាសិស្សឱ្យ ជួយប្រមូលកុមារចូលរៀន និងជំរុញការសិក្សារបស់កូនចៅ
-បំផុសសហគមន៍ឱ្យស្វែងរកថវិកា សម្ភារៈ ដើម្បីជួយកសាង ជួសជុល និងកែលម្អសាលារៀន ថ្នាក់រៀន
-ចលនាសហគមន៍ឱ្យចូលរួមផ្សព្វផ្សាយ និងទាក់ទាញសប្បុរសជនជួយដល់កម្មវិធីនានារបស់សាលារៀន
-បំផុស និងចលនាសហគមន៍ឱ្យចូលរួមអប់រំ ផ្សព្វផ្សាយវប្បធម៌ និងបំណិនងាយៗដល់គ្រូ-សិស្ស។

## គ.លក្ខខណ្ឌកម្រិតអភិវឌ្ឍន៍

កម្រងសាលារៀនដែលត្រូវបានកំណត់ក្នុងកម្រិតអភិវឌ្ឍន៍ នៅពេលដែលគ្រប់សាលាសម្ព័ន្ធបានបំពេញសព្វគ្រប់នូវលក្ខខណ្ឌនានាក្នុងកម្រិតមូលដ្ឋាន និងកម្រិតមធ្យមប្រកបដោយជោគជ័យ និងឈានទៅពង្រីកសកម្មភាពបន្ថែមដូចជា៖

- **រដ្ឋបាល**

-មនសិការវិជ្ជាជីវៈគ្រូបង្រៀន ត្រូវបានលើកកម្ពស់ស្របតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនច្បាប់ស្តីពីការអប់រំ សេចក្តីណែនាំនានា ប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ត្រូវបានផ្សព្វផ្សាយ និងអនុវត្តប្រកបដោយប្រសិទ្ធភាព
-កុមារជួបការលំបាក (កុមារពិការ កុមារក្រីក្រ កុមារងាយរងគ្រោះ កុមារជនជាតិភាគតិច កុមារី) ត្រូវបានចូលរៀនស្របតាមចំណុចដៅនៃឆ្នាំនីមួយៗ

-ក្រុមប្រឹក្សាយុវជន និងកុមារមានដំណើរការយ៉ាងសកម្មលើគ្រប់រូបភាព

-ការលើកកម្ពស់យេនឌ័រ និងទីប្រឹក្សាកុមារីត្រូវបានអនុវត្តលើគ្រប់សកម្មភាព

-ម៉ោង និងប្រតិទិនសិក្សាត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននៅគ្រប់សាលាសម្ព័ន្ធ។

- **បច្ចេកទេស**

-គ្រប់សាលាសម្ព័ន្ធ មានការអភិវឌ្ឍលើគ្រប់សមាសភាគនៃសាលាកុមារមេត្រី ស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតអភិវឌ្ឍន៍

-គុណភាពសាលារៀននីមួយៗ មានកម្រិតប្រហាក់ប្រហែលគ្នា ពិសេសអត្រាឡើងថ្នាក់ និងអត្រាបញ្ចប់ការសិក្សា និងអត្រាប្រឡងជាប់ស្របតាមចំណុចដៅ

-អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាត្រូវបានកាត់បន្ថយជាអតិបរមាស្របតាមចំណុចដៅ

-កម្មវិធីសិក្សា និងកម្មវិធីអប់រំបំណិនជីវិតត្រូវបានយកចិត្តទុកដាក់ខ្ពស់ និងមានដំណើរការជាប្រចាំស្របតាមតម្រូវការរបស់មូលដ្ឋាន

-ការប្រជុំបច្ចេកទេស ការជួយសិស្សរៀនយឺត ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនប្រកបដោយការទទួលខុសត្រូវ

-រៀបចំឱ្យមាន និងដំណើរការពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្រ ក្លិបគណិតវិទ្យា និងក្លិបវិទ្យាសាស្ត្រ ។

- **សហគមន៍**

-សហគមន៍មានការយល់ដឹងខ្ពស់អំពីភារកិច្ចរបស់ខ្លួន និងបានចូលរួមអនុវត្តយ៉ាងសកម្មក្នុង វិស័យអប់រំ

-មាតាបិតានាំកូនមកចូលរៀនបានច្រើនជាអតិបរមា និងជួយតាមដាន ព្រមទាំងជំរុញឱ្យមានការខិតខំរៀនសូត្រគ្រប់ៗគ្នា

-សហគមន៍មានភាពម្ចាស់ការក្នុងការទទួលខុសត្រូវចំពោះសាលារៀន ដោយចាត់ទុកថាសាលារៀនជាមជ្ឈមណ្ឌលរបស់សហគមន៍ ដើម្បីអភិវឌ្ឍសហគមន៍ ។

### ៥.៤.លក្ខណៈវិនិច្ឆ័យសាលាបង្គោល

សាលាបង្គោលគប្បីជាសាលាមានកម្រិតអភិវឌ្ឍន៍ខ្ពស់ជាងគេ (អាចជាវិទ្យាល័យ ឬអនុវិទ្យាល័យដែលមានលក្ខណៈសមស្របជាងគេ) ហើយមានទីតាំងដែលមានចម្ងាយសមស្រប អាចឱ្យសាលាសម្ព័ន្ធទាំងអស់ងាយទាក់ទងគ្នាទៅវិញទៅមកៈ

-មានបុគ្គលិកដែលមានសមត្ថភាព អាចបម្រើការងារកម្រងសាលារៀនបាន

-មានបរិវេណធំទូលាយ អាចសង់អគារ ឬពង្រីកហេដ្ឋារចនាសម្ព័ន្ធបន្ថែមបាន

-មានការចូលរួមពីសហគមន៍យ៉ាងខ្លាំងក្លាទាំងការកសាង ការការពារ និងការអប់រំ

-មានការគ្រប់គ្រងល្អ និងមានគ្រូបង្រៀនល្អច្រើនប្រកបដោយមនសិការវិជ្ជាជីវៈ

-មានបន្ទប់ អាចរៀបចំជាមជ្ឈមណ្ឌលធនធាន (ទីចាត់ការកម្រង បណ្ណាល័យ រោងជាង គេហកិច្ច បន្ទប់វប្បធម៌...)

-មានចក្ខុវិស័យ និងបេសកកម្មរបស់សាលារៀនច្បាស់លាស់

-មានសូចនាករទាំង១០ (អត្រារួមនៃការសិក្សា អត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់...) ច្បាស់លាស់ល្អ។

## ៦.ការបង្កើតក្រុមប្រឹក្សា និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សា

### ៦.១.ការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន

ដើម្បីឱ្យគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនអនុវត្តការងារបានល្អ គណៈកម្មការនេះត្រូវមានក្រុមប្រឹក្សាមួយសម្រាប់ពិគ្រោះ ពិភាក្សា វាយតម្លៃរាល់លទ្ធផលសម្រេចបាន និងលើកផែនការអភិវឌ្ឍន៍

ផែនការសកម្មភាពសម្រាប់អនុវត្ត ។ ក្រុមប្រឹក្សានេះមានសមាសភាពចម្រុះដែលមានឈ្មោះថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន។

**ក.ការជ្រើសរើសក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន**

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន នាយកសាលា ដើម្បីពិនិត្យជ្រើសរើសចៅអធិការវត្ត នាយកសាលាមធ្យមសិក្សា អភិបាល ឬអភិបាលស្រុករង អធិការស្រុក មេឃុំ ចៅសង្កាត់ នាយប៉ុស្តិ៍រដ្ឋបាល មេភូមិ គណៈកម្មការនារី ក្រុមប្រឹក្សាយុវជន និងកុមារ ចាស់ព្រឹទ្ធាចារ្យ សប្បុរសជនដែលមានប្រជាប្រិយភាព និមន្ត និងអញ្ជើញចូលរួមជាសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានជាក្រុមដែលគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនត្រូវធ្វើការពិគ្រោះការងារជាមួយ។ ក្រុមនេះគ្មានប្រធាន អនុប្រធានទេ មានតែប្រធានគណៈកម្មការកម្រងដែលជាលេខាធិការអចិន្ត្រៃយ៍។ ពេលប្រជុំក្រុមប្រឹក្សានេះត្រូវជ្រើសរើសម្នាក់ធ្វើជាប្រធានដឹកនាំ និងលេខាម្នាក់សម្រាប់កត់ត្រា ។

**ខ.សមាសភាព**

| លរ | សមាសភាព | ផ្សេងៗ |
|---|---|---|
| ១ | ព្រះអនុគណស្រុក ឬព្រះគ្រូចៅអធិការវត្ត | |
| ២ | សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | |
| ៣ | អភិបាល ឬអភិបាលស្រុករងទទួលបន្ទុកការងារអប់រំ និងវប្បធម៌ | |
| ៤ | មេឃុំ-ចៅសង្កាត់ (ពាក់ព័ន្ធ) | |
| ៥ | ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន | លេខាធិការអចិន្ត្រៃយ៍ |
| ៦ | អធិការក្រុង ស្រុក ខណ្ឌ ឬនាយប៉ុស្តិ៍រដ្ឋបាល ឃុំ សង្កាត់ពាក់ព័ន្ធក្នុងកម្រង | |
| ៧ | ប្រធានអនុគណៈកម្មការបច្ចេកទេស | |
| ៨ | ប្រធានអនុគណៈកម្មការរដ្ឋបាល | |
| ៩ | ប្រធានអនុគណៈកម្មការសហគមន៍ | |
| ១០ | ប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព | |
| ១១ | គណៈកម្មការនារី-កុមារ ស្រុក ឬឃុំ សង្កាត់ | |
| ១២ | ក្រុមប្រឹក្សាយុវជន និងកុមារ | |
| ១៣ | នាយកសាលាមធ្យមសិក្សាក្នុងកម្រង។ | |

**បញ្ជាក់៖** ចំនួនសមាជិកនារី គួរមានចំនួនអប្បបរមាស្មើចំនួនសាលារៀននៅក្នុងកម្រង។ ប្រសិនបើចំនួនមិនគ្រប់ លេខាធិការត្រូវពិនិត្យមើលបេក្ខភាពក្នុងចំណោមអ្នកគ្រូ ឬក្នុងចំណោមសមាជិកសហគមន៍ ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័តបំពេញបន្ថែម។

**គ.តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សា**

-ដឹកនាំសាលារៀននីមួយៗ កសាងឱ្យបានផែនការអភិវឌ្ឍន៍សាលារៀនរយៈពេលវែង និងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ ដោយអនុវត្តផែនការនោះបណ្តើរៗ។ ផែនការនេះត្រូវកសាងដោយមានការចូលរួម

ពីនាយក នាយករង គ្រូបង្រៀនទាំងអស់ មាតា-បិតាសិស្ស ប្រធានគណៈកម្មការសហគមន៍ មេឃុំ ចៅសង្កាត់ក្រុមប្រឹក្សាយុវជន និងកុមារប្រចាំសាលារៀន និងអ្នកពាក់ព័ន្ធដទៃទៀត

-គាំទ្រផែនការរយៈពេលវែង និងផែនការប្រចាំឆ្នាំរបស់សាលាមធ្យមសិក្សានីមួយៗ ហើយធ្វើសកម្មភាពសមស្រប ដើម្បីឧបត្ថម្ភ និងពិនិត្យតាមដានសកម្មភាពអនុវត្តរបស់សាលាមធ្យមសិក្សាទាំងនោះ

-ពិនិត្យ និងបិទផ្សាយតារាងប្រាក់ចំណូល ចំណាយប្រចាំឆ្នាំរបស់សាលាមធ្យមសិក្សានីមួយៗ ដើម្បីធានាការទទួលខុសត្រូវ និងតម្លាភាព

-ជួយសាលាមធ្យមសិក្សាក្នុងការអនុវត្តផែនការ ដោយចលនាប្រភពធនធានពីមូលដ្ឋាន រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយជាតិ និងអន្តរជាតិ

-សម្រួលការអនុវត្តគោលនយោបាយ និងសេចក្តីណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា

-ជួយសម្របសម្រួល និងទាក់ទងថ្នាក់លើ ក្នុងការដោះស្រាយរាល់បញ្ហាប្រឈមរបស់មូលដ្ឋាន

-កំណត់ស្តង់ដា និងគោលនយោបាយរួម (**ឧទាហរណ៍:** ដូចជាការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ការប្រើប្រាស់សម្ភារឧបទេស គោលការណ៍ឡើងថ្នាក់របស់សិស្ស ការប្រឡងបញ្ចប់មធ្យមសិក្សាបឋមភូមិ ការអនុវត្តសិទ្ធិកុមារ បរិយាកាសសិក្សាកុមារមេត្រី ការប្រើប្រាស់ថវិកា តម្លាភាពចំណូលចំណាយ សម្រាប់កម្រងសាលារៀន និងការពិនិត្យតាមដានការអនុវត្តការងារ)

-រៀបចំការប្រជុំថ្នាក់កម្រងមុនបវេសនកាល ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំសិក្សា ដោយអញ្ជើញគ្រូបង្រៀន ប្រធានគណៈកម្មការទ្រទ្រង់សាលា មាតាបិតាសិស្ស តំណាងសិស្សពីគ្រប់សាលារៀនចូលរួមស្តាប់ និងពិនិត្យរបាយការណ៍លំអិតអំពីការអនុវត្តសកម្មភាពការងារ ដំណោះស្រាយបញ្ហាកន្លងមក បញ្ជីចំណូល ចំណាយរបស់គណៈកម្មការកម្រងសាលាមធ្យមសិក្សា

-ធ្វើរបាយការណ៍បូកសរុបសមិទ្ធផល និងបញ្ហាប្រចាំឆ្នាំរបស់សាលារៀន ជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ។

### ឃ.ការប្រជុំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សា ប្រជុំយ៉ាងហោចណាស់ ៣ ដងក្នុង ១ ឆ្នាំ គឺមុនបវេសនកាល ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំសិក្សា ដើម្បីពិនិត្យមើលស្ថានការណ៍ និងធ្វើសេចក្តីសម្រេចចិត្តដោះស្រាយបញ្ហានានា។

ការប្រជុំត្រូវផ្តោតសំខាន់លើចំណុចមួយចំនួនដូចខាងក្រោមៈ

- ការប្រជុំមុនបវេសនកាល

-ប្រជុំកែសម្រួលផែនការអភិវឌ្ឍន៍របស់សាលាសម្ព័ន្ធក្នុងកម្រង

-ពិនិត្យផែនការប្រចាំឆ្នាំរបស់សាលារៀន និងត្រួតពិនិត្យតម្រូវការសម្ភារៈសិក្សាដូចជាសៀវភៅសិស្ស សៀវភៅគ្រូ ដែលអាចរកបាន

-ពិនិត្យឡើងវិញលើដំណោះស្រាយសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារៈដទៃទៀតដែលបានស្នើឡើង និងឆ្លងផែនការកម្រងសាលារៀនដែលថ្លែងឡើងដោយប្រធានគណៈកម្មការ

- ការប្រជុំដំណាច់ឆមាសទី១

-បូកសរុបការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនឆមាសទី១ និងលើកទិសដៅឆមាសទី២

-ពិនិត្យវត្តមានរបស់គ្រូ-សិស្ស និងលទ្ធផលប្រឡងឆមាសទី១ នៅទូទាំងកម្រងហើយមានវិធានការសមស្របក្នុងការពង្រឹងគុណភាពសិក្សា ការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាឱ្យបានទាន់ពេលវេលា។

- ការប្រជុំដំណាច់ឆ្នាំ

-បូកសរុប និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន និងលើកទិសដៅសម្រាប់ឆ្នាំបន្ត

-ពិនិត្យលទ្ធផលសិក្សា លើកទិសដៅ យុទ្ធវិធីបង្កើនបរិមាណ និងគុណភាពសិស្សនៅឆ្នាំបន្ទាប់។ សាលាមធ្យមសិក្សាទាំងអស់ ត្រូវគោរពសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្រងសាលាមធ្យមសិក្សា ប្រសិនបើសាលារៀនណាមួយ ឬគ្រូណាម្នាក់មិនព្រមគោរពសេចក្តីសម្រេចនេះ ក្រុមប្រឹក្សានឹងធ្វើការបញ្ចុះបញ្ចូលឱ្យយល់ និងអនុវត្តតាម។ ដំណាក់កាលចុងក្រោយប្រសិនបើនៅតែមិនអនុវត្តតាមក្រុមប្រឹក្សានេះ នឹងសុំឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ សម្រុះសម្រួល និងចាត់វិធានការសមស្រប។ នាយកសាលានីមួយៗ ទទួលខុសត្រូវលើការអនុវត្តសេចក្តីសម្រេចនេះ។

## ៦.២.ការបង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានជាក្បាលម៉ាស៊ីនដឹកនាំ និងជំរុញសកម្មភាពអភិវឌ្ឍន៍កម្រងសាលារៀនឱ្យមានដំណើរការល្អ។ សមាសភាពគណៈកម្មការមានចំនួនច្រើន ឬតិចទៅតាមទ្រង់ទ្រាយកម្រងសាលារៀនធំ ឬតូចតាមរចនាសម្ព័ន្ធរដ្ឋបាលមានស្រាប់នៅមូលដ្ឋាន។

**ក.សមាសភាព**

| **លរ** | **សមាសភាព** | **តួនាទី** |
|---|---|---|
| ១ | អភិបាល ឬអភិបាលស្រុករង ទទួលបន្ទុកការងារអប់រំ និងវប្បធម៌ | ជាប្រធានកិត្តិយស |
| ២ | នាយកវិទ្យាល័យ ឬអនុវិទ្យាវិទ្យាល័យ ១ រូប | ជាប្រធាន |
| ៣ | នាយកវិទ្យាល័យ ឬអនុវិទ្យាល័យ ១ រូប | ជាអនុប្រធានទទួលបន្ទុកបច្ចេកទេស |
| ៤ | នាយកវិទ្យាល័យ ឬអនុវិទ្យាល័យ ១ រូប | ជាអនុប្រធានទទួលបន្ទុករដ្ឋបាល |
| ៥ | តំណាងសហគមន៍ ១ រូប | ជាអនុប្រធាន ទទួលបន្ទុកសហគមន៍ |
| ៦ | នាយកវិទ្យាល័យ និងអនុវិទ្យាល័យទាំងអស់ក្នុងកម្រង | ជាសមាជិក |
| ៧ | ប្រធានគណៈកម្មការទ្រទ្រង់សាលាទាំងអស់ក្នុងកម្រង | ជាសមាជិក |
| ៨ | ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជាគ្រប់កម្រិតថ្នាក់ទាំងអស់ | ជាសមាជិក |
| ៩ | លេខាធិការសាលារៀនមួយ ឬពីររូប | ជាលេខាធិការ |

## អង្គការលេខគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន




### ខ.វិធីជ្រើសរើសគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ ដឹកនាំជ្រើសរើស និងរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន។

- ការជ្រើសរើសប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន៖

**អ្នកឈរឈ្មោះ៖** នាយកសាលាមធ្យមសិក្សា (វិទ្យាល័យ និងអនុវិទ្យាល័យ) ទាំងអស់ក្នុងកម្រង

**អ្នកបោះឆ្នោត៖**

-នាយក នាយករងសាលាមធ្យមសិក្សា ក្នុងកម្រងទាំងអស់ក្នុងកម្រង

-ប្រធានសហគមន៍គ្រប់សាលាមធ្យមសិក្សាក្នុងកម្រង និងអាជ្ញាធរមូលដ្ឋាន

-ប្រធាន-អនុប្រធានក្រុមបច្ចេកទេសសាលាមធ្យមទាំងអស់ក្នុងកម្រង

**លទ្ធផលរាប់សន្លឹកឆ្នោត**

អ្នកបានទទួលសន្លឹកឆ្នោតច្រើនជាងគេជាប់ជាប្រធាន។ ប្រធានជាប់ឆ្នោតត្រូវជ្រើសរើស អនុប្រធាន ២រូប ក្នុងចំណោមនាយកសាលាសម្ព័ន្ធទាំងអស់ឱ្យទទួលបន្ទុកការងារបច្ចេកទេស និងការងាររដ្ឋបាល

**ការទទួលស្គាល់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន**

ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានត្រូវធ្វើសំណើសុំទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡា តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ចុះហត្ថលេខាតែងតាំងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀន និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានជាផ្លូវការ

- ការជ្រើសរើសអនុគណៈកម្មការ និងក្រុមការងារនៃកម្រងសាលារៀនមូលដ្ឋាន៖

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានអាចបង្កើតអនុគណៈកម្មការ និងក្រុមការងារដើម្បីប្រតិបត្តិការងារតាមសេចក្តីត្រូវការចាំបាច់។ យ៉ាងហោចណាស់កម្រងនីមួយៗ គួរចាត់តាំងអនុប្រធានឱ្យដឹកនាំអនុគណៈកម្មការដូចខាងក្រោម៖

-អនុគណៈកម្មការទទួលបន្ទុករដ្ឋបាល

-អនុគណៈកម្មការទទួលបន្ទុកបច្ចេកទេស

-អនុគណៈកម្មការទទួលបន្ទុកសហគមន៍

ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន ស្នើសុំយោបល់សម្រេចទទួលស្គាល់អនុប្រធានគណៈកម្មការ ឬក្រុមការងារពីគណៈកម្មការអភិវឌ្ឍន៍កម្រងមូលដ្ឋានទាំងមូល។ នាយក នាយករង សិក្ខាបនធារីបុគ្គលិក សមាជិកគណៈកម្មការសហគមន៍ក៏អាចជាសមាជិកអនុគណៈកម្មការ ឬក្រុមការងារបានដែរ។ សមាសភាព និងភារកិច្ចរបស់អនុគណៈកម្មការ ត្រូវសម្រេចដោយគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន។

**បញ្ជាក់៖**

-សមាសភាពគណៈកម្មការអភិវឌ្ឍន៍កម្រងមធ្យមសិក្សាមូលដ្ឋាន អាចប្រែប្រួលទៅតាមមូលដ្ឋានជាក់ស្តែង។ ការិយាល័យអបរំ យុវជន និង កីឡាក្រុង ស្រុក ខណ្ឌ អាចសុំយោបល់ពីមន្ទីរអប់រំ យុវជន និងកីឡាធ្វើការកែប្រែតាមស្ថានភាពជាក់ស្តែង

-គណៈកម្មការអភិវឌ្ឍន៍កម្រងមធ្យមសិក្សាមូលដ្ឋាននីមួយៗអាចបំពេញតួនាទី និងភារកិច្ចទៅតាមសមត្ថភាពរបស់ខ្លួនតាមការណែនាំរបស់ថ្នាក់លើ និងសេចក្តីត្រូវការរបស់សាលារៀន

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន មានអាណត្តិ ៣ឆ្នាំ តែអាចសើរើបោះឆ្នោតឡើងវិញមុនចប់អាណត្តិ ក្រោមការសម្រេចរបស់ការិយាល័យអប់រំ យុវជននិងកីឡាក្រុង ស្រុក ខណ្ឌ ប្រសិនបើមានករណីចាំបាច់

-អ្នកជាប់ឆ្នោត និងអ្នកដែលត្រូវតែងតាំងក្នុងគណៈកម្មការកម្រងមូលដ្ឋានត្រូវបំពេញភារកិច្ចក្នុងសាលារៀនរបស់ខ្លួនដដែលគ្រាន់តែទទួលភារកិច្ចបន្ថែម ក្នុងតំណែងនៃគណៈកម្មការកម្រងតែប៉ុណ្ណោះ។

- ការជ្រើសរើសអនុប្រធានគណៈកម្មការកម្រងទទួលបន្ទុករដ្ឋបាល និងបច្ចេកទេស៖

គណៈកម្មការអភិវឌ្ឍន៍កម្រង តែងតាំងអនុប្រធានគណៈកម្មការកម្រងដោយខ្លួនឯង។ អនុប្រធានគណៈកម្មការកម្រងទទួលបន្ទុករដ្ឋបាល ត្រូវពិនិត្យជ្រើសរើសក្នុងចំណោមនាយកសាលាក្នុងកម្រង។ អនុប្រធានគណៈកម្មការកម្រងទទួលបន្ទុកបច្ចេកទេស ត្រូវពិនិត្យក្នុងចំណោម នាយកសាលា ឬនាយករងសាលាទទួលបន្ទុកបច្ចេកទេស នៃសាលារៀនក្នុងកម្រង។

លេខាធិការ និងបណ្ណារក្ស នៃសាលាបង្គោលក្លាយជាលេខាធិការ និងបណ្ណារក្ស របស់កម្រងសាលារៀន។ ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងត្រូវជ្រើសរើសបុគ្គលិកម្នាក់ក្នុងសាលាបង្គោលតែងតាំងជាអ្នកទទួលខុសត្រូវបន្ទប់ធនធានសម្ភារៈ។

- អនុប្រធានទទួលបន្ទុកសហគមន៍

**អ្នកឈរឈ្មោះ៖**

ប្រធានគណៈកម្មការទ្រទ្រង់សាលាមធ្យមសិក្សាទាំងអស់នៅក្នុងកម្រង។

**អ្នកបោះឆ្នោត៖**

ប្រធាន និងអនុប្រធានគណៈកម្មការទ្រទ្រង់សាលារៀនទាំងអស់នៅក្នុងកម្រង និងនាយក នាយករង សាលាមធ្យមសិក្សាទាំងអស់ក្នុងកម្រង។

**លទ្ធផលរាប់សន្លឹកឆ្នោត៖**

អ្នកទទួលសន្លឹកឆ្នោតគាំទ្រច្រើនជាងគេ ជាប់ជាអនុប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងទទួលបន្ទុកសហគមន៍ និងជាប្រធានសហគមន៍ប្រចាំកម្រង។ អ្នកមិនជាប់ឆ្នោតទាំងអស់ជាអនុប្រធានសហគមន៍ប្រចាំកម្រង និងជាសមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន។

**គ.ការជ្រើសរើសប្រធានក្រុមបច្ចេកទេសប្រចាំកម្រងតាមមុខវិជ្ជា**

ការបោះឆ្នោតជ្រើសរើសប្រធានក្រុមបច្ចេកទេសប្រចាំកម្រង ធ្វើឡើងទៅតាមមុខវិជ្ជានីមួយៗ ដាច់ពីគ្នាបានសេចក្ដីថា មួយមុខវិជ្ជា ត្រូវបោះឆ្នោតជ្រើសរើសប្រធានម្នាក់ប្រចាំកម្រង។

**អ្នកឈរឈ្មោះ៖**

ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗនៅតាមសាលាមធ្យមសិក្សាក្នុងកម្រង។

**អ្នកបោះឆ្នោត៖**

ប្រធាន អនុប្រធាន និងសមាជិកក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗ នៅតាមសាលាមធ្យមសិក្សាក្នុងកម្រង។

**លទ្ធផលរាប់សន្លឹកឆ្នោត៖**

អ្នកទទួលសន្លឹកឆ្នោតគាំទ្រច្រើនជាងគេជាប់ជាប្រធានក្រុមបច្ចេកទេសប្រចាំកម្រង។ អ្នកមិនជាប់ឆ្នោតទាំងអស់ជាអនុប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា ប្រចាំកម្រង។

**ឃ.តួនាទី និងភារកិច្ចគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន**

គណៈកម្មការនេះ ជាផ្នែកប្រតិបត្តិមួយរបស់កម្រងសាលាមធ្យមសិក្សាមូលដ្ឋានហើយដើរតួនាទីជាអ្នកអនុវត្តភារកិច្ច តាមការឯកភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សា។ ភារកិច្ចរបស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានមានដូចខាងក្រោម៖

- អភិវឌ្ឍផែនការរបស់កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន

តួនាទីសំខាន់របស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន គឺជំរុញសាលាមធ្យមសិក្សានីមួយៗ កសាង និងអនុវត្តផែនការរយៈពេលវែង ផែនការប្រចាំឆ្នាំ ដោយផ្សារភ្ជាប់កម្មវិធីសាលាកុមារមេត្រីដើម្បីសម្រេចផែនការអប់រំ។

- គ្រប់គ្រងប្រភពធនធាន

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានគ្រប់គ្រងការចែកចាយ និងប្រើប្រាស់ធនធានរួមនៅក្នុងកម្រង ដូចជាធនធានមនុស្ស សម្ភារៈ ហិរញ្ញវត្ថុ និងតាមដានត្រួតពិនិត្យវាយតម្លៃ និងកែលម្អការប្រើប្រាស់ធនធានទាំងនោះឱ្យបានត្រឹមត្រូវ។

- កសាងសមត្ថភាព

**ការបំប៉នសមត្ថភាពគ្រូ៖**

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន ចាត់ចែងគ្រូទាំងអស់ក្នុងកម្រងប្រជុំដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក លើការងារបច្ចេកទេសបង្រៀន និងបទពិសោធនៃការជួយសិស្សរៀនយឺត...។

**ការជួយជីវភាព៖**

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន សម្របសម្រួលជាមួយប្រធានគណៈកម្មការទ្រទ្រង់សាលា ចលនាប្រមូលធនធានក្នុងមូលដ្ឋានជួយឧបត្ថម្ភគ្រូបង្រៀនដែលជួបការខ្វះខាតខ្លាំងនិងសហការ ជាមួយអ្នកផ្តល់ជំនួយខាងក្រៅ ដើម្បីអនុវត្តគម្រោងរកចំណូលជួយគ្រូដែលមានការលំបាក ដូចជាគម្រោងឥណទាន ឬសកម្មភាពផ្សេងៗទៀត ដែលមានប្រយោជន៍ដល់គ្រូបង្រៀន។

**ការជួយកុមារ៖**

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន ជំរុញការជួយសង្គ្រោះកុមារ និងការចូលរួមរបស់កុមារ ក្នុងសកម្មភាពសាលារៀនព្រមទាំងជំរុញការបង្កើតក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី កម្មវិធីអប់រំសុខភាព និងព្រឹត្តិការណ៍ពិសេសធំៗរបស់កុមារ

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាស្រាវជ្រាវកុមារជួបការលំបាកក្នុងមូលដ្ឋាន និងធ្វើយ៉ាងណាឱ្យកុមារទាំងនោះបានសិក្សា ពិសេសកុមារីបានរៀនចប់មធ្យមសិក្សាបឋមភូមិ និងបន្តរៀននៅមធ្យមសិក្សាទុតិយភូមិទៀត ។

**ការជួយពីមាតាបិតា និងអាណាព្យាបាលសិស្ស៖**

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន រៀបចំកម្មវិធីអប់រំមាតា បិតាសិស្សឱ្យចេះជួយកូនរៀនសូត្របានល្អ

-គណៈកម្មការទាក់ទងជាមួយមណ្ឌលសុខភាព រៀបចំទិវាអប់រំសុខភាព អនាម័យតាមសាលារៀន ដើម្បីពិនិត្យជំងឺ ចាក់ថ្នាំបង្ការរោគឱ្យកុមារ និងផ្តល់ការអប់រំសុខភាពដល់ មាតាបិតាសិស្ស

-គណៈកម្មការត្រូវជំរុញគ្រប់សាលាមធ្យមសិក្សា ឱ្យធ្វើទំនាក់ទំនងជាមួយគ្រួសារសិស្សឱ្យបានល្អតាមរយៈការប្រើប្រាស់សៀវភៅទំនាក់ទំនង ដើម្បីផ្តល់ព័ត៌មាន និងកែលម្អស្ថានភាពសិក្សារបស់សិស្សឱ្យបានទាន់ពេលវេលា។

- **អធិការកិច្ចសាលារៀន៖**

នាយកសាលាជាអធិការដ៏សំខាន់នៃសាលារៀននីមួយៗ។ នាយកសាលាមធ្យមសិក្សាទទួលខុសត្រូវក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀន នៅក្នុងសាលារៀនរបស់ខ្លួន។ នាយកសាលាទទួលខុសត្រូវការងារអធិការកិច្ចគ្រូបង្រៀន ក្នុងសាលារៀនផ្ទាល់ និងចូលរួមធ្វើអធិការកិច្ចជាមួយគណៈកម្មការកម្រងដែរ។

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន ផ្តល់ការគាំទ្រដល់អធិការកិច្ចគ្រប់សាលារៀននៅក្នុងកម្រងដោយត្រូវកំណត់ឱ្យបានច្បាស់អំពីមុខសញ្ញា កម្មវត្ថុ ចំនួនពេលដែលត្រូវចុះពិនិត្យ។ អធិការកិច្ចនេះត្រូវផ្តោតការយកចិត្តទុកដាក់លើការជួយគ្រូបង្រៀនផ្នែករដ្ឋបាលគ្រប់គ្រង ថ្នាក់រៀន និងបច្ចេកទេសបង្រៀន និងរៀន។

- **ការគ្រប់គ្រងថវិកា៖**

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានគ្រប់គ្រងថវិការបស់កម្រង។ នាយកសាលា និងប្រធានគណៈកម្មការទ្រទ្រង់សាលារៀននីមួយៗ ជាអ្នកគ្រប់គ្រង និងប្រើប្រាស់ថវិការបស់សាលារៀន ។ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានបិទផ្សាយបញ្ជីចំណូល ចំណាយថវិកាទាំងអស់នោះនៅទីចាត់ការកម្រង ហើយលើកទឹកចិត្តឱ្យសាលារៀននីមួយៗ បិទផ្សាយដូចគ្នាដែរ។

- **ការចូលរួមរបស់សហគមន៍៖**

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន រៀបចំការប្រជុំមាតាបិតាសិស្សប្រចាំឆ្នាំដើម្បីជំរុញ និងណែនាំពួកគាត់ឱ្យជួយអប់រំកូនចៅ សម្របសម្រួលជាមួយការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ បង្កើតគណៈកម្មការទ្រទ្រង់សាលារៀនតាមសាលារៀននីមួយៗ ។ គណៈកម្មការទាំងនោះត្រូវជំរុញសាលារៀនរបស់ខ្លួន ប្រជុំរវាងគ្រូ និងមាតាបិតាសិស្ស ឱ្យបានទៀងទាត់ និងរៀបចំការប្រជុំប្រចាំឆ្នាំ ដោយមានមាតាបិតាសិស្ស ប្រធានគណៈកម្មការទ្រទ្រង់សាលា និងកុមារចូលរួម។

## ប្រព័ន្ធគ្រប់គ្រងកម្រងសាលារៀន



## ៦.៣.មុខងារ និងសកម្មភាពសំខាន់ៗរបស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន

### ក.ការងាររដ្ឋបាល

-ប្រជុំពិភាក្សា បន្តអនុវត្តសេចក្តីសម្រេចដែលបានដាក់ចុះឱ្យបានទៀងទាត់

-ពិនិត្យមើលសកម្មភាពអនុវត្តផែនការប្រចាំឆ្នាំរបស់សាលារៀននីមួយៗឱ្យទៀងទាត់

-ចាត់វិធានការសម្របសម្រួលឱ្យសាលារៀនអនុវត្តម៉ោង និងប្រតិទិនសិក្សាទៀងទាត់តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា

-ចាត់វិធានការសម្របសម្រួលឱ្យគ្រូ និងសិស្សអនុវត្តម៉ោងសិក្សាបានហ្មត់ចត់ និងមិនខ្វះខ្វាយ

-ចាត់វិធានការសម្របសម្រួលឱ្យគ្រូ និងសិស្សមកសាលារៀនទៀងទាត់និងទាន់ពេលវេលា

-ចាត់វិធានការចែកចាយសៀវភៅសិក្សា (Tx-Tm) ឱ្យដល់គ្រូ-សិស្សទាន់ពេលវេលា

-ធ្វើអធិការកិច្ចសាលារៀនសម្ព័ន្ធតាមផែនការ និងទៀងទាត់

-រក្សាឱ្យមានទិន្នន័យអប់រំថ្មីៗ ពីសាលារៀនសម្ព័ន្ធ និងសហគមន៍

-រៀបចំគោលការណ៍ ដើម្បីទទួលស្គាល់ស្នាដៃល្អរបស់គ្រូ នាយកសាលា គណៈកម្មការ សហគមន៍ និងសមាជិកផ្សេងៗទៀតរបស់សហគមន៍

-ជួយពិនិត្យបញ្ជីចំណូល ចំណាយរបស់សាលារៀននីមួយៗក្នុងមួយឆ្នាំម្តង និងធ្វើយ៉ាងណាឱ្យគ្រប់សាលាមធ្យមសិក្សាទុកដាក់ឯកសារនោះបានគត់មត់ល្អ

-ចាត់វិធានការសមស្របដោយពង្រឹងសាលានីមួយៗឱ្យមានតម្លាភាពក្នុងការធ្វើបញ្ជីហិរញ្ញវត្ថុ

-រៀបចំឱ្យនាយកសាលា គ្រូបង្រៀន មាតាបិតាសិស្សមានសាមគ្គីភាព និងមានទំនាក់ទំនងគ្នាល្អក្នុងសាលាមធ្យមសិក្សានីមួយៗ

-ជួយសម្របសម្រួលការប្រាស្រ័យទាក់ទងរវាងសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ

-ប្រមូលទិន្នន័យព័ត៌មាន ស្ថិតិអំពីស្ថានភាពសាលារៀនដូចជាអគារសិក្សា បន្ទប់រៀន សង្ហារិម បង្គន់អនាម័យ អណ្តូងទឹកស្អាត គ្រូ សិស្ស ...

-ក្នុងករណីចាំបាច់បែងចែកធនធានមនុស្សនៅក្នុងកម្រង ឱ្យសមាមាត្រគ្នា

-ស្នើសុំយោបល់ដំឡើងឋានៈ លើកសរសើរ ជូនរង្វាន់ដល់លោកគ្រូ-អ្នកគ្រូ និងមន្ត្រីដែលបំពេញភារកិច្ចទទួលបានស្នាដៃល្អ ។

### ខ.ការងារបច្ចេកទេស

-ជំរុញការបង្រៀន និងរៀន តាមគោលវិធីសិស្សមជ្ឈមណ្ឌលនៅគ្រប់សកម្មភាពបង្រៀន និងរៀនឱ្យស្របតាមគោលការណ៍នានា នៃកម្មវិធីសាលាកុមារមេត្រី

-រៀបចំបរិស្ថានសាលារៀនដើម្បីទាក់ទាញការចូលរៀន និងចូលរួមសកម្មភាពរៀនសូត្ររបស់សិស្ស

-ស្វែងយល់អំពីតម្រូវការបំប៉ន ការប្រជុំ និងសិក្ខាសាលាដើម្បីរៀបចំបំប៉នគ្រូ ឬផ្លាស់ប្តូរបទពិសោធទៅវិញ ទៅមក និងដោះស្រាយបញ្ហាគរុកោសល្យ ដែលគ្រូជួបប្រទះ

-រៀបចំសកម្មភាពមជ្ឈមណ្ឌលធនធានឱ្យមានដំណើរការល្អ ដោយឱ្យគ្រូចូលមកផលិត និងខ្ចីសម្ភារឧបទេសយកទៅប្រើប្រាស់

-រៀបចំបណ្ណាល័យមួយឱ្យមានដំណើរការល្អ ដោយផ្តល់សេវាកម្មអចិន្ត្រៃយ៍ដល់កុមារនៅសាលាបង្គោល និងសេវាកម្មចល័តដល់កុមារគ្រប់សាលាសម្ព័ន្ធ
-រៀបចំក្រុមអធិការកិច្ចចម្រុះរវាងនាយកសាលា និងប្រធានក្រុមបច្ចេកទេស ដើម្បីជួយគ្រូនៅពេលបង្រៀន
-តាមដានការអនុវត្តកម្មវិធីសិក្សានៅក្នុងសាលារៀន
-ធានាឱ្យសាលារៀនទាំងអស់អនុវត្តស្វ័យវាយតម្លៃយ៉ាងទៀងទាត់ និងស្វ័យកែលម្អឱ្យបានទាន់ពេលវេលាដោយសហការជាមួយអ្នកពាក់ព័ន្ធនានាក្នុងសាលារៀន
-រៀបចំនិងដំណើរការការងារពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្រ ក្លិបគណិតវិទ្យា និងក្លិបវិទ្យាសាស្ត្រ
-ពិនិត្យលទ្ធផលសិក្សារបស់សិស្សប្រុស សិស្សស្រី ដោយចាត់វិធានការសមស្រប កែលម្អលទ្ធផលសិស្សដោយធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងការសិក្សារបស់សិស្សប្រុស និងសិស្សស្រីក្នុងសាលារៀន រវាងសាលារៀនមួយ និងសាលារៀនមួយទៀត។

**គ.ភារៈខាងសេដ្ឋកិច្ច**

-រៀបចំទំនិញជុំ និងដឹកជញ្ជូនរួមគ្នា ដើម្បីសន្សំសំចៃថវិកា
-រក្សាសម្ភារៈមានតម្លៃក្នុងមជ្ឈមណ្ឌលធនធាន រួចបែងចែងពេលវេលាប្រើប្រាស់រួមបន្តគ្នាពីសាលារៀនមួយ ទៅសាលារៀនមួយ
-បង្កើនសមត្ថភាព ក្នុងការកៀរគរ រកមូលនិធិសម្រាប់អភិវឌ្ឍន៍សាលារៀន
-ជួយសាលារៀនក្នុងការរកថវិកាពីសប្បុរសជន រដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល
-ធ្វើអាជ្ញាកណ្តាល បែងចែកថវិកាដែលបានពីក្រៅដល់សាលារៀន និងតាមដានការប្រើប្រាស់ថវិកានោះឱ្យបានត្រឹមត្រូវ
-ចលនាសុំជំនួយពីមូលដ្ឋាន និងពីខាងក្រៅសម្រាប់ជួយសាលារៀនតូចៗ។

**ឃ.ភារៈខាងសហគមន៍**

-សហការជាមួយអាជ្ញាធរមូលដ្ឋាន ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀនសមាជិកទាំងអស់ក្នុងការបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន និងជំរុញឱ្យមានសកម្មភាពគ្រប់សាលារៀន
-លើកទឹកចិត្តសាលារៀននីមួយៗឱ្យប្រជុំមាតាបិតាសិស្ស និងគណៈកម្មការទ្រទ្រង់សាលារៀន អ្នកដឹកនាំសហគមន៍ ដើម្បីពិនិត្យ សកម្មភាពអនុវត្តក្នុងឆ្នាំកន្លងមក និងលើកទឹកចិត្តអនុវត្តសម្រាប់ឆ្នាំថ្មី
-រៀបចំគណៈកម្មការទ្រទ្រង់សាលាពីគ្រប់សាលាសម្ព័ន្ធ ដើម្បីធ្វើការប្រជុំប្រចាំឆ្នាំពិនិត្យមើលដំណើរការសកម្មភាព និងកំណត់វិធានការដោះស្រាយបញ្ហាដែលនៅសេសសល់
-លើកទឹកចិត្តសាលារៀន ឱ្យធ្វើទំនាក់ទំនងជាមួយមាតាបិតាសិស្ស អំពីការសិក្សារបស់សិស្ស (ការមករៀននិងរៀន) បានទៀតទាត់
-លើកទឹកចិត្តឱ្យសហគមន៍ ប្រើប្រាស់ទីតាំងអគាររបស់សាលារៀន ដើម្បីជាផលប្រយោជន៍សហគមន៍ក្នុងទិសដៅអូសទាញសហគមន៍ឱ្យជួយកសាង និងថែរក្សាសាលារៀនវិញ
-ជំរឿនស្ថិតិកុមារ ក្នុងផែនទីកម្រងសាលារៀន មុនបវេសនកាលរៀងរាល់ឆ្នាំដើម្បីធ្វើការវិភាគអំពីការរីកចម្រើន និងផលប៉ះពាល់ដែលកើតមានសម្រាប់ជាមូលដ្ឋាននៃការត្រៀមលក្ខណៈនាឆ្នាំបន្ទាប់ ។

## ៧.ការបង្កើតអនុគណៈកម្មការនានា

### ៧.១.អនុគណៈកម្មការរដ្ឋបាល

អនុគណៈកម្មការរដ្ឋបាលកម្រងសាលារៀន ជាកម្លាំងចលករអចិន្ត្រៃយ៍នៃការងាររដ្ឋបាលក្នុងកម្រងសាលារៀន ពិសេសការងារនៅក្នុងមជ្ឈមណ្ឌលធនធានរបស់កម្រង។

**ក.សមាសភាព**

| | |
|---|---|
| ១. អនុប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមទទួលបន្ទុករដ្ឋបាល | ប្រធាន |
| ២. នាយក-នាយករងគ្រប់សាលារៀនសម្ព័ន្ធទទួលបន្ទុករដ្ឋបាល | អនុប្រធាន |
| ៣. ក្រុមលេខាធិការ ក្រុមបណ្ណារក្ស ក្រុមគ្រូពេងជាង | សមាជិក |

**ខ.តួនាទី**

ជាសេនាធិការឱ្យគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន លើការងាររដ្ឋបាលក្នុងកម្រង។

**គ.ភារកិច្ច**

-ផ្សព្វផ្សាយរាល់លិខិតបទដ្ឋានរបស់មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាដល់គ្រប់សាលាសម្ព័ន្ធ

-អនុវត្តសេចក្តីសម្រេច របស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានលើការងាររដ្ឋបាល

-រៀបចំសកម្មភាពរដ្ឋបាល ដើម្បីដំណើរការមជ្ឈមណ្ឌលធនធាន

-រៀបចំកម្មវិធីអធិការកិច្ចលើការងាររដ្ឋបាល

-រៀបចំចាត់ចែងរាល់ការប្រជុំរបស់គណៈកម្មការកម្រង និងរាល់ការប្រជុំរបស់អនុគណៈកម្មការ

-សហការជិតស្និទ្ធជាមួយក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT3) លើគ្រប់សកម្មភាពបំប៉ន និងបណ្តុះបណ្តាល

-សហការល្អជាមួយអនុគណៈកម្មការបច្ចេកទេស ដើម្បីដំណើរការមជ្ឈមណ្ឌលធនធាន

-លើកផែនការ និងគម្រោងអភិវឌ្ឍន៍កម្រងសាលារៀនឱ្យស្របតាមកម្មវិធីសាលាកុមារមេត្រី

-ប្រមូលផ្តុំព័ត៌មាន ដែលទាក់ទងនឹងកម្រងសាលារៀន

-ចងក្រង និងគ្រប់គ្រងស្ថិតិអប់រំរបស់កម្រង និងធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំសិក្សា។

អនុគណៈកម្មការនេះប្រជុំរៀងរាល់សប្តាហ៍ទី៤ នៃខែនីមួយៗ និងតាមការចាំបាច់នៅសាលាបង្គោល ឬសាលាសម្ព័ន្ធណាមួយ។

ដើម្បីអនុវត្តភារកិច្ចឱ្យបានសម្រេច ប្រកបដោយប្រសិទ្ធភាព អនុគណៈកម្មការរដ្ឋបាលគួរចែកជា ៣ ក្រុមទៅតាមជំនាញ ។

- **ភារកិច្ចក្រុមលេខាធិការ** (សាលាបង្គោល និងសម្ព័ន្ធ)

-រៀបចំការប្រជុំផ្សេងៗក្នុងកម្រង និងធ្វើកំណត់ហេតុអង្គប្រជុំ

-ចូលរួមដឹងឮរាល់ចំណូល ចំណាយរបស់សាលារៀន

-គ្រប់គ្រងស្ថិតិកុមារ និងប្រជាជនក្នុងផែនទីកម្រង

-ប្រមូល និងគ្រប់គ្រងស្ថិតិ ទិន្នន័យព័ត៌មានដាក់ជូនគណៈកម្មការកម្រង វិភាគ វាយតម្លៃ ធ្វើផែនការ

-រៀបចំធ្វើតារាងស្ថិតិទិន្នន័យ សម្រាប់តាំងបង្ហាញ

-រៀបចំ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ
-រៀបចំ និងរក្សាទុកឯកសារនានារបស់ក្រសួងឱ្យបានត្រឹមត្រូវ
-ធ្វើរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារគ្រប់ផ្នែកក្នុងកម្រង ជូនគណៈកម្មការអភិវឌ្ឍន៍កម្រង
-ជួយរៀបចំសកម្មភាពកីឡា សិល្បៈ កសិកម្ម និងកម្មវិធីផ្សេងៗទៀត
-ជួយរៀបចំពិធីបុណ្យទានផ្សេងៗក្នុងសាលារៀន។

- **ភារកិច្ចក្រុមបណ្ណារក្ស** (សាលាបង្គោល និងសម្ព័ន្ធ)

-ធ្វើប្រព័ន្ធសេវាកម្មចែកចាយ (បញ្ជី សៀវភៅ និងលេខកូដ...)
-ទំនាក់ទំនង ផ្សព្វផ្សាយអំពីសកម្មភាពបណ្ណាល័យ
-រៀបចំផែនការសកម្មភាពបំរើសេវាក្នុងបណ្ណាល័យ
-ជួយបង្រៀនអំពីរបៀបតុបតែងលម្អ
-ជួយរៀបចំសកម្មភាពសិក្សាស្រាវជ្រាវ
-ជួយរៀបចំសកម្មភាពសិល្បៈ ការតាំងពិព័រណ៍
-បូកសរុបសកម្មភាពបណ្ណាល័យក្នុងកម្រងរាល់ដំណាច់ឆមាស និងដំណាច់ឆ្នាំសិក្សា។

- **ភារកិច្ចក្រុមរោងជាង** (គ្រូទទួលបន្ទុកធនធាន គ្រូរោងជាងតាមសាលាសម្ព័ន្ធ)

-លើកផែនការសកម្មភាព សម្រាប់បំរើសេវាក្នុងរោងជាងរាល់ដើមឆ្នាំសិក្សា
-ស្រាវជ្រាវគំរូសម្ភារឧបទេស ចងក្រង និងទុកដាក់តាមប្រភេទ និងតម្រូវការ
-សហការជាមួយប្រធានក្រុមបច្ចេកទេស និងសិក្ខាបនធារីដើម្បីផលិតសម្ភារឧបទេស
-ផ្សព្វផ្សាយ និងចែកចាយសម្ភារៈផលិតរួច ជូនដល់សាលាសម្ព័ន្ធ និងគ្រូបង្រៀន
-ស្រាវជ្រាវ និងចងក្រងពីរបៀបផលិត និងប្រើប្រាស់សម្ភារឧបទេសនានា
-រៀបចំ និងគ្រប់គ្រងសកម្មភាពកសិកម្ម
-រៀបចំ និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងសម្ភារឧបទេសដែលបានផលិត
-បូកសរុបវាយតម្លៃសកម្មភាពរោងជាង និងកសិកម្មរាល់ដំណាច់ឆមាស និងដំណាច់ឆ្នាំក្នុងកម្រងសាលារៀន។

## អង្គការលេខអនុគណៈកម្មការរដ្ឋបាល

**អនុគណៈកម្មការរដ្ឋបាល**

**ក្រុមលេខាធិការ**
- លេខាធិការកម្រង
- លេខាធិការសាលាសម្ព័ន្ធ

**ភារកិច្ចៈ**
- រៀបចំគ្រប់ការប្រជុំ
- គ្រប់គ្រងលិខិតបទដ្ឋាន
- ស្ថិតិទិន្នន័យព័ត៌មាន
- បូកសរុបលទ្ធផលការងារគណៈកម្មការកម្រង (ប្រចាំឆមាស និងឆ្នាំ)...

**ក្រុមបណ្ណារក្ស**
- បណ្ណារក្សសាលាបង្គោល
- បណ្ណារក្សសាលាសម្ព័ន្ធ

**ភារកិច្ចៈ**
- សេវាកម្ម
- ផ្សព្វផ្សាយ
- ទំនាក់ទំនង
- ថែរក្សា
- ស្រាវជ្រាវ
- បូកសរុប និងវាយតម្លៃការងារបណ្ណាល័យ...

**ក្រុមគ្រូធនធានសម្ភារៈ**
-គ្រូទទួលបន្ទុកបន្ទប់ធនធាន សម្ភារៈ
-គ្រូរោងជាង សិល្បៈ កីឡា...សាលាសម្ព័ន្ធ

**ភារកិច្ចៈ**
- ផលិតសម្ភារឧបទេស
- សេវាកម្ម
- ផ្សព្វផ្សាយ
- ថែរក្សា
- ស្រាវជ្រាវ
- បូកសរុប និងវាយតម្លៃការងាររោងជាង សិល្បៈ កីឡា...

### ៧.២.អនុគណៈកម្មការបច្ចេកទេស

អនុគណៈកម្មការបច្ចេកទេសកម្រងសាលារៀន ជាកម្លាំងចលករអចិន្ត្រៃយ៍នៃការងារបច្ចេកទេស។

**ក.សមាសភាព**

| | |
|---|---|
| ១.អនុប្រធាន គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាទទួលបន្ទុកបច្ចេកទេស | ប្រធាន |
| ២.នាយក-នាយករង គ្រប់សាលារៀនសម្ព័ន្ធទទួលបន្ទុកបច្ចេកទេស | អនុប្រធាន |
| ៣.ប្រធានក្រុមបច្ចេកទេសគ្រប់មុខវិជ្ជាក្នុងកម្រងសាលារៀន | សមាជិក |

**ខ.តួនាទី**

អនុគណៈកម្មការបច្ចេកទេស ជាសេនាធិការឱ្យគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនលើគ្រប់ការងារបច្ចេកទេស។

**គ.ភារកិច្ច**

-ជំរុញ និងពង្រឹងការអនុវត្តលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងបច្ចេកទេសដែលផ្សព្វផ្សាយដោយក្រសួង មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា

-អនុវត្តសេចក្តីសម្រេចចិត្តរបស់គណៈកម្មការអភិវឌ្ឍន៍កម្រង លើការងារបច្ចេកទេស

-រៀបចំសកម្មភាពប្រជុំបច្ចេកទេសទៅតាមផែនការរបស់កម្រង (ដឹកនាំការប្រជុំ ត្រៀមមុនការប្រជុំ)

-រៀបចំផែនការ និងវិធានការកាត់រម្លស់សិស្សរៀនយឺតនៅតាមសាលារៀន

-កសាងកម្រងសំណួរ ឬតែស្តសម្រាប់វាយតម្លៃការសិក្សារបស់សិស្ស

-ពិនិត្យលទ្ធផលសិក្សារបស់សិស្សនៅចុងឆមាសទី១ ទី២ និងដំណាច់ឆ្នាំ និងត្រៀមវិធានការកែលម្អ

-តាមដាន ត្រួតពិនិត្យសកម្មភាពក្រុមបច្ចេកទេសក្នុងកម្រងសាលារៀន

-រៀបចំសកម្មភាពអធិការកិច្ច ក្នុងកម្រងសាលារៀន ដោយសហការជាមួយក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT)

-រៀបចំកម្មវិធីបំប៉នការងារបច្ចេកទេសផ្សេងៗ និងកម្មវិធីអប់រំបំណិនជីវិត ដោយសហការជាមួយក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT)

-ធ្វើរបាយការណ៍ការងារបច្ចេកទេសជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន រាល់ដំណាច់ឆមាស និងរាល់ដំណាច់ឆ្នាំសិក្សា។

អនុគណៈកម្មការនេះ ប្រជុំរៀងរាល់ខែម្តងនៅសាលាបង្គោល ឬនៅសាលាសម្ព័ន្ធណាមួយតាមការកំណត់។

ដើម្បីសម្រេចប្រកបដោយប្រសិទ្ធភាព នូវភារកិច្ចខាងលើ អនុគណៈកម្មការនេះត្រូវបែងចែកជាក្រុមបច្ចេកទេសទៅតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ សម្រាប់មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ និងតាមស្ថានភាពជាក់ស្តែង។

**ក.ចំពោះសាលារៀនធំ**

ត្រូវចែកជាក្រុមបច្ចេកទេសតាមមុខវិជ្ជា ១០ តាមកម្រិតថ្នាក់ ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២ ដូចបានបង្ហាញក្នុងអង្គការលេខអនុគណៈកម្មការបច្ចេកទេសសម្រាប់សាលារៀនធំ។

- ក្រុមបច្ចេកទេសភាសាខ្មែរថ្នាក់ទី ៧

១.សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនទទួលបន្ទុកភាសាខ្មែរថ្នាក់ទី៧ ប្រធាន

២. ប្រធានក្រុមបច្ចេកទេសទទួលបន្ទុក ភាសាខ្មែរថ្នាក់ទី៧ ទាំងអស់ក្នុងកម្រងសាលារៀន អនុប្រធាន

៣. គ្រូបង្រៀន ភាសាខ្មែរថ្នាក់ទី៧ ទាំងអស់ក្នុងកម្រងសាលារៀន សមាជិក

- ក្រុមបច្ចេកទេសគីមីថ្នាក់ទី១០

១. សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនទទួលបន្ទុកមុខវិជ្ជាគីមី ថ្នាក់ទី១០ ប្រធាន

២. ប្រធានក្រុមបច្ចេកទេសមុខវិជ្ជា គីមីថ្នាក់ទី១០ ទាំងអស់ក្នុងកម្រងសាលារៀន អនុប្រធាន

៣. គ្រូបង្រៀនមុខវិជ្ជា គីមីថ្នាក់ទី១០ ទាំងអស់ក្នុងកម្រងសាលារៀន សមាជិក

**ខ.សម្រាប់សាលារៀនមធ្យម (ក)**

ត្រូវចែកជាក្រុមបច្ចេកទេស ១០ មុខវិជ្ជាសម្រាប់មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ដូចបានបង្ហាញក្នុងអង្គការលេខអនុគណៈកម្មការបច្ចេកទេសសម្រាប់សាលារៀនមធ្យម **ក** ។

- ក្រុមបច្ចេកទេសផែនដីវិទ្យាសម្រាប់មធ្យមសិក្សាបឋមភូមិ

១. សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនទទួលបន្ទុកមុខវិជ្ជាផែនដីវិទ្យា ប្រធាន

២. ប្រធានក្រុមបច្ចេកទេស ផែនដីវិទ្យាទាំងអស់ក្នុងកម្រងសាលារៀន អនុប្រធាន

៣. គ្រូបង្រៀន ផែនដីវិទ្យាទាំងអស់ក្នុងកម្រងសាលារៀន សមាជិក

- ក្រុមបច្ចេកទេសគីមីវិទ្យាសម្រាប់មធ្យមសិក្សាទុតិយភូមិ

១. សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនទទួលបន្ទុកមុខវិជ្ជាគីមីវិទ្យា ប្រធាន

២. ប្រធានក្រុមបច្ចេកទេសគីមីវិទ្យាទាំងអស់ក្នុងកម្រងសាលារៀន អនុប្រធាន

៣. គ្រូបង្រៀមុខវិជ្ជាគីមីវិទ្យាទាំងអស់ក្នុងកម្រងសាលារៀន សមាជិក

**គ.សម្រាប់សាលារៀនមធ្យម (ខ)**

ត្រូវចែកជាក្រុមបច្ចេកទេស **៥** បណ្តុំមុខវិជ្ជាសម្រាប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។ ដូចបានបង្ហាញក្នុងអង្គការលេខអនុគណៈកម្មការបច្ចេកទេសសម្រាប់សាលារៀនមធ្យម **ខ** ។

**ឃ.សម្រាប់សាលារៀនតូច**

ត្រូវចែកក្រុមបច្ចេកទេសជា **២** បណ្តុំមុខវិជ្ជាគឺក្រុមវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមសម្រាប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។ ដូចបានបង្ហាញក្នុងអង្គការលេខ អនុគណៈកម្មការបច្ចេកទេសសម្រាប់សាលារៀនតូច។

**អង្គការលេខអនុគណៈកម្មការបច្ចេកទេសកម្រង (សាលារៀនធំ ក)**




១. សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាទទួលបន្ទុក មុខវិជ្ជាភាសាខ្មែរ ប្រធាន

២. ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាភាសាខ្មែរ ទាំងអស់ក្នុងកម្រង អនុប្រធាន

៣.គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ ទាំងអស់ក្នុងកម្រង សមាជិក

## អង្គការលេខអនុគណៈកម្មការបច្ចេកទេសកម្រង (សាលារៀនមធ្យម ក)

**ក្រុមបច្ចេកទេសថ្នាក់ទី ៧ទៅ៩ ថ្នាក់ទី១០ទៅ ១២និង ៧ទៅ១២**

| ក្រុមបច្ចេកទេស **ភាសាខ្មែរ** | ក្រុមបច្ចេកទេស **គណិតវិទ្យា** | ក្រុមបច្ចេកទេស **រូបវិទ្យា** | ក្រុមបច្ចេកទេស **គិមីវិទ្យា** | ក្រុមបច្ចេកទេស **ជីវៈវិទ្យា** | ក្រុមបច្ចេកទេស **ផែនដីវិទ្យា** | ក្រុមបច្ចេកទេស **ភូមិវិទ្យា** | ក្រុមបច្ចេកទេស **ប្រវត្តិវិទ្យា** | ក្រុមបច្ចេកទេស **ពលរដ្ឋវិទ្យា** | ក្រុមបច្ចេកទេស **ភាសាបរទេស** |
|---|---|---|---|---|---|---|---|---|---|

| | |
|---|---|
| ១. សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនទទួលបន្ទុកមុខវិជ្ជាគណិតវិទ្យា | ប្រធាន |
| ២. ប្រធានក្រុមបច្ចេកទេសមុខវិជ្ជា គណិតវិទ្យា ទាំងអស់ក្នុងកម្រង | អនុប្រធាន |
| ៣. គ្រូបង្រៀនមុខវិជ្ជា គណិតវិទ្យា ទាំងអស់ក្នុងកម្រង | សមាជិក |

## អង្គការលេខអនុគណៈកម្មការបច្ចេកទេសកម្រង (សាលារៀនមធ្យម ខ)

ក្រុមបច្ចេកទេសថ្នាក់ទី៧-១២ ឬ ១០-១២

| ក្រុមបច្ចេកទេស **ភាសាខ្មែរ** | ក្រុមបច្ចេកទេស **គណិតវិទ្យា** | ក្រុមបច្ចេកទេស **រូប គីមី ជីវៈ ផែនដី** | ក្រុមបច្ចេកទេស **ប្រវត្តិ ភូមិ ពលរដ្ឋ** | ក្រុមបច្ចេកទេស **ភាសាបរទេស** |
|---|---|---|---|---|

| | |
|---|---|
| ១.សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន មុខវិជ្ជាភាសាខ្មែរថ្នាក់ទី៧ ដល់ ថ្នាក់ទី១២ | ប្រធាន |
| ២.ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាភាសាខ្មែរ ថ្នាក់ទី៧ ដល់ ថ្នាក់ទី១២ ទាំងអស់ ក្នុងកម្រង | អនុប្រធាន |
| ៣.គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ ថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ទាំងអស់ក្នុងកម្រង | សមាជិក |

## អង្គការលេខអនុគណៈកម្មការបច្ចេកទេស (សាលារៀនមធ្យម ខ)

**ក្រុមបច្ចេកទេសថ្នាក់ទី៧, ៨, ៩**

| ក្រុមបច្ចេកទេស **ភាសាខ្មែរ** | ក្រុមបច្ចេកទេស **គណិតវិទ្យា** | ក្រុមបច្ចេកទេស **រូប គីមី ជីវៈ ផែនដី** | ក្រុមបច្ចេកទេស **ប្រវត្តិ ភូមិ ពលរដ្ឋ** | ក្រុមបច្ចេកទេស **ភាសាបរទេស** |
|---|---|---|---|---|

១.សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន មុខវិជ្ជាភាសាបរទេសថ្នាក់ទី៧ ដល់ ថ្នាក់ទី៩ ប្រធាន
២.ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាភាសាបរទេស ថ្នាក់ទី៧ ដល់ ថ្នាក់ទី៩ទាំងអស់ ក្នុងកម្រង អនុប្រធាន
៣.គ្រូបង្រៀនមុខវិជ្ជាភាសាបរទេស ថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ទាំងអស់ក្នុងកម្រង សមាជិក

**អង្គការលេខអនុគណៈកម្មការបច្ចេកទេសកម្រង (សាលារៀនតូច)**




១.សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងទទួលបន្ទុកមុខវិជ្ជា វិទ្យាសាស្ត្រសង្គម ប្រធាន
២.ប្រធានក្រុមបច្ចេកទេសមុខវិជ្ជា វិទ្យាសាស្ត្រសង្គមថ្នាក់ទី៧ដល់ថ្នាក់ទី១២ ទាំងអស់ក្នុងកម្រង អនុប្រធាន
៣.គ្រូបង្រៀនមុខវិជ្ជា វិទ្យាសាស្ត្រសង្គម ថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ទាំងអស់ក្នុងកម្រង សមាជិក

**អង្គការលេខអនុគណៈកម្មការបច្ចេកទេសកម្រង (សាលារៀនតូច)**




១.សមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងទទួលបន្ទុកមុខវិជ្ជា វិទ្យាសាស្ត្រសង្គម ប្រធាន
២.ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ថ្នាក់ទី៧ ដល់ថ្នាក់ទី១២ទាំងអស់ក្នុងកម្រង អនុប្រធាន
៣.គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ទាំងអស់ក្នុងកម្រង សមាជិក

## ៧.៣.ប្រធានក្រុមបច្ចេកទេស

ក្រុមបច្ចេកទេស ជាកម្លាំងចលករសំខាន់ជាងគេ ក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀន។ ដូចនេះប្រធានក្រុមបច្ចេកទេសគប្បីមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

-មានចំណេះដឹងទូលាយ (សមត្ថភាពមូលដ្ឋាន គរុកោសល្យ និងអធិការកិច្ច)

-មានមនសិការវិជ្ជាជីវៈខ្ពស់ ឧស្សាហ៍ ព្យាយាម

-យល់ច្បាស់ អំពីកម្មវិធីសិក្សាថ្មី តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់

-យល់ច្បាស់ និងអនុវត្តល្អនូវគោលវិធី “សិស្សមជ្ឈមណ្ឌល”

-យល់ច្បាស់ពីច្បាប់ស្ដីពីការអប់រំ គោលបំណងអប់រំ គោលការណ៍អប់រំ គោលដៅអប់រំជាតិ គោលនយោបាយអប់រំ សារាចរណែនាំ សេចក្ដីណែនាំ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា

-មានបទពិសោធល្អក្នុងការបង្រៀន និងដឹកនាំការប្រជុំបច្ចេកទេស ធ្វើថ្នាក់និទស្សន៍ និងថ្នាក់បង្ហាញ

-ស្រាវជ្រាវជាប្រចាំទាំងវិធីសាស្ត្របង្រៀន ការផលិត និងប្រើប្រាស់សម្ភារឧបទេស

-មានទំនាក់ទំនងល្អ មានប្រជាប្រិយភាព និងទទួលការគោរពរាប់អានច្រើនពីគ្រូបង្រៀនដូចគ្នា

**ក.តួនាទី**

-ជាសមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន (អនុគណៈកម្មការបច្ចេកទេស)

-ទទួលខុសត្រូវដឹកនាំក្រុមបច្ចេកទេស

-ទទួលខុសត្រូវ លើគុណភាពអប់រំក្នុងកម្រង

-ទទួលខុសត្រូវក្នុងការធ្វើប្រធានវិញ្ញាសាប្រឡងឆមាស ឬតែស្តផ្សេងៗ

-ជាអ្នកបណ្ដុះបណ្ដាល ឬបំប៉នបន្ត និងធ្វើអធិការកិច្ចផ្នែកបច្ចេកទេសក្នុងកម្រងនិង

-ជាទីប្រឹក្សារបស់លោកគ្រូ អ្នកគ្រូក្នុងកម្រង។

**ខ.ភារកិច្ច**

-បង្រៀនមុខវិជ្ជាណាមួយ នៅសាលាបង្គោល ឬសាលាសម្ព័ន្ធ

-ធ្វើថ្នាក់និទស្សន៍ និងថ្នាក់បង្ហាញ ផ្ដល់បទពិសោធដល់លោកគ្រូ-អ្នកគ្រូ

-លើកផែនការសកម្មភាពបង្រៀន និងរៀន ឱ្យប្រព្រឹត្តទៅបានល្អ និងទទួលជោគជ័យ

-ស្រាវជ្រាវឯកសារផ្សេងៗ បម្រើឱ្យការបង្រៀន និងរៀន និងការប្រជុំបច្ចេកទេស

-កែលម្អកិច្ចតែងការបង្រៀនរបស់ក្រុមឱ្យមានការវិវត្តជានិច្ច

-ពិនិត្យតាមដានការបង្រៀនរបស់សមាជិកក្រុម ដើម្បីកែលម្អការបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព

-ខិតខំច្នៃប្រឌិតសម្ភារឧបទេសបម្រើឱ្យការបង្រៀន និងរៀន

-ស្រាវជ្រាវកម្រងសំណួរ តែស្ត សំដៅវាយតម្លៃការសិក្សារបស់សិស្សឱ្យបានត្រឹមត្រូវល្អ

-ចូលរួមកសាងផែនការនានារបស់សាលារៀន និងកម្រងសាលារៀន

-សហការធ្វើកម្មវិធីបង្រៀន ឯកសារណែនាំបង្រៀន ការប្រើប្រាស់សម្ភារឧបទេស

-សហការជាមួយលោកគ្រូ អ្នកគ្រូក្នុងការស្រាវជ្រាវវិធីសាស្ត្របង្រៀន ឱ្យបានកាន់តែប្រសើរឡើង

-រាយការណ៍ និងផ្ដល់យោបល់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនដើម្បីកែលម្អគុណភាពអប់រំ

-បំប៉ន និងផ្សព្វផ្សាយបទពិសោធ វិធីសាស្ត្រ បច្ចេកទេសថ្មីៗដល់លោកគ្រូ អ្នកគ្រូ ដើម្បីពង្រឹងការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព

-ណែនាំប្រើប្រាស់សម្ភារឧបទេស និងសៀវភៅសិក្សាគោលឱ្យស្របតាមគោលការណ៍ និងវិធីសាស្ត្រ

-ជំរុញការប្រើប្រាស់សម្ភារឧបទេសក្នុងបន្ទប់ធនធានសម្ភារៈ និងក្នុងបណ្ណាល័យជាប្រចាំ

-សហការជិតស្និទ្ធជាមួយក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ លើការងារបច្ចេកទេស ដើម្បីពង្រឹង និងអភិវឌ្ឍការងារអប់រំរបស់កម្រងសាលារៀនឱ្យមានដំណើរការស្របគ្នាលើគ្រប់ទិដ្ឋភាព។

**៧.៤.អនុគណៈកម្មការសហគមន៍**

អនុគណៈកម្មការសហគមន៍ ជាកម្លាំងចលករអចិន្ត្រៃយ៍នៃការងារសហគមន៍ក្នុងកម្រងសាលារៀន។

**ក.សមាសភាព**

| លរ | សមាសភាព | តួនាទី |
|---|---|---|
| ១ | អនុប្រធានគណៈកម្មការកម្រងទទួលបន្ទុកការងារសហគមន៍ | ប្រធាន |
| ២ | ប្រធានគណៈកម្មការទ្រទ្រង់សាលា តាមសាលារៀនសម្ព័ន្ធក្នុងកម្រងសាលារៀន | អនុប្រធាន |
| ៣ | ប្រធានគណៈកម្មការទ្រទ្រង់សាលាតាមសាលារៀនសម្ព័ន្ធក្នុងកម្រងសាលារៀន ១ រូប | ហេរញ្ញិក |
| ៤ | ប្រធានគណៈកម្មការទ្រទ្រង់សាលា តាមសាលារៀនសម្ព័ន្ធក្នុងកម្រងសាលារៀន ១ រូប | បេឡា |
| ៥ | អនុប្រធានគណៈកម្មការទ្រទ្រង់សាលា តាមសាលារៀនសម្ព័ន្ធក្នុងកម្រងសាលារៀន | សមាជិក |
| ៦ | នាយកសាលាសម្ព័ន្ធ ១ រូប | លេខាធិការ |

**ខ.តួនាទី**

-ជាសេនាធិការឱ្យគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនលើការងារសហគមន៍

-ទ្រទ្រង់ និងសហការគ្រប់គ្រងថវិកា

-ចូលរួមផ្តល់យោបល់លើការលើកកម្ពស់គុណភាពអប់រំ។

**គ.ភារកិច្ច**

១-ចូលរួមសហការ និងទទួលខុសត្រូវក្នុងការងារអភិបាល ចាត់ចែង គ្រប់គ្រង ប្រើប្រាស់ថវិកាសាលារៀនរួមទាំងចំណូលផ្សេងៗពីអគារធនធានផង

២-ចូលរួមកសាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងចាត់ចែងអនុវត្តផែនការសកម្មភាព

៣-សហការដឹកនាំយុទ្ធនាការផ្សព្វផ្សាយពីសារប្រយោជន៍ ភាពចាំបាច់នៃការអប់រំ និងឱកាសសិក្សាសម្រាប់កុមារក្នុងសហគមន៍

៤-សហការចលនាមាបិតាសិស្សឱ្យចេះតាមដានការសិក្សា និយ័តភាពសិក្សារបស់បុត្រធិតា និងដាស់តឿនឱ្យស្វ័យសិក្សា

៥-ចលនាសហគមន៍ឱ្យចូលរួមថែរក្សា ការពារសម្ភាររូបវន្ត កសាង និងជួសជុលសាលារៀន

៦-សហការជួយពង្រឹងវិន័យ សណ្តាប់ធ្នាប់ សីលធម៌រស់នៅរបស់សិស្ស និងមានវិធានការការពារសុវត្ថិភាពសាលារៀន

៧-សហការដឹកនាំ ចាត់ចែង គ្រប់គ្រងសកម្មភាពបណ្តុះបណ្តាលបំណិនជីវិតតាមមូលដ្ឋាន និងអប់រំវិជ្ជាជីវៈជម្រើស

៨-សហការប្រមូល គ្រប់គ្រងទិន្នន័យសិស្សស្ថិតនៅក្នុងគ្រួសារក្រីក្រ គ្រួសារជួបការលំបាក និងសិស្សកំព្រាគ្មានទីពឹង

៩-ប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរដែនដី ស្ថាប័នជំនាញដែលមានទីតាំងក្នុងតំបន់ឬសហគមន៍។ល។

អនុគណៈកម្មការនេះ ត្រូវធ្វើការប្រជុំ៣ដងក្នុងមួយឆ្នាំ គឺមុនបវេសនកាល ដំណាច់ឆមាសទី ១ និងដំណាច់ឆ្នាំសិក្សា។ ក្នុងករណីចាំបាច់ អាចប្រជុំជាវិសាមញ្ញទៅតាមស្ថានភាពជាក់ស្តែង ។

# អង្គការលេខអនុគណៈកម្មការសហគមន៍



## ៧.៥.ការរៀបចំមជ្ឈមណ្ឌលធនធាននៃកម្រងសាលារៀន

និយាយពីកម្រងសាលារៀន គឺនិយាយពីមជ្ឈមណ្ឌលធនធាន។

### ក.មជ្ឈមណ្ឌលធនធាន

-ជាលេខាធិការដ្ឋាន បណ្ណាល័យ និងបន្ទប់ធនធានសម្ភារៈដែលស្ថិតនៅក្នុងសាលាបង្គោល

-ជាសេនាធិការដ្ឋាន ជាលេខាធិការ និងជាខួរក្បាលរបស់កម្រង

-ជាកន្លែងបំប៉នសមត្ថភាពនៅនឹងកន្លែងនូវធនធានមនុស្សលើការងាររដ្ឋបាល បច្ចេកទេស និងសហគមន៍ ព្រមទាំងជាកន្លែងផលិតធនធានសម្ភារៈ។ កម្រងសាលារៀនអាចអភិវឌ្ឍទៅបានលុះត្រាតែមជ្ឈមណ្ឌលធនធានមានដំណើរការល្អ។

### ខ.ដំណើរការមជ្ឈមណ្ឌលធនធាន

ដំណើរការល្អ ឬមិនល្អនៃមជ្ឈមណ្ឌលធនធានជាសញ្ញាចង្អុលបង្ហាញពីជោគជ័យ ឬបរាជ័យនៃដំណើរអភិវឌ្ឍន៍កម្រងសាលារៀន។ អាស្រ័យហេតុនេះ ទើបគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនប្រគល់ភារកិច្ចឱ្យអនុប្រធានគណៈកម្មការទទួលបន្ទុករដ្ឋបាលជាអ្នកគ្រប់គ្រងផ្ទាល់។

ភារកិច្ចចម្បងរបស់មជ្ឈមណ្ឌលធនធានមាន ៣ គឺៈ

១- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍

២- ការងារផលិត និងផ្សព្វផ្សាយ

៣- សេវាកម្ម។

ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព ភារកិច្ចខាងលើនេះ ត្រូវបានប្រគល់ទៅឱ្យលេខាធិការដ្ឋាន បណ្ណាល័យ និងបន្ទប់ធនធានសម្ភារៈដែលមានអ្នកប្រចាំការនៅទីនោះជាអ្នកគ្រប់គ្រងផ្ទាល់គឺក្រុមលេខាធិការ ក្រុមបណ្ណារក្ស និងក្រុមរោងជាង។

**កំណត់សម្គាល់ៈ** ក្នុងករណីខ្វះបន្ទប់ យើងអាចប្រើប្រាស់បន្ទប់មួយ ឬពីរ តាមលទ្ធភាពជាក់ស្តែង និងជាបណ្តោះអាសន្ន។

**អង្គការលេខមជ្ឈមណ្ឌលធនធាន**




## ៧.៦.ការរៀបចំទីចាត់ការគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន

### ក.លេខាធិការកម្រងសាលារៀន

លេខាធិការ ត្រូវបានជ្រើសរើសតាមការចាត់តាំងរបស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន ដោយមានការឯកភាពពីថ្នាក់លើ និងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

-មានសមត្ថភាពគ្រប់គ្រាន់ ពិសេសយល់ដឹងការងាររដ្ឋបាល និងគ្រប់គ្រង

-មានចរិយាសម្បត្តិល្អ ឈ្លាសវៃ និងស្មោះត្រង់

-មានមនសិការវិជ្ជាជីវៈ និងមានការលះបង់

-មានទំនាក់ទំនងល្អ និងមិនប្រកាន់បក្សពួក ឬរើសអើង ។

លេខាធិការកម្រងសាលារៀន ជាបុគ្គលិកមិនបង្រៀនត្រូវធ្វើការជាប្រចាំ នៅលេខាធិការដ្ឋានកម្រងសាលារៀន។

- **តួនាទី**

-ជាសមាជិកគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន

-ជាលេខាធិការទទួលខុសត្រូវលើលេខាធិការដ្ឋានកម្រងសាលារៀន

-ជាសេនាធិការរបស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន។

- **ភារកិច្ច**

-រៀបចំចាត់ចែងការប្រជុំផ្សេងៗ ធ្វើលិខិតអញ្ជើញសមាជិក សមាជិកាក្នុងកម្រងចូលរួម

-ទំនាក់ទំនង់គ្រប់រូបភាពផ្នែកលិខិតស្នាម ជាមួយសាលាសម្ព័ន្ធនានាក្នុងកម្រង និងជាមួយអង្គភាពស្ថាប័នក្រៅកម្រងសាលារៀន

-សហការគ្រប់គ្រង និងថែរក្សាមជ្ឈមណ្ឌលធនធាន (រោងជាង និងបណ្ណាល័យ)

-ចូលរួមធ្វើផែនការការងារកម្រងសាលារៀន

-រៀបចំតារាងស្ថិតិ ទិន្នន័យ ព័ត៌មានរបស់កម្រងសាលារៀន

-ធ្វើរបាយការណ៍ និងផ្សព្វផ្សាយការងារកម្រងសាលារៀន

-ធ្វើកំណត់ហេតុរាល់សម័យប្រជុំរបស់កម្រង

-ជួយរៀបចំសកម្មភាពកីឡា និងការតាំងពិព័រណ៍របស់កម្រងសាលារៀន

-ជួយតាមដាន ត្រួតពិនិត្យការងារក្នុងកម្រងសាលារៀន

-ជួយរៀបចំបែងចែកទីកន្លែង ឬលិខិតអញ្ជើញមាតា-បិតាសិស្សឱ្យចូលរួមកម្មវិធីបុណ្យទានផ្សេងៗនៅក្នុងកម្រង។

លេខាធិការកម្រងមានភារកិច្ចទទួលខុសត្រូវលើការរៀបចំ និងដំណើរការការប្រជុំរបស់គណៈកម្មការអភិវឌ្ឍន៍កម្រង។ លទ្ធផលនៃការប្រជុំគឺជាសញ្ញាចង្អុលបង្ហាញពីជោគជ័យ ឬបរាជ័យរបស់គណៈកម្មការកម្រង។ ដូចនេះលេខាធិការត្រូវឈ្លាសវៃ រហ័សរហួន ប៉ិនប្រសប់ ទើបទទួលការងារនេះបាន។

**កំណត់សម្គាល់៖** ជាការល្អលេខាធិការកម្រងសាលារៀន គួរជ្រើសរើសយកលេខាធិការដែលមានបទពិសោធលើការងាររដ្ឋបាលរបស់សាលាបង្គោល។

## ខ.បណ្ណារក្សកម្រងសាលារៀន

ទន្ទឹមនឹងលេខាធិការដ្ឋាននៅមានបន្ទប់មួយទៀតសម្រាប់តម្កល់សៀវភៅអាន ឯកសារស្រាវជ្រាវ គំរូសម្ភារឧបទេស និងសម្រាប់ជាសាលអានរបស់គ្រូ សិស្ស សហគមន៍ ឈ្មោះថាបណ្ណាល័យ។ បណ្ណាល័យនេះត្រូវគ្រប់គ្រងដោយបណ្ណារក្ស ១នាក់ ឬ ២នាក់ ទៅតាមលទ្ធភាពជាក់ស្តែង ។ បណ្ណារក្សត្រូវបានជ្រើសរើស និងតែងតាំងក្នុងចំណោមបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលជំនាញបណ្ណាល័យរួចហើយ ដោយគណៈ

កម្មការកម្រង និងមានការឯកភាពពីថ្នាក់លើ ។ ប្រសិនបើគ្មានបណ្ណារក្សដែលបានទទួល ការបណ្តុះបណ្តាលទេ បណ្ណារក្សដែលត្រូវជ្រើសរើសត្រូវជា៖

-បុគ្គលិកមិនបង្រៀន ដែលមានសិស្សស្រឡាញ់ច្រើន ស្រឡាញ់ការងារ និងការស្រាវជ្រាវ

-អ្នករួសរាយរាក់ទាក់ជាមួយភ្ញៀវ ឬអ្នកមកទទួលផល ពីបណ្ណាល័យរបស់កម្រងដោយមិនរើសអើង

-បុគ្គលិក ឧស្សាហ៍ ព្យាយាមក្នុងការងារ

-មនុស្សម៉ឺងម៉ាត់ ទៀងទាត់ និងគោរពវិន័យ។

- **តួនាទី**

-ទទួលខុសត្រូវលើសកម្មភាពបណ្ណាល័យអចិន្ត្រៃយ៍ បណ្ណាល័យចល័ត និងមណ្ឌលវប្បធម៌

-ទទួលខុសត្រូវលើដំណើរការគ្រប់គ្រង ចែកផលបណ្ណាល័យឱ្យទទួលបានផលល្អដល់មហាជន។

- **ភារកិច្ច**

ក្នុងការគ្រប់គ្រងបណ្ណាល័យ បណ្ណារក្សត្រូវ៖

-រៀបចំបណ្ណាល័យឱ្យបានសមស្រប និងមានសោភ័ណភាពដើម្បីទាក់ទាញអ្នកអាន

-ធ្វើបញ្ជីសៀវភៅ លេខកូដ ងាយស្រួលដល់ការខ្ចីឯកសារ

-ប្រមូលទុកដាក់សៀវភៅសិក្សាផ្សេងៗតាមប្រភេទ

-ចងក្រងបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យដើម្បីឱ្យការអាន និងការខ្ចីទទួលបានផលល្អ

-ប្រើសៀវភៅចេញចូល ដើម្បីសម្រួលដល់ការខ្ចីសៀវភៅ ឯកសារផ្សេងៗ ក្នុងបណ្ណាល័យ

-បែងចែកសៀវភៅអាន សម្ភារៈផ្សេងៗដល់សាលាសម្ព័ន្ធ

-លើកផែនការច្បាស់លាស់ ដើម្បីទ្រទ្រង់ និងបម្រើគ្រប់សកម្មភាព ទាំងការងារបណ្ណាល័យអចិន្ត្រៃយ៍ និងបណ្ណាល័យចល័ត

-ចុះតាមដាន ត្រួតពិនិត្យរាល់សកម្មភាពអនុវត្ត

-ស្រង់ស្ថិតិសិស្ស ប្រជាជន ដែលបានចូលមកទទួលផលពីបណ្ណាល័យ ។

**ថែរក្សា ការពារ៖**

-ជួសជុលសៀវភៅចាស់ៗ ឱ្យល្អឡើងវិញដោយមានការចូលរួមពីគ្រូ និងសិស្ស

-ទុកដាក់សៀវភៅទៅតាមកន្លែង ចៀសវាងការច្របូកច្របល់ និងការបាត់បង់

-ធ្វើបញ្ជីសារពើភ័ណ្ឌ និងរក្សាទុកឱ្យបានត្រឹមត្រូវ

-រួមចំណែកការពារបណ្ណាល័យ (ការសំអាត ការយាមកាម) ...។

**គ.គ្រូទទួលបន្ទុកធនធានសម្ភារៈ**

តួនាទី និងភារកិច្ចរបស់អ្នកទទួលបន្ទុកធនធានសម្ភារៈទីនេះគឺសំដៅដល់គ្រប់គ្រងរោងជាង ការផលិតសម្ភារឧបទេសទូទៅ បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលធនធាននៃសាលាបង្គោល។

អ្នកទទួលបន្ទុកកិច្ចការបន្ទប់ធនធានសម្ភារៈនេះ ត្រូវតែងតាំងដោយគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន និងមានការឯកភាពពីថ្នាក់លើ ស្របតាមលក្ខណៈសម្បត្តិដូចខាងក្រោមនេះ៖

-គ្រូបង្រៀនដែលមានចំណេះដឹង បំណិនខាងផ្នែកជាង គំនូរ និងចម្លាក់

-មានបទពិសោធក្នុងការដឹកនាំសកម្មភាពរោងជាង ឬសិប្បកម្ម

-មានកម្រិតច្នៃប្រឌិត និងចាត់ចែងការងារល្អប្រកបដោយការទទួលខុសត្រូវ

-យល់ច្បាស់អំពីវិធីសាស្ត្របង្រៀន

-មានទំនាក់ទំនងល្អ សហការល្អ និងឧស្សាហ៍ព្យាយាម ។

- **តួនាទី**

-ទទួលបន្ទុកការងារផលិតសម្ភារឧបទេសបម្រើការសិក្សាក្នុងកម្រងសាលារៀន

-ធានារ៉ាប់រងគ្រប់សកម្មភាពនៃដំណើរការផលិតសម្ភារឧបទេស

-ធានាថែរក្សាការពារសម្ភារៈសម្រាប់ផលិតសម្ភារឧបទេស និងសេវាកម្មក្នុងកម្រងសាលារៀន

-គ្រប់គ្រងបន្ទប់ពិសោធន៍ និងសម្ភារបរិក្ខារគ្រប់ប្រភេទ។

- **ភារកិច្ច**

**ផលិត៖**

-ស្រាវជ្រាវ ផលិតសម្ភារឧបទេសគំរូ ចងក្រង និងអភិវឌ្ឍ

-ចាត់ចែង បែងចែក និងផលិតសម្ភារឧបទេសតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់

-ផ្តល់មធ្យោបាយសម្រាប់ផលិតដល់ក្រុមនីមួយៗដែលចូលមកផលិត

-ផ្តល់គំនិត និងធ្វើការណែនាំដល់ក្រុមផលិតសម្ភារឧបទេសនានាក្នុងដំណើរការផលិត

-រៀបចំទុកដាក់សម្ភារឧបទេសតាមក្រុម តាមប្រភេទដែលបាន និងត្រូវផលិត

-ធ្វើបញ្ជីសារពើភ័ណ្ឌ សង្ហារិម សម្ភារឧបទេសចាស់ និងថ្មី

-ធ្វើបញ្ជីរាយនាមចំនួនមនុស្សដែលបានចូលមកផលិត និងមកទទួលផលពីរោងជាងតាមត្រីមាស និងតាមឆ្នាំ

-ចងក្រងបទពិសោធ ស្តីពីការផលិត និងប្រើប្រាស់សម្ភារឧបទេស

-ជួយរៀបចំ និងដឹកនាំសកម្មភាពកសិកម្ម សិប្បកម្ម... ក្នុងកម្រងសាលារៀន ។

**សេវាកម្ម៖**

-ផ្សព្វផ្សាយ សម្ភារឧបទេសដែលផលិតបាន

-ធ្វើការវិភាគ ចែកចាយសម្ភារឧបទេសដល់សាលារៀនក្នុងកម្រង

-ធ្វើបញ្ជីអ្នកខ្ចី និងអ្នកសងសម្ភារឧបទេស

-បង្កលក្ខណៈឱ្យគ្រូមកទទួលសម្ភារឧបទេសពីរោងជាងទៅប្រើប្រាស់ ។

**ការពិនិត្យតាមដាន៖**

ពិនិត្យតាមដានការប្រើប្រាស់ ការថែរក្សា ការទុកដាក់សម្ភារឧបទេសតាមសាលារៀនទាំងអស់ក្នុងកម្រងយ៉ាងហោចណាស់ឱ្យបានមួយដងក្នុងមួយត្រីមាស ។

**របាយការណ៍៖**

ធ្វើរបាយការណ៍ពីសកម្មភាពផលិត សេវាកម្មជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនរៀងរាល់ត្រីមាសតាមរយៈលេខាធិការដ្ឋានកម្រងសាលារៀនឱ្យបានទៀងទាត់។

**កំណត់សម្គាល់៖** ក្នុងបន្ទប់ធនធានសម្ភារៈនេះចាំបាច់ត្រូវមាន៖

-ឃ្លាំងទុកសម្ភារៈប្រើប្រាស់ដែលមានទំហំសមស្រប

-ធ្នើរសម្រាប់ដាក់កិច្ចការអ្នកមកផលិត និងសម្រាប់ដាក់វត្ថុធាតុដើម សម្រាប់ផលិត

-ទូដាក់សម្ភារៈ

-តុជាង ឬកៅអី សម្រាប់អារ ឈូស និងឧបករណ៍ជាងឈើ ឬសិប្បកម្មមួយចំនួន

-ក្តារខៀន

-កុំព្យូទ័រ ព្រីនធ័រ និងម៉ាស៊ីនថតចម្លង ...។

## ៨-ការបង្កើតក្រុមប្រឹក្សា និងគណៈកម្មការអភិវឌ្ឍន៍កម្រងថ្នាក់ក្រុង ស្រុក ខណ្ឌ

### ៨.១.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ ជាក្រុមដែលគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌប្រជុំពិគ្រោះការងារ។ ក្រុមនេះគ្មានប្រធាន និងអនុប្រធានទេ មានតែលេខាធិការអចិន្ត្រៃយ៍ម្នាក់ប៉ុណ្ណោះ។ នៅពេលប្រជុំការងារម្តងៗ ក្រុមនេះចាត់តាំងម្នាក់ធ្វើជាប្រធានដើម្បីដឹកនាំ និងលេខាម្នាក់សម្រាប់កត់ត្រា។ លេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត ជាអ្នកព្រាងសមាសភាពក្រុមប្រឹក្សាដើម្បីស្នើសុំការសម្រេច ទទួលស្គាល់ពីអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត។

**ក.សមាសភាព**

| លរ | សមាសភាព | ផ្សេងៗ |
|---|---|---|
| ១ | ព្រះអនុគណក្រុង ស្រុក ខណ្ឌ | |
| ២ | សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | |
| ៣ | អភិបាល នៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ | |
| ៤ | ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាថ្នាក់ ក្រុង ស្រុក ខណ្ឌ | លេខាធិការអចិន្ត្រៃយ៍ |
| ៥ | ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានទាំងអស់ក្នុង ក្រុង ស្រុក ខណ្ឌ | |
| ៦ | ប្រធានសហគមន៍ប្រចាំកម្រងសាលាមូលដ្ឋានទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌ | |
| ៧ | នាយកវិទ្យាល័យ/អនុវិទ្យាល័យ | |

**ខ.ភារកិច្ច**

ក្រុមប្រឹក្សានេះប្រជុំ៣ដងក្នុងមួយឆ្នាំគឺមុនបវេសនកាល ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំសិក្សាក្រោមការអញ្ជើញរបស់លេខាធិការ ដើម្បីបូកសរុប ត្រួតពិនិត្យ វាយតម្លៃលទ្ធផលសិក្សារបស់សិស្សានុសិស្ស ការអភិវឌ្ឍកម្រងសាលារៀនទូទាំងក្រុង ស្រុក ខណ្ឌ និងលើកផែនការសកម្មភាព ដើម្បីឱ្យគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ និងកម្រងសាលារៀនមូលដ្ឋានអនុវត្ត។

### ៨.២.គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន ថ្នាក់រាជធានី ខេត្ត ជាអ្នករៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ក.សមាសភាព**

| លរ | **សមាសភាព** | **តួនាទី** |
|---|---|---|
| ១ | អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ | ប្រធានកិត្តិយស |
| ២ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ | ប្រធាន |
| ៣ | អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ | អនុប្រធានអចិន្ត្រៃយ៍ |

| | | |
|---|---|---|
| ៤ | ប្រធានសហាគមន៍ប្រចាំ ក្រុង ស្រុក ខណ្ឌ (បើមាន) | អនុប្រធាន |
| ៥ | ប្រធានផ្នែករដ្ឋបាល | ហេរញ្ញិក |
| ៦ | ប្រធានផ្នែកចំណេះទូទៅ | លេខាធិការ |
| ៧ | ប្រធានផ្នែកអប់រំក្រៅប្រព័ន្ធ យុវជន និងកីឡា | សមាជិក |
| ៨ | ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានទាំងអស់ | សមាជិក |
| ៩ | ប្រធានសហាគមន៍ប្រចាំកម្រងសាលារៀនមូលដ្ឋានទាំងអស់ | សមាជិក |

## ខ.តួនាទី និងភារកិច្ច

**តួនាទី៖**

-ជាសេនាធិការជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត

-ដឹកនាំ និងគ្រប់គ្រងកម្រងសាលារៀនទូទាំងក្រុង ស្រុក ខណ្ឌ

-អធិការកិច្ចលើគ្រប់ផ្នែកអប់រំក្នុងក្រុង ស្រុក ខណ្ឌ។

**ភារកិច្ច៖**

-លើកសំណើទៅថ្នាក់លើក្នុងការកំណត់ទីតាំងកម្រងសាលាមធ្យមសិក្សាក្នុងក្រុង ស្រុក ខណ្ឌ

-រៀបចំគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាក្នុងក្រុង ស្រុក ខណ្ឌ

-ឱ្យយោបល់និងសម្រេច លើផែនការកម្រងសាលាមធ្យមសិក្សា របស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាក្នុងក្រុង ស្រុក ខណ្ឌ

-ឱ្យយោបល់និងសម្រេចលើសំណើរបស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានក្នុងការផ្លាស់ប្តូរសមាសភាពគណៈកម្មការនានា

-ផ្សព្វផ្សាយលិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់រាជធានី ខេត្ត ដែលបានដាក់ឱ្យអនុវត្ត

-កសាងផែនការបំប៉ន និងអធិការកិច្ចតាមដានការងាររដ្ឋបាល និងបច្ចេកទេសក្នុងកម្រងសាលាមធ្យមសិក្សា ដោយសហការជាមួយក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ ក្រុង ស្រុក ខណ្ឌ (DTMT)

-តាមដាន ត្រួតពិនិត្យ ការផលិត ការប្រើប្រាស់សម្ភារៈ ថវិកាកម្រងសាលាមធ្យមសិក្សា

-ដឹកនាំទស្សនកិច្ចដកពិសោធន៍ រវាងក្រុង ស្រុក ខណ្ឌ និងរវាងរាជធានី ខេត្ត

-រៀបចំផែនការអភិវឌ្ឍន៍ និងផែនការសកម្មភាពកម្រងសាលាមធ្យមសិក្សា ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការកម្រងថ្នាក់រាជធានី ខេត្ត

-ជំរុញសកម្មភាពប្រឡងប្រណាំងគ្រប់ផ្នែកអប់រំ រវាងកម្រងសាលាមធ្យមសិក្សាក្នុងក្រុង ស្រុក ខណ្ឌ

-ជំរុញលើកទឹកចិត្តរាល់សកម្មភាពអនុវត្តរបស់កម្រងសាលាមធ្យមសិក្សា

-ប្រមូលព័ត៌មាន ចងក្រងស្ថិតិ ទិន្នន័យការងារអប់រំតាមកម្រងសាលាមធ្យមសិក្សាក្នុងក្រុង ស្រុក ខណ្ឌ

-ជំរុញគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន ដើម្បីជួយពង្រឹងគុណភាពអប់រំនៅសាលាមធ្យមសិក្សាដាច់ស្រយាល

-ដោះស្រាយបញ្ហាដែលកម្រងសាលាមធ្យមសិក្សាបានជួបប្រទះ

-រៀបចំ និងអនុវត្តផែនការប្រចាំឆ្នាំឱ្យបានទៀងទាត់

-បូកសរុប និងវាយតម្លៃសកម្មភាពអនុវត្តការងារកម្រងសាលាមធ្យមសិក្សារាល់ដំណាច់ឆមាស និង ដំណាច់ឆ្នាំ និងធ្វើរបាយការណ៍ផ្ញើទៅរាជធានី ខេត្ត តាមកាលកំណត់

-ធ្វើពិធីប្រកាសទទួលស្គាល់សមាសភាព គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានដោយ សហការជាមួយគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាថ្នាក់រាជធានី ខេត្ត

-ចាត់ចែងការបោះឆ្នោត ជ្រើសរើសប្រធានក្រុមបច្ចេកទេសគ្រប់មុខវិជ្ជាប្រចាំកម្រង និងជ្រើសរើស ប្រធានគណៈកម្មការកម្រង។

ដើម្បីសម្រេចភារកិច្ចខាងលើនេះ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំ ៣ ដង ក្នុងមួយឆ្នាំ គឺនៅមុនបវេសនកាល ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំ សិក្សា។ ក្នុងករណីចាំបាច់ អាចមានការប្រជុំវិសាមញ្ញទៅតាមស្ថានភាពជាក់ស្តែង ។

**គ.ក្រុមការងារ**

ក្នុងករណីដែលមានបញ្ហាពិសេសកើតឡើង ដូចជា ការចុះអធិការកិច្ចវាយតម្លៃ ការសាងសង់ ការប្រកួតកីឡា សិល្បៈ ការធ្វើបុណ្យ ។ល។ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារ ដើម្បីដោះស្រាយបញ្ហាទាំងនោះ ។ ក្រុមការងារនេះ មានសមាសភាពចម្រុះទៅតាម ទំហំការងារជាក់ស្តែង។

**អង្គការលេខគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន**
**ថ្នាក់ក្រុង ស្រុក ខណ្ឌ**




**៦. តួនាទី និងភារកិច្ចការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ** / DTMT

ដើម្បីអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមគ្រូតពិនិត្យតាមដានវាយតម្លៃដែលមានសមាសភាព និងការទទួលខុសត្រូវដូចខាងក្រោម៖

DTMT **ទី១ ៖** ទទួលបន្ទុកផ្នែករដ្ឋបាល ការគ្រប់គ្រង និងការដឹកនាំទូទៅរបស់សាលារៀនដែលមាន សមាសភាព ៦នាក់ ៖

| លរ | សមាសភាព DTMT ទី១ | តួនាទី |
|---|---|---|
| ១ | ប្រធានការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌ | ប្រធានទទួលបន្ទុករួម |
| ២ | អនុប្រធានការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌ | អនុប្រធានទទួលបន្ទុកបឋមសិក្សា |
| ៣ | អនុប្រធានការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌ | អនុប្រធានទទួលបន្ទុកមធ្យមសិក្សា |
| ៤ | មន្ត្រីការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌ ១នាក់ | ទទួលបន្ទុកបឋម/មត្តេយ្យ |
| ៥ | មន្ត្រីការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌ១នាក់ | ទទួលបន្ទុកមធ្យមសិក្សា |
| ៦ | មន្ត្រីការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌ១នាក់ | ទទួលបន្ទុកអប់រំក្រៅប្រព័ន្ធ |

**DTMTទី២ ៖** ជាមន្ត្រីអប់រំស្រុក/ប្រធានក្រុមបច្ចេកទេស ដែលដឹកនាំដោយអនុប្រធានទទួលបន្ទុកបឋមសិក្សាក្នុងការចុះពិនិត្យតាមដានសាលារៀន ។ ក្រុមនេះមានសមាសភាព ២-៣នាក់ ទទួលបន្ទុកការបង្រៀន និងរៀននៅបឋមសិក្សា មត្តេយ្យសិក្សា និងអប់រំក្រៅប្រព័ន្ធ ។ ប្រសិនបើចាំបាច់ ក្រុមនេះអាចសហការជាមួយក្រុមកម្ចីដើម្បីបំពេញការងារទៅតាមផែនការ។

**DTMTទី៣ ៖** ជាមន្ត្រីអប់រំស្រុក/ប្រធានក្រុមបច្ចេកទេស ដែលដឹកនាំដោយអនុប្រធានទទួលបន្ទុកមធ្យមសិក្សាក្នុងការចុះពិនិត្យតាមដានសាលារៀន។ ក្រុមនេះទទួលបន្ទុកការបង្រៀននិងរៀននៅមធ្យមសិក្សា ដែលមានសមាសភាព ២នាក់ ក្នុងស្រុកនីមួយៗ ដែលម្នាក់ទទួលខុសត្រូវមុខវិជ្ជាវិទ្យាសាស្ត្រ និងម្នាក់ទៀតទទួលខុសត្រូវមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។ ប្រសិនបើចាំបាច់ ក្រុមនេះក៏អាចសហការជាមួយក្រុមកម្ចីដើម្បីបំពេញការងារទៅតាមផែនការផងដែរ។

**ក្រុមកម្ចី ៖** ជាមុខសញ្ញានាយក នាយករងបច្ចេកទេស ឬប្រធានក្រុមបច្ចេកទេសឆ្នើម នៃវិទ្យាល័យ និងអនុវិទ្យាល័យ ដែលអាចអញ្ជើញឲ្យចូលរួមជាមួយDTMT ក្នុងការពិនិត្យតាមដាន បំប៉ន និងគាំទ្រដល់សាលារៀនទៅតាមតម្រូវការរបស់ស្រុកនីមួយៗ ។ សមាជិកក្រុមនេះអាចក្លាយទៅជាសមាជិក DTMT ពេញលេញនៅពេលមានសមាជិកណាម្នាក់ចាកចេញពី DTMT។

**ក្រុមគ្រូចល័ត៖** ជាគ្រូឯកទេសតាមមុខវិជ្ជានៅតាមសាលាចំណុះឱ្យក្រុង/ស្រុក/ខណ្ឌ ហើយត្រូវបានចាត់តាំងឱ្យទៅបង្រៀននៅសាលាផ្សេងក្រៅពីសាលារបស់ខ្លួន ទៅតាមគោលការណ៍ប្រាក់ម៉ោងបន្ថែម។ ការិយាល័យអប់រំស្រុកអាចបង្កើតក្រុមគ្រូចល័ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការខ្វះគ្រូឯកទេសនៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ ក្នុងតំបន់ដាច់ស្រយាល។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ គួរធ្វើការជាមួយនាយកសាលា ដើម្បីកំណត់មុខវិជ្ជាឯកទេសដែលខ្វះគ្រូនៅតាមវិទ្យាល័យ និង អនុវិទ្យាល័យ រួចធ្វើផែនការជាមួយក្រុមគ្រូចល័តដើម្បីឆ្លើយតបទៅនឹងតម្រូវការសាលាទាំងនោះ។

## ៩.១. តួនាទីចម្បងរបស់ DTMT

ក.កសាងផែនការរួមក្នុងការចុះពិនិត្យតាមដានសាលា ដោយបញ្ចូលរាល់សកម្មភាពដែលអនុវត្តនៅតាមសាលារៀន ដូចជា PB ដៃគូអភិវឌ្ឍន៍ អាហារូបករណ៍ សាលាកុមារមេត្រី និងសកម្មភាពផ្សេងទៀត ដែលគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល ។ល។

ខ.ចុះពិនិត្យតាមដានសាលារៀនដោយប្រើបញ្ជីតាមដាន និងវាយតម្លៃសាលាកុមារមេត្រី និង ឧបករណ៍ពាក់ព័ន្ធផ្សេងទៀត ដើម្បីកំណត់ចំណុចល្អដែលត្រូវសរសើរដល់សាលារៀន និងចំណុចដែលសាលារៀនត្រូវពង្រឹងបន្ថែម

គ. សហការជាមួយក្រុមអធិការថ្នាក់ខេត្តក្នុងការធ្វើអធិការកិច្ចសាលារៀន រួចពិនិត្យតាមដានសាលារៀនក្នុងការអនុវត្តអនុសាសន៍របស់ក្រុមអធិការកិច្ច

ឃ. បំប៉នសមាជិក DTMTថ្មី តាមរយៈការបង្រៀននៅនឹងកន្លែង ដោយផ្តល់ឱកាសឲ្យចូលរួមក្នុងការចុះពិនិត្យតាមដាន រួចធ្វើការឆ្លុះបញ្ចាំងនូវដំណើរការ និងខ្លឹមសារទាំងនោះ

ង. រៀបចំការបំប៉នដល់គ្រូបង្រៀន និងនាយកសាលា ចំពោះប្រធានបទទាំងឡាយណា ដែលជាតម្រូវការរបស់សាលារៀន នាយក និងគ្រូបង្រៀន (ផ្អែកលើរបាយការណ៍ចុះពិនិត្យតាមដាន និងអធិការកិច្ចសាលារៀនខាងលើ និងរបាយការណ៍ផ្សេងទៀត)

ច. គ្រោងថវិកា(PB និងម្ចាស់ជំនួយ) សម្រាប់ការចុះពិនិត្យតាមដាន និងបំប៉នដល់គ្រូ និងនាយកសាលា ដោយផ្អែកលើរបាយការណ៍ពិនិត្យតាមដាន និងអធិការកិច្ច (ប្រសិនបើចាំបាច់)

## ៩.២.ដំណើរការអនុវត្ត ៖

### ៩.២.១. ការចុះពិនិត្យតាមដានសាលារៀន

ក្នុងការចុះគាំទ្រដល់សាលារៀន DTMT គួររៀបចំផែនការឲ្យបានច្បាស់លាស់ក្នុងការចុះគាំទ្រដល់សាលារៀននីមួយៗ ដោយយកចិត្តទុកដាក់ទៅលើ ៖

- ចុះធ្វើការជាក្រុម២-៣នាក់ (ចម្រុះសមាសភាព ៖ ក្រុម១ និង២ សម្រាប់បឋមសិក្សា ឬក្រុម១ និង៣ សម្រាប់មធ្យមសិក្សា)
- ចំណាយពេលពេញមួយថ្ងៃក្នុងការពិនិត្យតាមដានឲ្យបានគ្រប់ជ្រុងជ្រោយ ដោយចែកតួនាទីគ្នាក្នុងការប្រមូលព័ត៌មានពីនាយកសាលា បុគ្គលិកសិក្សា សិស្ស សហគមន៍ និងសង្កេតថ្នាក់រៀន
- ផ្តល់អនុសាសន៍ដែលបានមកពីការពិនិត្យតាមដានប្រកបដោយការវិភាគគ្រប់ជ្រុងជ្រោយ ដោយស្នើឲ្យដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនឆ្នាំបន្ទាប់
- ធ្វើផែនការចុះពិនិត្យតាមដានសាលារៀននីមួយៗម្តង[1] ក្នុងមួយឆ្នាំដោយមានអនុសាសន៍ជាក់លាក់ ហើយទុកពេលឲ្យបានគ្រប់គ្រាន់សម្រាប់សាលារៀនអនុវត្តអនុសាសន៍ទាំងនោះ
- ក្នុងករណីចាំបាច់ DTMTអាចចុះទៅពិនិត្យសាលាមួយលើសពីមួយដងក្នុងមួយឆ្នាំ ។

### ក. ការជ្រើសរើសសាលា ៖

- កំណត់សាលារៀន (៣០%-៥០%) ជាអាទិភាពក្នុងស្រុក ផ្អែកលើចំណាត់ថ្នាក់សាលាកុមារមេត្រី និងសូចនាករលទ្ធផលសិក្សារបស់សិស្សដែលសម្រេចបានកម្រិតទាប ដើម្បីរៀបចំផែនការចុះជួយគាំទ្រក្នុងឆ្នាំសិក្សានីមួយៗ
- ស្វែងយល់ពីសាលារៀនមួយចំនួនក្នុងស្រុក ផ្អែកលើចំណាត់ថ្នាក់សាលាកុមារមេត្រី និងសូចនាករលទ្ធផលសិក្សារបស់សិស្សដែលសម្រេចបានកម្រិតខ្ពស់ ដើម្បីដកស្រង់បទពិសោធ និងមេរៀនល្អៗចែករំលែកជាមួយសាលារៀនដទៃទៀត
- ឆ្លើយតបទៅនឹងសាលារៀនកម្រិតមធ្យម ប្រសិនបើសាលាណាតម្រូវឲ្យមានការពិនិត្យតាមដានពី DTMT និងក្នុងករណីមានលទ្ធភាពគ្រប់គ្រាន់ ។

[1] បន្ថែមពីការចុះពិនិត្យតាមដាន DTMT ត្រូវចុះតាមសាលាដើម្បីចូលរួមប្រជុំក្រុមបច្ចេកទេស ឬការបំប៉នសមត្ថភាពដល់អ្នកពាក់ព័ន្ធ។

### ខ. មុនពេលចុះពិនិត្យតាមដាន ៖

- ពិនិត្យមើលទិន្នន័យ (EMIS) ឯកសារពាក់ព័ន្ធ និងរបាយការណ៍ផ្សេងទៀតរបស់សាលាដែលនឹងត្រូវចុះពិនិត្យតាមដាន
- វិភាគលើទិន្នន័យនិងរបាយការណ៍ទាំងនោះ ដើម្បីកំណត់ពីចំណុចដែលត្រូវយកចិត្តទុកដាក់ក្នុងការចុះពិនិត្យតាមដាន
- រៀបចំឧបករណ៍ពិនិត្យតាមដាន (កម្មវិធីទាំងអស់ដែលសាលារៀនមាន រួមទាំង PB ដៃគូអភិវឌ្ឍន៍ អាហារូបករណ៍ សាលាកុមារមេត្រី និងសកម្មភាពផ្សេងទៀតដែលគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល រួចបែងចែកការទទួលខុសត្រូវក្នុងក្រុម)
- ផ្តល់ព័ត៌មានដល់សាលាក្នុងការចុះពិនិត្យតាមដាន ដោយបញ្ជាក់ពីការជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដូចជាគណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតាសិស្ស និងអាជ្ញាធរជាដើម ។

### គ. ពេលដំណើរការពិនិត្យតាមដាន ៖

- ពិនិត្យមើលលើការសម្រេចបានរបស់សាលារៀន ដោយប្រើបញ្ជីពិនិត្យតាមដាន(សាលារៀន និងថ្នាក់រៀន) និងឧបករណ៍ពាក់ព័ន្ធផ្សេងទៀត
- សង្កេតមើលសកម្មភាព និងបរិស្ថានសាលារៀនជាទូទៅ រួមទាំងអនាម័យកន្លែងលក់ចំណីអាហារ បង្គន់អនាម័យ ទីធ្លាសម្រាប់លេងកីឡា និងកម្មវិធីពាក់ព័ន្ធផ្សេងទៀត
- សង្កេតថ្នាក់រៀន ដោយជ្រើសរើសតាមភាពចៃដន្យក្នុងចំណោមមុខវិជ្ជាវិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គម បន្ទាប់មកផ្តល់ព័ត៌មានត្រឡប់
- ពិនិត្យមើលកិច្ចការរបស់សិស្ស និងរដ្ឋបាលថ្នាក់រៀន
- ពិភាក្សាជាមួយនាយក បុគ្គលិកសិក្សា គ្រូបង្រៀន សិស្ស សហគមន៍ គណៈកម្មការទ្រង់ទ្រង់សាលារៀន និងអាជ្ញាធរមូលដ្ឋាន
- ផ្តល់ព័ត៌មានត្រឡប់ផ្ទាល់មាត់ដល់ភាគីពាក់ព័ន្ធពីអ្វីដែលបានរកឃើញ ។

### ឃ. ការផ្តល់ព័ត៌មានត្រឡប់ដល់គ្រូបន្ទាប់ពីការសង្កេតថ្នាក់ ៖

- អរគុណ រួចបង្កើតភាពស្និទ្ធស្នាលជាមួយគ្រូ
- ទុកលទ្ធភាពឲ្យគ្រូរៀបរាប់ពីអ្វីដែលគាត់គិតថាធ្វើបានល្អចំនួន៣ចំណុច ដោយសួរសំណួរបញ្ជាក់បន្ថែម និងលើកទឹកចិត្តឲ្យអនុវត្តបន្ត
- សួរគ្រូចំពោះចំណុចដែលគាត់គិតថា គួរកែលម្អពេលក្រោយ ១-២ចំណុច ដោយបញ្ជាក់ពីយុទ្ធសាស្ត្រក្នុងការកែលម្អ
- សរសើរចំពោះអ្វីដែលគ្រូធ្វើបានល្អ រួចពិភាក្សាលើចំណុចដែលគ្រូគិតថាចាំបាច់គួរកែលម្អនៅពេលក្រោយ ដោយផ្តើមចេញពីចំណុចដែលគាត់បានលើកឡើង ៖
    - ផ្អែកលើចំណុចកែលម្អរបស់គ្រូបង្រៀន ដោយនិយាយថា ប្រសិនបើខ្ញុំបង្រៀនត្រង់ចំណុចនេះ ខ្ញុំនឹងធ្វើ...
    - DTMT អាចលើកយកចំណុចផ្សេងទៀត ដែលខ្លួនគិតថាចាំបាច់ត្រូវកែលម្អ ដោយសួរគ្រូថា តើត្រង់ចំណុចនេះអ្នកគួរបង្រៀនដូចម្តេចនៅពេលក្រោយ មុននឹងផ្តល់ជាគំនិតផ្ទាល់ខ្លួន

- ចុងបញ្ចប់ DTMT និងគ្រូកំណត់យកចំណុចដែលត្រូវកែលម្អពេលក្រោយ ១-២ ចំណុចប៉ុណ្ណោះ រួចពិភាក្សាពីយុទ្ធសាស្រ្តត្រូវកែលម្អ
- ការពិភាក្សាមិនត្រូវលើសពី ១៥ នាទីឡើយ ។

**ខ. ការផ្តល់ព័ត៌មានត្រឡប់ដល់អ្នកពាក់ព័ន្ធក្នុងសាលារៀនជារួម ៖**

- ក្រុម DTMT ជួបប្រជុំពិភាក្សាពីអ្វីដែលបានរកឃើញ ដើម្បីទាញសន្និដ្ឋានលើការប្រតិបត្តិរបស់សាលារៀនទាំងមូល (ចំណុចល្អ ៣-៤ និងអនុសាសន៍ ២-៣) មុននឹងផ្តល់ព័ត៌មានត្រឡប់ផ្ទាល់មាត់ដល់អ្នកពាក់ព័ន្ធ
- ជួបជាមួយនាយកសាលាដោយឡែកដើម្បីស្វាបស្ទង់ទស្សនៈរបស់គាត់ពាក់ព័ន្ធទៅនឹងអ្វីដែលបានរកឃើញ។ បន្ទាប់មកជួបតំណាងភាគីពាក់ព័ន្ធ រួមទាំងនាយកសាលា ដើម្បីធ្វើរបាយការណ៍ផ្ទាល់មាត់ដោយផ្តោតលើ ៖
    - លទ្ធផលល្អដែលសាលាសម្រេចបាន ដោយបញ្ជាក់ពីកម្រិតសាលាកុមារមេត្រីដែលសាលាទទួលបាន (មូលដ្ឋាន មធ្យម និងអភិវឌ្ឍន៍)
    - អនុសាសន៍ដែលត្រូវបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន
    - ស្តាប់ប្រតិកម្មត្រឡប់ពីភាគីពាក់ព័ន្ធ រួចពិភាក្សាលើចំណុចទាំងនោះ ដោយផ្អែកលើអំណះអំណាង និងភស្តុតាងបន្ថែម
- ជម្រាបលាម្ចាស់សាលា ព្រមទាំងសន្យាសរសេររបាយការណ៍ជាលាយលក្ខអក្សរជូនមកសាលា និងមន្ទីរ អយក ដើម្បីរក្សាទុកកាលប្បវត្តិ ។

**ច.ក្រោយពេលពិនិត្យតាមដាន (ត្រឡប់មកការិយាល័យ អយក ក្រុង/ស្រុក/ខណ្ឌវិញ) ៖**

- ពិភាក្សាជាក្រុម និងសរសេររបាយការណ៍ផ្លូវការ (ជូនសាលារៀន និងមន្ទីរអប់រំ យុវជននិងកីឡា)
- ប្រសិនបើសាលាមិនឯកភាពត្រង់ចំណុចណាមួយនៃរបាយការណ៍ ត្រូវពិភាក្សា និងផ្តល់យោបល់សមហេតុផលឲ្យបានគ្រប់គ្រាន់ និងមានការទទួលយល់ព្រមពីសាលា
- កំណត់អាទិភាព (អនុសាសន៍) ដែលត្រូវជួយចំពោះមុខ តាមរយៈការនាំធ្វើផ្ទាល់ ដូចជាប្រជុំក្រុមបច្ចេកទេស ឬរៀបចំការបំប៉ននៅនឹងកន្លែងប្រសិនបើចាំបាច់
- កំណត់អាទិភាព (អនុសាសន៍) ដែលត្រូវជួយគាំទ្របន្ត ឬដាក់បញ្ចូលផែនការអភិវឌ្ឍន៍សាលារៀនក្នុងឆ្នាំបន្ទាប់ និងជាចំណុចសម្រាប់ពិនិត្យតាមដាននៅឆ្នាំក្រោយ ។

### ៩.២.២. ការគាំទ្របន្ត បន្ទាប់ពីការពិនិត្យតាមដាននិងវាយតម្លៃ

ផ្អែកលើរបាយការណ៍ពិនិត្យតាមដាន និងអធិការកិច្ច DTMTត្រូវធ្វើការវិភាគ រួចកំណត់ឱ្យបានច្បាស់នូវតម្រូវការក្នុងការកសាងសមត្ថភាពដល់សាលារៀន ។ ក្រុង/ស្រុក/ខណ្ឌនីមួយៗអាចគ្រោងថវិកាដើម្បីគាំទ្រសកម្មភាពដូចខាងក្រោម ដោយប្រើកញ្ចប់ថវិកា PB និងម្ចាស់ជំនួយ ។ សកម្មភាពគាំទ្រ បន្តរបស់ DTMT ដល់សាលារៀនមានដូចខាងក្រោម៖

- **ការបំប៉នបន្ថែម ៖**
    - អ្វីដែលត្រូវបំប៉ន (ការដឹកនាំគ្រប់គ្រង រដ្ឋបាល ការកសាងផែនការ កម្មវិធីសិក្សា ការបង្រៀន និងរៀន។ល។)
    - មុខសញ្ញា (គ្រូបង្រៀន នាយក គណៈកម្មការទ្រទ្រង់សាលារៀន)

- ពេលវេលាបំប៉ន (មិនឲ្យប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស)
- ទីកន្លែងដែលត្រូវបំប៉ន ៖
  - នៅតាមសាលារៀន ឬនៅកម្រងសាលា
  - ប្រមូលផ្តុំនៅក្រុង/ស្រុក/ខណ្ឌ
- គ្រូឧទ្ទេស (DTMT អាចសហការជាមួយគ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការរាជធានី/ខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងអធិការថ្នាក់ខេត្ត ដើម្បីរៀបចំការបំប៉ននេះ)
- ខ្លឹមសារ និងសម្ភារៈដែលត្រូវបំប៉ន (ដកស្រង់ចេញពីឯកសារសាលាកុមារមេត្រី បំណិនជីវិត ការបង្រៀន និងរៀនវិទ្យាសាស្ត្រ ពិសោធន៍វិទ្យាសាស្ត្រ និងប្រភពផ្សេងៗទៀត)

- **សម្របសម្រួលការប្រជុំបច្ចេកទេស ៖**
  - DTMTអាចស្នើរបៀបវារៈប្រជុំ ដោយបញ្ចូលប្រធានបទដែលខ្លួនគិតថាចាំបាច់ ដោយផ្អែកទៅលើលទ្ធផលនៃការពិនិត្យតាមដាន
  - រៀបចំកិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស
  - រៀបចំថ្នាក់និទស្សន៍ ដែលបង្ហាញបច្ចេកទេសល្អៗ រួចដឹកនាំពិភាក្សាពីជំហានគរុកោសល្យ
  - រៀបចំកម្មវិធីគ្រូជួយគ្រូ (ដៃគូ) ក្នុងការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារឧបទេស ការសង្កេតការបង្រៀន និងការជួយកែលម្អ

- **រៀបចំទស្សនកិច្ចផ្លាស់ប្តូរបទពិសោធ ៖**

ក្នុងតួនាទីរបស់ខ្លួន DTMT អាចកំណត់បានសាលាដែលអនុវត្តល្អ ហើយទទួលបានសមិទ្ធផល និងលទ្ធផលសិក្សាប្រសើរក្នុងស្រុក ដើម្បីជាកន្លែងដែលអាចឲ្យសាលាផ្សេងទៀត មកដកស្រង់បទពិសោធន៍។ ស្រុកអាចរៀបចំជាកម្មវិធីសាលាជួយសាលា ដោយឲ្យសាលាដែលសម្រេចបានលទ្ធផលសិក្សាខ្ពស់ ជួយសាលាដែលជួបការលំបាកក្នុងការអភិវឌ្ឍសាលារៀនលើផ្នែកដូចជាការដឹកនាំគ្រប់គ្រង ការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ជាដើម ។

## ១០.ការបង្កើតក្រុមប្រឹក្សា និងគណៈកម្មការអភិវឌ្ឍន៍កម្រងថ្នាក់រាជធានី ខេត្ត

### ១០.១.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រង ថ្នាក់រាជធានី ខេត្ត

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត ជាក្រុមដែលគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត ប្រជុំពិគ្រោះការងារ ។ ក្រុមនេះ គ្មានប្រធាន អនុប្រធានទេមានតែលេខាធិការអចិន្ត្រៃយ៍ម្នាក់ប៉ុណ្ណោះ។ នៅពេលប្រជុំការងារម្តងៗ ក្រុមនេះចាត់តាំងម្នាក់ធ្វើជាប្រធាន ដើម្បីដឹកនាំការប្រជុំ និងលេខាម្នាក់សម្រាប់កត់ត្រា។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀន ថ្នាក់រាជធានី ខេត្ត ត្រូវបានទទួលស្គាល់ដោយគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា។

**ក.សមាសភាព**

-ព្រះមេគណរាជធានី ខេត្ត

-អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

-ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងថ្នាក់រាជធានី ខេត្ត ជាលេខាធិការអចិន្ត្រៃយ៍

-ប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ ទាំងអស់ក្នុងរាជធានី ខេត្ត

-ប្រធានសហគមន៍ប្រចាំកម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌទាំងអស់ក្នុងរាជធានីខេត្ត។

**ខ.ភារកិច្ច**

ក្រុមប្រឹក្សានេះប្រជុំ ៣ ដង ក្នុងមួយឆ្នាំគឺ មុនបវេសនកាល ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំសិក្សា តាមការអញ្ជើញរបស់លេខាធិការ ដើម្បីបូកសរុប ត្រួតពិនិត្យ វាយតម្លៃលទ្ធផលសិក្សារបស់សិស្សានុសិស្ស ការអភិវឌ្ឍកម្រងសាលារៀនទូទាំងរាជធានី ខេត្ត និងលើកផែនការសកម្មភាពដើម្បីឱ្យគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាថ្នាក់រាជធានី ខេត្ត អនុវត្ត។

**១០.២.គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត**

លេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត ជាអ្នកព្រាងសមាសភាពក្រុមគណៈកម្មការ ដើម្បីស្នើសុំការសម្រេចទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈអភិបាលនៃគណអៈភិបាលរាជធានី ខេត្ត។

**ក.សមាសភាព**

| លរ | សមាសភាព | តួនាទី |
|---|---|---|
| ១ | អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធានកិត្តិយស |
| ២ | ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត | ប្រធាន |
| ៣ | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (បើមាន) | អនុប្រធាន |
| ៥ | ប្រធានសហគមន៍រាជធានី ខេត្ត (បើមាន) | អនុប្រធាន |
| ៦ | ប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅ | លេខាធិការ |
| ៧ | ប្រធានការិយាល័យបឋមសិក្សា | សមាជិក |
| ៨ | ប្រធានការិយាល័យអប់រំកុមារតូច | សមាជិក |
| ៩ | ប្រធានការិយាល័យអធិការកិច្ច | សមាជិក |
| ១០ | ប្រធានការិយាល័យអប់រំក្រៅប្រព័ន្ធ | សមាជិក |
| ១១ | ប្រធានការិយាល័យផែនការ និងគណនេយ្យ សម្ភារៈ | ហេរញ្ញិក |
| ១២ | ប្រធានការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល | សមាជិក |
| ១៣ | នាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្ត | សមាជិក |
| ១៤ | ប្រធានការិយាល័យយុវជន | សមាជិក |
| ១៥ | ប្រធានការិយាល័យអប់រំកាយ និងកីឡា | សមាជិក |
| ១៦ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌទាំងអស់ | សមាជិក |
| ១៧ | ប្រធានសហគមន៍ក្រុង ស្រុក ខណ្ឌទាំងអស់ | សមាជិក |

**ខ.តួនាទី និងភារកិច្ច**

**តួនាទី**

-ជាសេនាធិការជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ

-ដឹកនាំ និងគ្រប់គ្រងកម្រងសាលារៀនទូទាំង រាជធានី ខេត្ត ។

**ភារកិច្ច**

-សម្រេចរៀបចំគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនក្នុងក្រុង ស្រុក ខណ្ឌ

-ពិនិត្យ និងសម្រេចផែនការកម្រងសាលារៀនរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់មូលដ្ឋាន

-ផ្សព្វផ្សាយលិខិតបទដ្ឋាន ដែលក្រសួងអប់រំ យុវជន និងកីឡាដាក់ឱ្យអនុវត្ត

-រៀបចំផែនការអភិវឌ្ឍន៍កម្រងសាលារៀន និងស្នើឡើងក្រសួងពិនិត្យ និងសម្រេច

-កសាងកម្មវិធីអធិការកិច្ច តាមដានការងារកម្រងសាលារៀន

-ពិនិត្យតាមដាន ការប្រើប្រាស់សម្ភារៈ ថវិកាកម្រងសាលារៀន

-ជំរុញសកម្មភាពប្រឡងប្រណាំងគ្រប់ផ្នែកអប់រំ រវាងកម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុង ស្រុក ខណ្ឌ

-លើកទឹកចិត្ត ជំរុញសកម្មភាពអភិវឌ្ឍន៍កម្រងសាលារៀន

-ទំនាក់ទំនង និងសហការជាមួយស្ថាប័នជាតិ អន្តរជាតិ ដើម្បីអភិវឌ្ឍកម្រងសាលារៀនក្នុងរាជធានី ខេត្ត

-ប្រមូលព័ត៌មាន ចងក្រងស្ថិតិ ទិន្នន័យអប់រំពីថ្នាក់ក្រុង ស្រុក ខណ្ឌ

-ដោះស្រាយបញ្ហា ដែលកម្រងសាលារៀនបានជួបប្រទះ

-បូកសរុបវាយតម្លៃ សកម្មភាពកម្រងសាលារៀន និងធ្វើរបាយការណ៍ជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ តាមកាលកំណត់

-ធ្វើពិធីប្រកាសទទួលស្គាល់សមាសភាព គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ ។

ដើម្បីសម្រេចភារកិច្ចខាងលើនេះ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត ត្រូវរួមប្រជុំ ៣ដង ក្នុងមួយឆ្នាំគឺនៅមុនបវេសនកាល ដំណាច់ឆមាសទី១ និងដំណាច់ឆ្នាំសិក្សា។ ក្នុងករណីចាំបាច់ អាចមានការប្រជុំវិសាមញ្ញទៅតាមស្ថានភាពជាក់ស្តែង។

**គ.ក្រុមការងារ**

ក្នុងករណីដែលមានបញ្ហាពិសេសកើតឡើងដូចជា ការចុះអធិការកិច្ច ការសាងសង់ ការប្រកួតកីឡា សិល្បៈ ការធ្វើបុណ្យ...គណៈកម្មការអភិវឌ្ឍន៍កម្រងថ្នាក់រាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារ ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ នៅពេលការងារនោះ ដោះស្រាយរួចរាល់ហើយ ក្រុមនេះនឹងរំសាយទៅវិញជាស្វ័យប្រវត្តិ ។ ក្រុមការងារនេះមានសមាសភាពចម្រុះទៅតាមទំហំការងារជាក់ស្តែង។

**អង្គការលេខគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់រាជធានី ខេត្ត**




**១១.ការបង្កើតគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ**

សមាសភាពគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ ត្រូវទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីចៀសវាងការជាន់ភារកិច្ច គណៈកម្មការនេះអាចប្រើប្រាស់សមាសភាព គណៈកម្មការដឹកនាំ និងសម្របសម្រួលអភិវឌ្ឍន៍កម្មវិធីសាលាកុមារមេត្រីថ្នាក់ជាតិបាន។

### ១១.១.សមាសភាពគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនថ្នាក់ជាតិ

-អនុគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនផ្នែកបឋមសិក្សា

-អនុគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនផ្នែកអប់រំកុមារតូច

-អនុគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនផ្នែកមធ្យមសិក្សា

-អនុគណៈកម្មការអធិការកិច្ច ប្រឡងប្រណាំង និងវាយតម្លៃ។

### ១១.២.ក្រុមការងារផ្នែកបឋមសិក្សា

#### ក.ក្រុមអ្នកនិពន្ធ និងកែលម្អឯកសារ

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-កសាង និងកែលម្អឡើងវិញនូវបញ្ញត្តិផ្សេងៗ ដើម្បីអភិវឌ្ឍកម្រងសាលារៀន

-សិក្សាស្រាវជ្រាវបទពិសោធល្អៗ និងចងក្រងឯកសារសម្រាប់អនុវត្ត

-សម្រេចឱ្យបាននូវផែនការក្រុម ។

#### ខ.ក្រុមបច្ចេកទេស អធិការកិច្ច ប្រឡងប្រណាំង និងវាយតម្លៃ

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១ រូប មានភារកិច្ចៈ

-កសាងឯកសារបច្ចេកទេសនានា និងឧបករណ៍អធិការកិច្ច

-រៀបចំ កសាងគោលការណ៍ និងលិខិតបទដ្ឋាននានាសម្រាប់អនុវត្តការងារ

-កសាងលក្ខណៈវិនិច្ឆ័យ សម្រាប់វង្វាយតម្លៃ និងប្រឡងប្រណាំង

-កសាងលក្ខណៈវិនិច្ឆ័យតែសវាយតម្លៃលទ្ធផលបំពេញការងារ

-កសាងសៀវភៅ ផលិត និង ប្រើប្រាស់សម្ភារឧបទេស

-សហការជាមួយនាយកដ្ឋានពាក់ពន្ធ័ (អភិវឌ្ឍកម្មវិធីសិក្សា បណ្តុះបណ្តាល...) សម្រាប់ជាមូលដ្ឋានឯកភាពក្នុងការធ្វើសកម្មភាព និងអនុវត្ត

-សម្រេចឱ្យបាននូវផែនការក្រុម ។

#### គ.ក្រុមរដ្ឋបាល ផែនការ ស្ថិតិ និងសហប្រតិបត្តិការ

ក្រុមនេះដឹកនាំដោយ ប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-សហការស្រាវជ្រាវជាមួយ EMIS ជាមូលដ្ឋានឯកភាពក្នុងការកសាងស្ថិតិ និងសូចនាករនានា

-ចងក្រងស្ថិតិគ្រប់លំដាប់ជាទិន្នន័យព័ត៌មាន សម្រាប់វាយតម្លៃការអភិវឌ្ឍគុណភាពអប់រំ

-សិក្សាផែនទីសិក្សាកម្រងទូទាំងប្រទេសដើម្បីជាមូលដ្ឋានវិភាគ និងលើកផែនការអនុវត្ត

-កសាងឯកសាររូបភាពជា Album កាសែតវីដេអូ សកម្មភាពទាំង៤ របស់កម្រងសាលារៀន (ការងារគ្រប់គ្រងរដ្ឋបាល ការបង្រៀន និងរៀន មជ្ឈមណ្ឌលធនធាន បណ្ណាល័យ និងការងារសហគមន៍)។

-ផ្សព្វផ្សាយព័ត៌មាន និងលទ្ធផលនានាទាក់ទងនឹងកម្រងសាលារៀនតាមរយៈព្រឹត្តិប័ត្រកម្រងសាលារៀន និងសមាគមបុគ្គលិកសិក្សា សារព័ត៌មាន ទូរទស្សន៍ ឬវិទ្យុ ។

#### ឃ.ក្រុមអប់រំពិសេស និងសកម្មភាពប្រតិបត្តិ

ក្រុមនេះដឹកនាំដោយប្រធាន ១រូប និងអនុប្រធាន ១រូប មានភារកិច្ចៈ

-ដឹកនាំ និងសម្របសម្រួលការងារអប់រំកុមារពិការ កុមារជនជាតិភាគតិច កុមារក្រីក្រ និងកុមារី

-សហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍ការងារអប់រំពិសេស

-សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ និងដៃគូនានារៀបចំអភិវឌ្ឍការងារអប់រំបំណិនជីវិត (សិល្បៈ កីឡា និងជំនាញផ្សេងៗ)

-រៀបចំពង្រឹងដំណើរការ និងសកម្មភាពបណ្ណាល័យនៅតាមសាលារៀន ។

## ១១.៣.ក្រុមការងារផ្នែកមធ្យមសិក្សា

### ក.ក្រុមអ្នកនិពន្ធ និងកែលម្អឯកសារ

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១ រូប មានភារកិច្ចៈ

-កសាង និងកែលម្អឡើងវិញនូវបញ្ញត្តិផ្សេងៗ ដើម្បីអភិវឌ្ឍកម្រងសាលារៀន

-សិក្សាស្រាវជ្រាវបទពិសោធល្អៗ និងចងក្រងឯកសារសម្រាប់អនុវត្ត

-សម្រេចឱ្យបាននូវផែនការក្រុម ។

### ខ.ក្រុមបច្ចេកទេសមធ្យមសិក្សា និងអធិការកិច្ច

ក្រុមនេះ ដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-កសាងឯកសារបច្ចេកទេសនានា និងឧបករណ៍អធិការកិច្ច

-រៀបចំ កសាងគោលការណ៍ និងលិខិតបទដ្ឋាននានាសម្រាប់អនុវត្តការងារ

-កសាងលក្ខណៈវិនិច្ឆ័យ សម្រាប់វាយតម្លៃ និងប្រឡងប្រណាំង

-កសាងលក្ខណៈវិនិច្ឆ័យតែសវាយតម្លៃលទ្ធផលការបំពេញការងារ

-កសាងសៀវភៅ ផលិត និងប្រើប្រាស់សម្ភារឧបទេស

-សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ (អភិវឌ្ឍកម្មវិធីសិក្សា បណ្តុះបណ្តាល...) សម្រាប់ជាមូលដ្ឋានឯកភាពក្នុងការធ្វើសកម្មភាព និងអនុវត្ត

-សម្រេចឱ្យបាននូវផែនការក្រុម ។

### គ.ក្រុមរដ្ឋបាល និងផែនការ

ក្រុមនេះដឹកនាំដោយ ប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-សហការស្រាវជ្រាវជាមួយ EMIS ជាមូលដ្ឋានឯកភាពក្នុងការកសាងស្ថិតិ និងសូចនាករនានា

-ចងក្រងស្ថិតិគ្រប់លំដាប់ជាទិន្នន័យព័ត៌មាន សម្រាប់វាយតម្លៃការអភិវឌ្ឍគុណភាពអប់រំ

-សិក្សាផែនទីសិក្សាកម្រងទូទាំងប្រទេសដើម្បីជាមូលដ្ឋានវិភាគ និងលើកផែនការអនុវត្ត

-កសាងឯកសាររូបភាពជា Album កាសែតវីដេអូ សកម្មភាពទាំង៤ របស់កម្រងសាលារៀន (ការងារគ្រប់គ្រងរដ្ឋបាល ការបង្រៀន និងរៀន មជ្ឈមណ្ឌលធនធាន បណ្ណាល័យ និងការងារសហគមន៍)។

-ផ្សព្វផ្សាយព័ត៌មាន និងលទ្ធផលនានាទាក់ទងនឹងកម្រងសាលារៀនតាមរយៈព្រឹត្តិប័ត្រកម្រងសាលារៀន និងសមាគមបុគ្គលិកសិក្សា សារព័ត៌មាន ទូរទស្សន៍ ឬវិទ្យុជាតិ ។

### ឃ.ក្រុមអាហារូបករណ៍ និងប្រឡង

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-ដឹកនាំ និងសម្របសម្រួលការងារអប់រំកុមារពិការ កុមារជនជាតិភាគតិច កុមារក្រីក្រ និងកុមារី

-សហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍ការងារប្រឡង

-សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ និងដៃគូនានារៀបចំអភិវឌ្ឍការងារអប់រំបំណិនជីវិត (សិល្បៈ កីឡា និងជំនាញផ្សេងៗ)

-ចងក្រងខ្លឹមសារតែសវិញ្ញាសាតាមមុខវិជ្ជា សម្រាប់តែសស្តង់ដា ការប្រឡងឆមាស និងសញ្ញាបត្រ

-រៀបចំពង្រឹងដំណើរការ និងសកម្មភាពបណ្ណាល័យនៅតាមសាលារៀន ។

## ១១.៤.ក្រុមការងារផ្នែកអប់រំកុមារតូច

### ក.ក្រុមអ្នកនិពន្ធ និងកែលម្អឯកសារ

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-កសាង និងកែលម្អឡើងវិញនូវបញ្ញត្តិផ្សេងៗដើម្បីអភិវឌ្ឍកម្រងសាលារៀន

-សិក្សាស្រាវជ្រាវបទពិសោធល្អៗ និងចងក្រងឯកសារសម្រាប់អនុវត្ត

-សម្រេចឱ្យបាននូវផែនការក្រុម

### ខ.ក្រុមមត្តេយ្យសិក្សា និងអធិការកិច្ច

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-កសាងឯកសារបច្ចេកទេស និងឧបករណ៍អធិការកិច្ច

-រៀបចំ និងកសាងគោលការណ៍ និងលិខិតបទដ្ឋាននានាសម្រាប់អនុវត្តការងារ

-កសាងលក្ខណៈវិនិច្ឆ័យ សម្រាប់វាយតម្លៃ និងប្រឡងប្រណាំង

-កសាងលក្ខណៈវិនិច្ឆ័យតែសវាយតម្លៃលទ្ធផលបំពេញការងារ

-កសាងសៀវភៅ ផលិត និងប្រើប្រាស់សម្ភារឧបទេស

-សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ (អភិវឌ្ឍកម្មវិធីសិក្សា បណ្តុះបណ្តាល) សម្រាប់ជាមូលដ្ឋានឯកភាពក្នុងការធ្វើសកម្មភាព និងអនុវត្ត

-រៀបចំពង្រឹងដំណើរការ និងសកម្មភាពបណ្ណាល័យនៅតាមសាលាមត្តេយ្យសិក្សា

-សម្រេចឱ្យបាននូវផែនការក្រុម ។

### គ.ក្រុមរដ្ឋបាល និងផែនការ

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-សហការស្រាវជ្រាវជាមួយ EMIS ជាមូលដ្ឋានឯកភាពក្នុងការកសាងស្ថិតិ និងសូចនាករនានា

-ចងក្រងស្ថិតិគ្រប់លំដាប់ជាទិន្នន័យព័ត៌មានសម្រាប់វាយតម្លៃការអភិវឌ្ឍគុណភាពអប់រំ

-សិក្សាផែនទីសិក្សាកម្រងទូទាំងប្រទេសដើម្បីជាមូលដ្ឋានវិភាគ និងលើកផែនការអនុវត្ត

-កសាងឯកសាររូបភាពជា Album កាសែតវីដេអូ សកម្មភាពទាំង ៤ របស់កម្រងសាលារៀន (ការងារគ្រប់គ្រងរដ្ឋបាល ការបង្រៀននិងរៀន មជ្ឈមណ្ឌលធនធាន បណ្ណាល័យ និងការងារសហគមន៍)

-ផ្សព្វផ្សាយព័ត៌មាន និងលទ្ធផលនានាទាក់ទងនឹងកម្រងសាលារៀនតាមរយៈព្រឹត្តិប័ត្រកម្រងសាលារៀន និងសមាគមបុគ្គលិកសិក្សា សារព័ត៌មាន ទូរទស្សន៍ ឬវិទ្យុ ។

### ឃ.ក្រុមអប់រំកុមារតូច

ក្រុមនេះដឹកនាំដោយប្រធាន និងអនុប្រធាន ១រូប មានភារកិច្ចៈ

-ដឹកនាំ និងសម្របសម្រួល ការងារអប់រំកុមារតូច

-សហការជាមួយដៃគូអភិវឌ្ឍន៍រៀបចំគម្រោងអភិវឌ្ឍន៍ការងារអប់រំកុមារតូច

-សហការជាមួយដៃគូពាក់ព័ន្ធ និងដៃគូនានារៀបចំអភិវឌ្ឍរៀបចំការងារបំណិនជីវិតទូទៅ ។

## ១២.សេចក្ដីសន្និដ្ឋាន

ការអភិវឌ្ឍវិស័យអប់រំជាប្រការចាំបាច់ដែលត្រូវយកចិត្តទុកដាក់នៅគ្រប់ប្រព័ន្ធអប់រំ ចាប់តាំងពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា។ ដោយឡែក ការពង្រឹងគុណភាពអប់រំមធ្យមសិក្សា ត្រូវផ្សារភ្ជាប់ទៅនឹង យុទ្ធសាស្ត្រសំខាន់ៗដែលពាក់ព័ន្ធនឹងកម្រងសាលារៀន និងកម្មវិធីសាលាកុមារមេត្រីដែលបាន និងកំពុងដំណើរការគ្រប់សាលារៀននៅទូទាំងប្រទេស ។ យុទ្ធសាស្ត្រទាំងពីរនេះ ទាមទារនូវការគាំទ្រយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋាន ទាំងក្នុងមូលដ្ឋានផ្ទាល់ ទាំងគ្រប់អ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិ ។ ការចូលរួមយ៉ាងសកម្ម និងការទទួលខុសត្រូវក្នុងការអនុវត្តតាមតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈកម្មការនីមួយៗ តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន និងធ្វើឱ្យកម្មវិធីសាលាកុមារមេត្រី និងកម្រងសាលារៀន មានដំណើរការប្រកបដោយជោគជ័យ។ ទាំងនេះជាបំណងប្រាថ្នារបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើឱ្យសម្រេចនូវការអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់នានា និងសិទ្ធិកុមារនៅកម្ពុជា ។ សម្រេចបានគោលដៅនេះ យើងនឹងកសាងបានធនធានមនុស្សដ៏រឹងមាំជាបន្តបន្ទាប់ សម្រាប់អភិវឌ្ឍប្រទេសជាតិ ឱ្យមានកិត្យានុភាព ប្រកបដោយភាពរុងរឿងនាពេលអនាគតដ៏យូរអង្វែង ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

## ការលើកកម្ពស់គុណភាពអប់រំ តាមរយៈកម្រងសាលារៀន

ការអភិវឌ្ឍកម្រងសាលារៀនគឺសំដៅឱ្យកុមារគ្រប់រូបបានចូលរៀនប្រកបដោយសមធម៌ និងមានគុណភាព ។

កម្រងសាលារៀនគឺជាយន្តការដែលធ្វើឱ្យសាលារៀនរីកចម្រើន និងតម្រូវឱ្យសាលារៀននីមួយៗ ពង្រឹងគុណភាពឱ្យបានឆាប់រហ័ស តាមស្ថានភាពជាក់ស្តែង យ៉ាងហោចណាស់ក៏ត្រូវតែធ្វើឱ្យមានការប្រែប្រួលលើបរិមាណ និងគុណភាពជាបន្តបន្ទាប់រៀងរាល់ឆ្នាំ ។

កម្រងសាលារៀន គឺជាគ្រួសារ នៃសាលារៀនទាំងឡាយដែលមានមុខងារដូចជាគ្រួសារខ្មែរមួយ ។ សាលារៀនត្រូវចេះជួយគ្នាឱ្យមានការរីកចម្រើនព្រមៗគ្នា ពិសេសសាលារៀនដែលមានការរីកចម្រើនខ្លាំង ត្រូវជួយសាលារៀនខ្សោយ ។

សាលារៀននីមួយៗ ត្រូវធ្វើផែនការសម្រាប់អភិវឌ្ឍរយៈពេលវែង ។ ប្រសិនបើមូលដ្ឋានមានធនធានមនុស្សនិងសម្ភារៈ គួបផ្សំនឹងជំនួយជាតិនិងអន្តរជាតិ សាលារៀនអាចអនុវត្តគម្រោងផែនការនេះ បានឆាប់រហ័ស ។ ប៉ុន្តែបើខ្វះធនធាន សាលារៀនទាំងឡាយក៏ត្រូវតែអភិវឌ្ឍ ជាជំហានៗ ។ ទាំងនេះជា លទ្ធភាពធ្វើឱ្យសម្រេចបាននូវភាពរីកចម្រើនយ៉ាងធំធេងជាបណ្តើរៗ ។ សូម្បីតែប្រាសាទអង្គរវត្តដ៏ធំមហិមា ក៏ត្រូវបានកសាងឡើងពីបន្តិចម្តងៗដែរ ។ អាស្រ័យហេតុនេះ ដំណើរការអភិវឌ្ឍន៍សាសារៀនតាមរយៈ ប្រព័ន្ធកម្រងសាលារៀន ត្រូវអនុវត្តល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

-អភិវឌ្ឍទស្សនៈសាលារៀនគំរូ ត្រូវសមស្របតាមស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន

-ស្វ័យវាយតម្លៃសាលារៀននីមួយៗ

-អភិវឌ្ឍផែនការកែលម្អសាលារៀនរយៈពេលវែង

-អភិវឌ្ឍផែនការកែលម្អកម្រងសាលារៀនរយៈពេលវែង

-អភិវឌ្ឍផែនការកែលម្អប្រចាំឆ្នាំសម្រាប់សាលារៀន និងកម្រងសាលារៀននីមួយៗ

-អនុវត្តផែនការប្រចាំឆ្នាំដោយកម្រងសាលារៀន ក្រោមការឧបត្ថម្ភរបស់គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន

-វាយតម្លៃការរីកចម្រើន និងលើកផែនការសម្រាប់ឆ្នាំក្រោយ ។

### ១.អភិវឌ្ឍទស្សនៈសាលារៀនគំរូក្នុងកម្រង

ក្រោយពីការចាត់តាំងរួច គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន ត្រូវរៀបចំអភិវឌ្ឍសាលារៀនគំរូមួយ នៅក្នុងកម្រងរបស់ខ្លួនដែលអាចធ្វើឡើងតាមវិធីខុសៗគ្នា ។ វិធីមួយស្នើឱ្យលោកគ្រូ អ្នកគ្រូនៅក្នុងកម្រងសាលារៀន សរសេរអំពីលក្ខណៈសម្បត្តិ នៃសាលារៀនល្អដែលអាចអភិវឌ្ឍបានក្នុងមូលដ្ឋាន ។ ជាការប្រសើរគួរឱ្យសិស្សានុសិស្ស សហគមន៍បានចូលរួមសរសេរពីលក្ខណៈនោះដែរ។ បន្ទាប់មកយើងបង្កើត តារាងមួយហើយជ្រើសរើសចំណុចល្អដែលគ្រូ សិស្ស និងសហគមន៍បានសរសេរ (លក្ខណៈវិនិច្ឆ័យនៃ ចំណុចល្អរបស់សិស្ស គ្រូ និងសហគមន៍) ។

ទស្សនៈដែលយើងចង់បាន គឺផែនការដែលអាចអភិវឌ្ឍបានតិចជាង៥ឆ្នាំ ប៉ុន្តែមិនត្រូវមានទស្សនៈស្រមើស្រមៃហួសហេតុហួតដល់ ៥០ឆ្នាំ ដែលមិនអាចសម្រេចបាន។ លក្ខណៈវិនិច្ឆ័យក្នុងការអភិវឌ្ឍនេះ គួរតែបញ្ចូលនូវមុខងារទាំងអស់ដូចជា រដ្ឋបាល អប់រំកាយ គរុកោសល្យ ការកែលម្អបរិស្ថាន ការងារអធិការកិច្ច ការងារហិរញ្ញកិច្ច ទំនាក់ទំនងសហគមន៍និងសាលារៀន លក្ខណៈសម្បត្តិរបស់នាយក គ្រូ សិស្ស ការចូលរួមរបស់មាតាបិតាសិស្ស កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន អត្រាបោះបង់ការសិក្សា អត្រារួមនៃការសិក្សា អត្រាត្រួតថ្នាក់ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ អត្រាប្រឡងជាប់មធ្យមសិក្សាបឋមភូមិនិងអត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ ពិសេសផ្តោតទៅលើការអនុវត្តកម្មវិធីសាលាកុមារមេត្រី។

## ២.ស្វ័យវាយតម្លៃសាលារៀន

ផ្អែកលើលក្ខណៈវិនិច្ឆ័យអភិវឌ្ឍសាលារៀនគំរូ ដែលបានរៀបរាប់ខាងលើ សាលាសម្ព័ន្ធទាំងអស់ត្រូវវាយតម្លៃអំពីស្ថានភាពរបស់សាលារៀនខ្លួនផ្ទាល់ ។ នាយកសាលា លោកគ្រូ អ្នកគ្រូ សហគមន៍ ត្រូវចូលរួមធ្វើការវាយតម្លៃ ។ វាជាការប្រសើរណាស់ ប្រសិនបើយើងឱ្យសិស្សានុសិស្សរៀនថ្នាក់ខ្ពស់បញ្ចេញមតិនូវអ្វីដែលគេចូលចិត្ត និងបានឃើញនូវការរីកចម្រើនរបស់សាលារៀន ។ ចំណុចខ្វះខាតដែលនៅសេសសល់ត្រូវតែកែលម្អនិងអភិវឌ្ឍ។ ប្រធាននិងអនុប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន ត្រូវចូលរួមក្នុងការវាយតម្លៃនេះ។

**កំណត់សម្គាល់** ៖ គំរូវាយតម្លៃកម្រងសាលារៀនជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ ។

## ៣.ការកសាងផែនការកែលម្អសាលារៀនរយៈពេលវែង

បន្ទាប់ពីស្រង់បានចំណុចខ្លះដែលត្រូវកែលម្អ នាយក នាយិកាសាលា លោកគ្រូ អ្នកគ្រូ និងសមាជិកសកម្មនៃគណៈកម្មការទ្រទ្រង់សាលា ត្រូវលើកផែនការរយៈពេលវែង (ឧទាហរណ៍ ៥ឆ្នាំ) ដើម្បីកែលម្អសាលារៀន ។ ផែនការនេះ ត្រូវមានភាពជាក់ស្តែង តាមស្ថានភាពមូលដ្ឋាន ងាយស្រួលទទួលផលសម្រេច ទៅតាមធនធានមនុស្ស ថវិកា និងសម្ភារៈ ។ ប្រធាន និងអនុប្រធាននៃគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានត្រូវចូលរួមក្នុងដំណើរការនេះ ។

## ៤.ការកសាងផែនការកែលម្អកម្រងសាលារៀនរយៈពេលវែង

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន ត្រូវតែពិនិត្យឡើងវិញ នូវផែនការរយៈពេលវែងរបស់សាលារៀននីមួយៗ ។ ផែនការទាំងនេះត្រូវបញ្ចូលជាផែនការរួមសម្រាប់ជួយជំរុញឱ្យសាលាសម្ព័ន្ធអនុវត្តសម្រេចផែនការរបស់គេ ។

## ៥.ការកសាងផែនការប្រចាំឆ្នាំ

ផ្អែកលើផែនការរយៈពេលវែង នៅរាល់ដើមឆ្នាំសិក្សាសាលាសម្ព័ន្ធនីមួយៗ និង គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានត្រូវធ្វើផែនការអនុវត្តប្រចាំឆ្នាំ ។ ផែនការនេះមិនគួរឱ្យមាន ការងារដដែលៗទេ ប៉ុន្តែគួរបញ្ចូលនូវសកម្មភាព ដែលធ្វើឱ្យសម្រេចផែនការរយៈពេលវែង ។ គណៈកម្មការ អភិវឌ្ឍន៍កម្រងសាលារៀនត្រូវពិនិត្យសម្រេចផែនការប្រចាំឆ្នាំរបស់សាលាសម្ព័ន្ធនីមួយៗ ជួយជំរុញឱ្យ សាលាសម្ព័ន្ធទាំងនោះ អនុវត្តសម្រេចនូវផែនការរបស់ខ្លួន ។

នាយក នាយិកាសាលាសម្ព័ន្ធនីមួយៗត្រូវអញ្ជើញមាតាបិតាសិស្ស មកប្រជុំ ពន្យល់អំពីផែនការ និងសំណើឧបត្ថម្ភ ។ ប្រធាន និងអនុប្រធានគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន ត្រូវជួយក្នុងដំណើរការនេះ ។

## ៦.ការអនុវត្តផែនការប្រចាំឆ្នាំ

សាលារៀននីមួយៗ និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋាន ត្រូវតែអនុវត្ត សកម្មភាពតាមផែនការដែលបានគ្រោងទុក។ ប្រសិនបើមានអ្នកទទួលខុសត្រូវច្បាស់លាស់ ការអនុវត្តផែនការនេះអាចវាស់បាននូវការរីកចម្រើន។ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលាមធ្យមសិក្សាមូលដ្ឋានត្រូវតាមដានត្រួតពិនិត្យការរីកចម្រើនរៀងរាល់ត្រីមាស ។

## ៧.ពិនិត្យផែនការឆ្នាំចាស់ និងធ្វើផែនការឆ្នាំថ្មី

នៅដើមឆ្នាំសិក្សា សាលាសម្ព័ន្ធនីមួយៗ ត្រូវពិនិត្យសកម្មភាពដែលបានអនុវត្តកន្លងមក រួចវិភាគបញ្ហាចំពោះមុខ និងរកមធ្យោបាយដោះស្រាយ ព្រមទាំងធ្វើរបាយការណ៍ចំណូលចំណាយលម្អិតប្រចាំឆ្នាំ ជូនគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋាន ។

សាលាសម្ព័ន្ធនីមួយៗ និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានត្រូវធ្វើផែនការប្រចាំឆ្នាំ ដូចដែលបានធ្វើពីឆ្នាំមុន បន្ទាប់មកសាលាសម្ព័ន្ធនីមួយៗត្រូវអញ្ជើញមាតាបិតាសិស្សចូលរួមប្រជុំ បូកសរុប វាយតម្លៃលទ្ធផលដំណាច់ឆ្នាំ និងលើកទិសដៅសម្រាប់ឆ្នាំសិក្សាថ្មី ។

**ភាពទន់ភ្លន់នៃការអនុវត្ត**

ប្រសិនបើកម្រងសាលារៀនណាមួយមានសាលារៀន ដែលមិនអាចអនុវត្តផែនការបាន គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនមូលដ្ឋានត្រូវរួមប្រជុំ លើកផែនការរួម ដើម្បីមានវិធានការជួយដោះស្រាយ ។

**កម្រងសាលារៀនដំណើរការល្អ**

គ្រប់កម្រងសាលារៀនមិនអាចដោះស្រាយរាល់បញ្ហាទាំងឡាយក្នុងប្រព័ន្ធអប់រំបានទេ ប៉ុន្តែកម្រងសាលារៀនដើរតួយ៉ាងសំខាន់ ដោយធ្វើឱ្យមាតាបិតាសិស្ស លោកគ្រូ អ្នកគ្រូ និងរដ្ឋអំណាចមូលដ្ឋានទាំងអស់រួមគ្នារិះរកមធ្យោបាយដើម្បីលើកកម្ពស់ស្ថានភាពអប់រំឱ្យបានប្រសើរ។ ម្យ៉ាងទៀតកម្រងសាលារៀននឹងប្រែប្រួលទៅតាមសមត្ថភាពរបស់គេ ។ អ្វីដែលកម្រងសាលារៀនអាចប្រែប្រួល និងធ្វើទៅបាន អាស្រ័យលើការដឹកនាំ ប្រភពធនធាន និងការខិតខំប្រឹងប្រែងរបស់លោកគ្រូ អ្នកគ្រូ តំណាងសហគមន៍ ព្រមទាំងមានការគាំទ្រពីមន្ត្រីអប់រំគ្រប់ជាន់ថ្នាក់។

## មុខងារកម្រងសាលារៀនល្អ ៖

## ១.មុខងារផែនការ

### ក.ផែនការប្រមូលសិស្សចូលរៀន

កម្រងសាលារៀនគឺជាផ្នែកមួយនៃផែនការអប់រំសម្រាប់ទាំងអស់គ្នា ។ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន សហការជាមួយអាជ្ញាធរដែនដីប្រមូលស្ថិតិកុមារក្នុងដែនទីកម្រង។ ផ្អែកលើព័ត៌មាននេះ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនធ្វើផែនការតម្រូវការគ្រូ និងថ្នាក់រៀន ដើម្បីអប់រំសិស្សទាំងនោះ ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលា

រៀន ត្រូវធ្វើផែនការរយៈពេលវែង ដើម្បីសាងសង់បន្ទប់រៀនចាំបាច់ និងធ្វើសំណើក្របខ័ណ្ឌគ្រូតម្រូវតាមឆ្នាំនីមួយៗ ។ ប្រសិនបើឃុំ ឬសង្កាត់មួយចំនួន មិនមានអនុវិទ្យាល័យនៅជិតទេ គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនត្រូវស្នើសុំបង្កើតអនុវិទ្យាល័យថ្មីនៅឃុំ ឬសង្កាត់នោះ។

### ខ.ផែនការកែលម្អគុណភាព

ការអប់រំមិនមែនស្ថិតនៅលើ ការចុះឈ្មោះចូលរៀនតែប៉ុណ្ណោះទេ សាលារៀនត្រូវតែផ្តល់គុណភាពអប់រំ ប្រកបដោយសុខភាព និងបរិយាកាសសប្បាយរីករាយ ។ អាស្រ័យហេតុនេះកម្រងសាលារៀននីមួយៗត្រូវអភិវឌ្ឍផែនការរយៈពេលវែង និងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីកែលម្អគុណភាពអប់រំ។

## ២.មុខងាររដ្ឋបាល

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនត្រូវះ

-តាមដានការអនុវត្តផែនការហើយប្រជុំទៀងទាត់ដោះស្រាយបញ្ហាដែលជួបប្រទះដើម្បីពិភាក្សា បញ្ហាលម្អិត និងតាមដានការអនុវត្តរាល់ការសម្រេចចិត្តរបស់ខ្លួន

-ពិនិត្យទៀងទាត់ នូវការរីកចម្រើននៃកាអនុវត្តផែនការប្រចាំឆ្នាំ របស់សាលាសម្ព័ន្ធ

-អនុវត្តសកម្មភាពសមស្របតាមគោលការណ៍ណែនាំរបស់ក្រសួង ដើម្បីធានាមិនឱ្យសាលារៀន បើក ឬបិទខុសពេលវេលា

-អនុវត្តសកម្មភាពសមស្រប ដើម្បីធានាឱ្យគ្រូបង្រៀន សិស្ស មិនបាត់បង់ម៉ោងសិក្សា

-មានវិធានការសមស្របដើម្បីធានាឱ្យគ្រូ និងសិស្សមកសាលារៀនទៀងទាត់

-ធានាបែងចែកសៀវភៅសិក្សាដល់សិស្សទាំងអស់ទាន់ពេលវេលា

-ចាត់តាំងធ្វើអធិការកិច្ច សាលាសម្ព័ន្ធតាមកាលកំណត់

-រក្សាទិន្នន័យអប់រំ ដែលបានមកពីសាលាសម្ព័ន្ធ និងសហគមន៍

-បែងចែកមុខងារ និងប្រគល់ភារកិច្ចដល់នាយក នាយិកា គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលារៀន និងសមាជិកសហគមន៍ ដើម្បីដំណើរការការងារបានល្អ

-ដឹកនាំសាលាសម្ព័ន្ធនានា ឱ្យថេះថៃរក្សាបញ្ជីចំណូល-ចំណាយថវិកា និងត្រួតពិនិត្យរៀងរាល់ឆ្នាំ

-ធានាឱ្យមានតម្លាភាពក្នុងការគ្រប់គ្រងថវិកានៅក្នុងសាលារៀននីមួយៗ

-ធានាឱ្យបាននូវរាល់ទំនាក់ទំនងល្អរវាងសាលារៀន គ្រួសារ គ្រូបង្រៀន មាតាបិតាសិស្ស នាយក នាយិកា និងសហគមន៍

-សម្របសម្រួលទំនាក់ទំនងរវាងសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ។

## ៣.មុខងារគរុកោសល្យ

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនត្រូវះ

-លើកកម្ពស់ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនិងសហប្រតិបត្តិការលើការ

បង្រៀន និងរៀននៅក្នុងកម្រងសាលារៀន

-កែលម្អបរិស្ថានសាលារៀន ដោយធ្វើយ៉ាងណាឱ្យសិស្សសកម្មក្នុងការសិក្សា ហើយគ្រូបង្រៀន មានទឹកចិត្តសប្បាយរីករាយក្នុងការដឹកនាំសកម្មភាពបង្រៀន និងរៀន

-រកឱ្យឃើញនូវតម្រូវការនៃការបំប៉នគ្រូ និងរៀបចំការប្រជុំ ឬផ្លាស់ប្តូរបទពិសោធពីគ្នាទៅវិញទៅមក និងដោះស្រាយបញ្ហាគរុកោសល្យដែលគ្រូជួបប្រទះ

-រៀបចំសកម្មភាពមជ្ឈមណ្ឌលធនធានឱ្យបានល្អ សម្រាប់គ្រូផលិត និងខ្ចីសម្ភារឧបទេស យកទៅប្រើប្រាស់

-រៀបចំដំណើរការបណ្ណាល័យអចិន្ត្រៃយ៍ និងបណ្ណាល័យចល័ត សម្រាប់បម្រើឱ្យការអានរបស់សិស្សានុសិស្សទាំងសាលាបង្គោល និងសាលាសម្ព័ន្ធ

-ចាត់តាំងធ្វើអធិការកិច្ចរបស់នាយក និងប្រធានក្រុមបច្ចេកទេសដើម្បីជួយគ្រូនៅតាមថ្នាក់

-តាមដានការអនុវត្តកម្មវិធីសិក្សានៅតាមសាលាសម្ព័ន្ធ

-ធានាដឹកនាំស្វ័យវាយតម្លៃរបស់សាលារៀននីមួយៗ ហើយប្រើប្រាស់លទ្ធផលនេះដើម្បីជួយសិស្សរៀនយឺត ឱ្យមានការរីកចម្រើន

-ពិនិត្យលទ្ធផលការសិក្សារបស់សិស្សទាំងពីរភេទ នៅគ្រប់សាលារៀន និងធ្វើការកែលម្អលទ្ធផលសិក្សាឱ្យប្រសើរឡើង ដោយយកចិត្តទុកដាក់ក្នុងការកាត់បន្ថយគម្លាត លទ្ធផលសិក្សារវាងសិស្សប្រុស និងសិស្សស្រី ។

## ៤.មុខងារសេដ្ឋកិច្ច

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនត្រូវៈ

-ប្រសិនបើសាលារៀនទាំងឡាយត្រូវការទិញសម្ភារៈ គណៈកម្មការកម្រងរៀបចំទិញ និងដឹកជញ្ជូនរួមគ្នាដើម្បីសន្សំសំចៃថវិកា

-សម្ភារៈមានតម្លៃខ្ពស់ មានចំនួនតិច ត្រូវរក្សាទុកនៅមជ្ឈមណ្ឌលធនធាន ហើយផ្លាស់ប្តូរគ្នាប្រើប្រាស់នៅតាមសាលាសម្ព័ន្ធ ។ បើសម្ភារៈមានច្រើន អាចចែកចាយទៅតាមសាលាសម្ព័ន្ធនានាប្រើប្រាស់

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនរិះរកគ្រប់មធ្យោបាយ ដើម្បីរកថវិកា និងសម្ភារៈសម្រាប់ទ្រទ្រង់កម្រងសាលារៀន

-គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនផ្សព្វផ្សាយធនធាន ដែលបានឧបត្ថម្ភពីខាងក្រៅចំពោះសាលារៀនណាមួយ ហើយត្រួតពិនិត្យការប្រើប្រាស់ជំនួយនោះឱ្យបានត្រឹមត្រូវ។

## ៥.មុខងារសហគមន៍

គណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀនត្រូវៈ

-សហការជាមួយអាជ្ញាធរមូលដ្ឋាន ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលាសម្ព័ន្ធ ធានាបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន ព្រមទាំងរៀបចំឱ្យមានសកម្មភាពនៅគ្រប់សាលារៀន

-លើកទឹកចិត្តសាលារៀននីមួយៗឱ្យ គណៈកម្មការទ្រទ្រង់សាលារៀនប្រជុំ រៀងរាល់ឆ្នាំ ដើម្បីពិនិត្យការរីកចម្រើនក្នុងឆ្នាំកន្លងមក និងលើកផែនការសម្រាប់ឆ្នាំថ្មី

-រៀបចំសមាជិក សមាជិកា សហគមន៍ថ្នាក់កម្រងរៀងរាល់ឆ្នាំ ដើម្បីពិនិត្យការរីកចម្រើន និងរកវិធានការ ដើម្បីដោះស្រាយបញ្ហាដែលនៅសេសសល់

-យកចិត្តទុកដាក់លើទំនាក់ទំនងល្អរវាងសាលារៀន និងមាតាបិតាសិស្សស្តីពីលទ្ធផលការសិក្សារបស់សិស្ស

-លើកទឹកចិត្តដល់សហគមន៍ក្នុងការប្រើប្រាស់សាលារៀន ដើម្បីជាផលប្រយោជន៍ទៅវិញទៅមក ៕

# ឧបសម្ព័ន្ធ ២
# គោលការណ៍
# ស្តីពីការកំណត់សាលាកុមារមេត្រីតាមកម្រិត

**សេចក្តីផ្តើម**

ការពង្រឹងនិងពង្រីកសាលាកុមារមេត្រី មានគោលបំណងឆ្លើយតបទៅនឹងការអនុវត្តសិទ្ធិកុមារ និងធានាការ ពង្រឹងគុណភាពអប់រំ ក្នុងសាលារៀន (កម្រិតមធ្យមសិក្សា) សំដៅធ្វើឱ្យសម្រេចចំណុចដៅនានានៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

ក្នុងជំហានឆ្ពោះទៅសម្រេចចំណុចដៅ និងគោលដៅខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាចិត្តប្រែក្លាយសាលារៀនកម្រិតអប់រំមូលដ្ឋានទូទាំងប្រទេស ឲ្យក្លាយទៅជាសាលាកុមារមេត្រីពេញលេញនៅឆ្នាំ២០១៨។ ឈរលើមូលដ្ឋាននេះ ក្រសួងបានខិតខំប្រឹងប្រែងធ្វើសកម្មភាពគ្រប់បែបយ៉ាងប្រកបដោយការទទួលខុសត្រូវដូចជា៖

* ការកសាង និងអភិវឌ្ឍន៍ឯកសារនានាសម្រាប់គាំទ្រការអនុវត្តកម្មវិធីសាលាកុមារមេត្រី
* ការបំប៉នសមត្ថភាពមន្ត្រីពាក់ពន្ធ័ និងគ្រូបង្រៀនក្នុងបរិបទអប់រំថ្មី
* ការចុះជួយនាយកសាលារៀននិងគ្រូបង្រៀនតាមរយៈការងារពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឱ្យពួកគាត់អាចអនុវត្តគោលការណ៍នានានៃកម្មវិធីសាលាកុមារមេត្រីបានត្រឹមត្រូវ
* ការពង្រឹងការទទួលខុសត្រូវលើការងាររបស់មន្ត្រីអប់រំគ្រប់ឋានានុក្រម
* ការទាក់ទាញប្រមែប្រមូលដៃគូអភិវឌ្ឍនានា និងសហគមន៍ដើម្បីចូលរួមអភិវឌ្ឍសាលារៀន

## ១. គោលបំណង

ការកំណត់សាលាកុមារមេត្រីតាមកម្រិតសំដៅ៖

* កំណត់លក្ខណៈសម្បត្តិសាលាកុមារមេត្រីតាមកម្រិតនីមួយៗឱ្យបានច្បាស់លាស់ ទាំងសមិទ្ធផលសម្រេចបាន និងលទ្ធផលសិក្សាតាមឆ្នាំនីមួយៗ
* ពង្រឹងកិច្ចខិតខំប្រឹងប្រែងនៃអ្នកពាក់ព័ន្ធតាមសាលារៀននីមួយៗ ដើម្បីឈានទៅសម្រេចផែនការឆ្នាំរបស់ខ្លួន
* រម្លស់ជាបណ្តើរៗនូវសាលាកុមារមេត្រីកម្រិតមូលដ្ឋាន(ទាប) និងកម្រិតមធ្យម ដើម្បីឈានជាបន្តបន្ទាប់ទៅកម្រិតអភិវឌ្ឍន៍ និងមានគុណភាពប្រហាក់ប្រហែល ឬស្មើគ្នានាពេលអនាគត ។

## ២. គោលការណ៍សំខាន់ៗ

### ២.១. ការកំណត់

ជាគោលការណ៍សាលាកុមារមេត្រីត្រូវបានកំណត់ ៣ ប្រភេទគឺ៖

**ក. សាលាកុមារមេត្រីកម្រិតមូលដ្ឋាន**

សំដៅលើសាលារៀនទាំងឡាយណាដែលសម្រេចបានលទ្ធផលនានាទាក់ទងនឹងសមាសភាគទាំង៦ មិនបានគ្រប់គ្រាន់ ហើយលទ្ធផលសិក្សាប្រចាំឆ្នាំរបស់សិស្សមានកម្រិតទាបនៅឡើយ

**ខ. សាលាកុមារមេត្រីកម្រិតមធ្យម**

សំដៅលើសាលារៀនទាំងឡាយណាដែលសមិទ្ធផលនានាក្នុងសមាសភាគទាំង៦ មានលក្ខណៈល្អខ្លះ ឬល្អបង្គួរខ្លះ តែមិនទូទៅ រីឯលទ្ធផលសិក្សារបស់សិស្សក៏ស្ថិតនៅកម្រិតមធ្យមដែរ។

**គ. សាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍**

សំដៅលើសាលារៀនទាំងឡាយណាដែលសមិទ្ធផលនៃសមាសភាគទាំង៦ ជាទូទៅមានលក្ខណៈល្អភាគច្រើនហើយលទ្ធផលសិក្សារបស់សិស្សសម្រេចបានល្អ ។

## ២.២. ការវាយតម្លៃ

ក្នុងការវាយតម្លៃដើម្បីកំណត់សាលាកុមារមេត្រី គប្បីយកចិត្តទុកដាក់លើចំណុចមូលដ្ឋានពីរសំខាន់គឺ សមិទ្ធផលសម្រេចបានតាមសមាសភាគ និងលទ្ធផល/គុណភាពសិក្សារបស់សិស្សក្នុងឆ្នាំសិក្សានីមួយៗ ។

**ក. ការវាយតម្លៃផ្អែកលើសមិទ្ធផល៖** ចំពោះការវាយតម្លៃតាមរូបភាពនេះយើងគប្បីកំណត់ថា៖

ក.១. ប្រសិនបើសាលារៀនណាមួយអនុវត្តគ្រប់សមាសភាគបាននិទ្ទេស **ល្អ ដែលមាន**ពិន្ទុ **២.៨១** ដល់ **៣.០០** អាចកំណត់ថាជាសាលា**កម្រិតអភិវឌ្ឍន៍ផ្អែកលើសមិទ្ធផល** ។

ក.២. ប្រសិនបើសាលារៀនណាមួយមាននិទ្ទេស **ល្អ** និង**ល្អបង្គួរ** ចំពោះលទ្ធផលគ្រប់សមាសភាគទាំងអស់ ហើយទទួលពិន្ទុពី **១.៧១** ទៅ **២.៨០** ត្រូវកំណត់ថាជាសាលាកុមារមេត្រី **កម្រិតមធ្យមផ្អែកលើសមិទ្ធផល** ។

ក.៣. ប្រសិនបើសាលារៀនណាដែលមានសមិទ្ធផលតាមសមាសភាគសម្រេចបាននិទ្ទេស **ល្អ ល្អបង្គួរ** និងមធ្យម ប៉ុន្តែទទួលបានពិន្ទុពី **១.០០** ទៅ **១.៧០** ត្រូវបានកំណត់ថាជាសាលាកុមារមេត្រី **កម្រិតមូលដ្ឋានផ្អែកលើសមិទ្ធផល** ។

ក.៤. ប្រសិនបើសាលារៀនណាដែលមានសមិទ្ធផលតាមសមាសភាគសម្រេចបាននិទ្ទេស **ល្អ ល្អបង្គួរ** និងមធ្យម ប៉ុន្តែទទួលបានពិន្ទុក្រោម **១.០០** ត្រូវបានកំណត់ថាមិនទាន់មានលក្ខណៈសម្បត្តិជាសាលាកុមារមេត្រីទេ ។

**ខ-ការវាយតម្លៃផ្អែកលើលទ្ធផល/គុណភាពសិក្សា**(សម្រាប់សាលាមធ្យមសិក្សា)

ការវាយតម្លៃតាមរូបភាពនេះ គឺផ្តោតយ៉ាងសំខាន់លើ អត្រារួមនៃការសិក្សា អត្រាឡើងថ្នាក់ អត្រាប្រឡងជាប់ និងអត្រាបោះបង់ការសិក្សា ក្នុងឆ្នាំសិក្សាដោយប្រៀបធៀបទៅនឹងចំណុចដៅដែលបានកំណត់តាមឆ្នាំសិក្សានីមួយៗ។ ផ្អែកលើមូលដ្ឋាននេះយើងកំណត់បានពីកម្រិតសាលាកុមារមេត្រីតាមគុណភាពនីមួយៗ ដូចជា៖

**ខ.១. សាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ផ្អែកគុណភាព:**

ចំពោះសាលាមធ្យមសិក្សាបឋមភូមិទាំងឡាយណាដែលសម្រេចបាន៖

- អត្រារួមនៃការសិក្សា ចាប់ពី ៨៧%

- អត្រាឡើងថ្នាក់ ចាប់ពី ៩៨%
- អត្រាប្រឡងជាប់ ចាប់ពី ៩៨%
- អត្រាបោះបង់ការសិក្សា ក្រោម ៣%

**ខ.២. សាលាកុមារមេត្រីកម្រិតមធ្យមផ្នែកគុណភាព:**

ចំពោះសាលាមធ្យមសិក្សាបឋមភូមិទាំងឡាយណាដែលសម្រេចបាន៖

- អត្រារួមនៃការសិក្សា ពី ៧០-៨៦%
- អត្រាឡើងថ្នាក់ ពី ៨៧-៩៧%
- អត្រាប្រឡងជាប់ ពី ៩៥-៩៧%
- អត្រាបោះបង់ការសិក្សា ពី ៣-១១%

**ខ.៣. សាលាកុមារមេត្រីកម្រិតមូលដ្ឋានផ្នែកគុណភាព:**

ចំពោះសាលាមធ្យមសិក្សាបឋមភូមិទាំងឡាយណាដែលសម្រេចបាន៖

- អត្រារួមនៃការសិក្សា ក្រោម ៧០%
- អត្រាឡើងថ្នាក់ ក្រោម ៨៧%
- អត្រាប្រឡងជាប់ ក្រោម ៩៥%
- អត្រាបោះបង់ការសិក្សា លើស ១១%

## ៣. ការកំណត់កម្រិតសាលាកុមារមេត្រី

### ៣.១. ស្វ័យវាយតម្លៃដោយសាលារៀន

-ការវាយតម្លៃដើម្បីកំណត់គុណភាពត្រូវអនុវត្តរាល់ដើមឆ្នាំសិក្សាថ្មី ដោយយកលទ្ធផលសម្រេចបានធៀបនឹងចំណុចដៅតាមឆ្នាំសិក្សានីមួយៗ

-ការវាយតម្លៃផ្នែកលើសមិទ្ធផល ត្រូវអនុវត្តក្នុងឆ្នាំសិក្សា តាមរយៈការប្រើប្រាស់បញ្ជីពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងាររបស់សាលារៀនក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រី (សូមមើលការវាយតម្លៃលម្អិតនៅទំព័រ ៧៦ ដល់ ៩០)

-ការកំណត់លទ្ធផលពិតប្រាកដត្រូវយកលទ្ធផលទាំងពីរ (សមិទ្ធផល និងគុណភាព) មកផ្គូផ្គងឱ្យបានច្បាស់លាស់ ដើម្បីរកឱ្យឃើញនូវលក្ខណៈសមស្របដែលអាចទទួលយកបាន ក៏ប៉ុន្តែទោះជាយ៉ាងណា ត្រូវផ្តោតលើគុណភាពជាអាទិភាពក្នុងការកំណត់សាលាកុមារមេត្រីទាំង ៣ កម្រិតនេះ

-ករណីសាលារៀនមួយបានសម្រេចសមិទ្ធផលក្នុងកម្រិតអភិវឌ្ឍន៍ ហើយលទ្ធផលសិក្សាស្ថិតក្នុងកម្រិតអភិវឌ្ឍន៍ដូចគ្នា ត្រូវបានកំណត់ថាជាសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ពេញលេញ (ប្រភេទ ល្អ) តែបើលទ្ធផលសិក្សាស្ថិតក្នុងកម្រិតមធ្យម ឬប្រហាក់ប្រហែលកម្រិតអភិវឌ្ឍន៍ ត្រូវបានកំណត់ថាជាសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ ប្រភេទល្អបង្គួរ។

### ៣.២. ការវាយតម្លៃដោយ DTMT

- DTMT ត្រូវរៀបចំការចុះពិនិត្យតាមដាន ដើម្បីវាយតម្លៃកម្រិតសាលាកុមារមេត្រីនៅក្នុងក្រុង/ស្រុក/ខណ្ឌរបស់ខ្លួន ដោយប្រើបញ្ជីពិនិត្យតាមដានសាលារៀននិងថ្នាក់រៀន

- DTMT ត្រូវអនុវត្តការងារនេះ ឲ្យបានគ្រប់ជ្រុងជ្រោយដោយប្រើពេលពេញមួយថ្ងៃដើម្បីអាច

កំណត់កម្រិតសាលាកុមារមេត្រីសម្រាប់សាលានោះ (សូមមើលការវាយតម្លៃលម្អិតនៅទំព័រ ៦៨)

- DTMTត្រូវផ្ទៀងផ្ទាត់លទ្ធផលការវាយតម្លៃរបស់ខ្លួនទៅនឹងស្វ័យវាយតម្លៃសាលារៀនដើម្បីឱ្យមានការឯកភាពគ្នាលើចំណាត់ថ្នាក់សាលាកុមារមេត្រី

- DTMT ត្រូវសរសេររបាយការណ៍ពីអ្វីដែលបានរកឃើញ រួចកំណត់ឲ្យបានច្បាស់ពីកម្រិតសាលាកុមារមេត្រី ដោយមានការឯកភាពពីសាលាដើម្បីទុកជាឯកសារយោង រួចហើយផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡា ជាព័ត៌មាន និងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគុណភាព (QEMIS) ។

## តារាងកំណត់កម្រិតសាលាកុមារមេត្រី សម្រាប់សាលាមធ្យមសិក្សា

| ល.រ | កម្រិត | សមិទ្ធផលសម្រេចបានតាមសមាសភាគ (ក) | | | | | | | លទ្ធផល/គុណភាពសិក្សា (ខ) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សមាស ភាគ I (4) | សមាស ភាគ II (11) | សមាស ភាគ III (9) | សមាស ភាគ IV (3) | សមាស ភាគ V (5) | សមាស ភាគ VI (7) | សរុប (39) | អត្រារួមនៃការសិក្សា | អត្រាឡើងថ្នាក់ | អត្រាប្រឡងជាប់ | អត្រាបោះបង់ |
| 1 | **អភិវឌ្ឍន៍** | 2.41-3.00 | 2.41-300 | 2.41-3.00 | 2.41-3.00 | 2.41-3.00 | 2.41-3.00 | 2.41-3.00 | ≥ 87% | ≥ 98% | ≥ 98% | < 3% |
| 2 | **មធ្យម** | 1.71-2.40 | 1.71-2.40 | 1.71-2.40 | 1.71-2.40 | 1.71-2.40 | 1.71-2.40 | 1.71-2.40 | 70-86% | 87-97% | 95-97% | 3-11% |
| 3 | **មូលដ្ឋាន** | 1.00-1.70 | 1.00-1.70 | 1.00-1.70 | 1.00-1.70 | 1.00-1.70 | 1.00-1.70 | 1.00-1.70 | < 70% | < 87% | < 95% | >11% |

**កំណត់សម្គាល់** :

- DTMT មានភារកិច្ចរៀបចំ និងស្រង់លទ្ធផល **ក** និង **ខ** ខាងលើ (សមិទ្ធផលសម្រេចបាន និងលទ្ធផល/គុណភាពសិក្សា) ដោយធ្វើតារាងរាយឈ្មោះសាលាកុមារមេត្រីតាមកម្រិតនីមួយៗ បញ្ជូនមកមន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត ដើម្បីបូកសរុបចុងក្រោយ (ឧបសម្ព័ន្ធជូនភ្ជាប់)។
- សញ្ញាសម្គាល់សំខាន់ៗសម្រាប់លទ្ធផល/គុណភាពសិក្សាមាន : សញ្ញា (≥) សម្គាល់ "ស្មើ ឬ លើស" សញ្ញា (>) សម្គាល់ "លើស ឬធំជាង" សញ្ញា (<) សម្គាល់ "ក្រោម ឬទាបជាង"
- ក្នុងការវាយតម្លៃត្រូវផ្តោតសំខាន់លើលទ្ធផល/គុណភាពសិក្សាជាអាទិភាព ទោះបីសមិទ្ធផលតាមសមាសភាគខ្ពស់ ឬទាបក៏ដោយ
- ក្នុងករណីដែលសាលារៀនទាំងអស់ក្លាយជាសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ផ្នែកសមិទ្ធផល ការកំណត់កម្រិតត្រូវផ្តោតលើគុណភាពវិញ ដោយបែងចែកសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ទាំងនេះ ជាប្រភេទ "**ល្អ**" ប្រភេទ "**ល្អបង្គួរ**" និងប្រភេទ "**មធ្យម**" ផ្អែកតាមលទ្ធផល (អត្រាខ្ពស់ ឬទាប) ទាក់ទង នឹងសូចនាករលទ្ធផលទាំង៤ (សម្រាប់មធ្យមសិក្សា) នៃសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍។

## ៣.៣. សន្និដ្ឋាន

ការកំណត់សាលាកុមារមេត្រីតាមកម្រិតនីមួយៗមិនអាចស្មើគ្នាបានទេ ទាំងសមិទ្ធផលដែលសម្រេចបានទាំងលទ្ធផល/គុណភាពសិក្សា។ ការវាយតម្លៃដើម្បីដាក់បញ្ចូលតាមកម្រិត ទាមទារនូវការវិភាគថ្លឹងថ្លែងច្បាស់លាស់ ដោយផ្តោតសំខាន់លើគុណភាពជាអាទិភាព។ លើមូលដ្ឋាននេះ យើងអាចនឹងកាត់បន្ថយជាបណ្តើរៗនូវសាលាកុមារមេត្រីកម្រិតមូលដ្ឋាន និងកម្រិតមធ្យម ទន្ទឹមនឹងការបង្កើនសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ ហើយដែលនឹងសម្រិតសម្រាំងឱ្យទៅជាកម្រិតអភិវឌ្ឍន៍ទាំងអស់នាពេលអនាគត។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
មន្ទីរអប់រំ យុវជន និងកីឡា......................
ការិយាល័យអប់រំ យុវជន និងកីឡា........

## តារាងស្រង់លទ្ធផល
## វាយតម្លៃសាលាកុមារមេត្រី(សម្រាប់មធ្យមសិក្សាបឋមភូមិ)
## ឆ្នាំសិក្សា................................................

| ល.រ | ឈ្មោះសាលារៀន | សមិទ្ធផលតាមសមាសភាគ | | | | | | លទ្ធផលសរុប | កម្រិតសមិទ្ធផល | គុណភាពសិក្សា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សមាសភាគ I | សមាសភាគ II | សមាសភាគ III | សមាសភាគ IV | សមាសភាគ V | សមាសភាគ VI | | | អត្រារួមនៃការសិក្សា | អត្រាឡើងថ្នាក់ | អត្រាប្រឡងជាប់ | អត្រាបោះបង់ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |

ធ្វើនៅ............................ ថ្ងៃទី...............ខែ............ ឆ្នាំ.............

បានឃើញ និងឯកភាព
**ប្រធានការិយាល័យអប់រំ យុវជន និងកីឡា**

**អ្នកធ្វើតារាង**

**បញ្ជាក់:**
- តារាងនេះត្រូវស្រង់តាមលទ្ធផលដែលមានការឯកភាពគ្នារវាងស្វ័យវាយតម្លៃរបស់សាលារៀន និងការវាយតម្លៃពីក្រុម DTMT។
- ការស្រង់លទ្ធផលវាយតម្លៃនេះមិនបាច់ធ្វើតាមលំដាប់កម្រិតទេ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
មន្ទីរអប់រំ យុវជន និងកីឡា........................
ការិយាល័យអប់រំ យុវជន និងកីឡា..........

**របាយការណ៍**
**វាយតម្លៃសាលាកុមារមេត្រី**
**ឆ្នាំសិក្សា**.................................

| ល.រ | ឈ្មោះសាលារៀន | លទ្ធផលសម្រេចបានតាមផ្នែក | | ចំណាត់ប្រភេទ | ផ្សេងៗ |
|---|---|---|---|---|---|
| | | សមិទ្ធផល | គុណភាពសិក្សា | | |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |

- សរុបសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ :
- សរុបសាលាកុមារមេត្រីកម្រិតមធ្យម :
- សរុបសាលាកុមារមេត្រីកម្រិតមូលដ្ឋាន :

ធ្វើនៅ................ ថ្ងៃទី.......... ខែ....... ឆ្នាំ..........
**ប្រធានការិយាល័យអប់រំ យុវជន និងកីឡា**.......

**បញ្ជាក់:** របាយការណ៍លទ្ធផលនេះ ត្រូវរៀបចំតាមលំដាប់កម្រិត (ពីអភិវឌ្ឍន៍មកកម្រិតមូលដ្ឋាន)។

-លទ្ធផលសម្រេចបានតាមផ្នែក (សមិទ្ធផល និងគុណភាពសិក្សា) ត្រូវសរសេរជាលេខសម្គាល់ដូចតទៅ៖ " I " (អភិវឌ្ឍន៍) " II " (មធ្យម) " III " (មូលដ្ឋាន) ។

-ចំណាត់ប្រភេទ: ត្រូវសរសេរ "IA" ប្រសិនបើលទ្ធផលទាំង២ ស្ថិតក្នុងកម្រិតអភិវឌ្ឍន៍ដូចគ្នា តែប្រសិនបើសមិទ្ធផលស្ថិតក្នុងកម្រិតអភិវឌ្ឍន៍ តែគុណភាពសិក្សាស្ថិតក្នុងកម្រិតមធ្យម ត្រូវសរសេរ " IB " ក្រៅពីនេះអាចកំណត់តាមការជាក់ស្តែងតាមកម្រិតនីមួយៗ (មធ្យម ឬមូលដ្ឋាន)។

# ឧបសម្ព័ន្ធ ៣

## សេចក្តីណែនាំអំពីការបំពេញទម្រង់បញ្ជីតាមដាន និងវាយតម្លៃលទ្ធផលការងាររបស់សាលារៀន និងគ្រូបង្រៀនក្នុងកម្មវិធីសាលាកុមារមេត្រី

### ១. គោលបំណង

ការដាក់ឱ្យប្រើប្រាស់បញ្ជីពិនិត្យតាមដាន និងវាយតម្លៃ(Check List) មានគោលបំណង ជួយដល់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង/ស្រុក/ខណ្ឌ (DTMT) ក្នុងការៈ

១.តាមដានការបំពេញការងាររបស់សាលារៀន និងថ្នាក់រៀន (សម្រេចបានអ្វីខ្លះ?)

២.វាយតម្លៃលទ្ធផលការងារដែលសាលារៀន និងថ្នាក់រៀនសម្រេចបាន (កម្រិតណា?)

៣.ជួយ និងកែលម្អការងាររបស់មុខសញ្ញាទាំងពីរ(សាលារៀន និងថ្នាក់រៀន) ឱ្យបានកាន់តែប្រសើរ តាមរយៈការផ្តល់អនុសាសន៍ក្នុងពេលចុះជួយសម្របសម្រួលឱ្យធ្វើដោយផ្ទាល់

៤.ប្រើប្រាស់ព័ត៌មាននានាធ្វើជាមូលដ្ឋាននៃការវិភាគដើម្បីកសាងផែនការនិងកំណត់កម្រិតនីមួយៗនៃសាលាកុមារមេត្រី(កម្រិតអភិវឌ្ឍន៍ កម្រិតមធ្យម និងកម្រិតមូលដ្ឋាន) ឱ្យបានច្បាស់លាស់ ។

### ២. ការបំពេញតារាង

ដើម្បីជាមូលដ្ឋានក្នុងការសរុបលទ្ធផលនៃការបំពេញការងាររបស់សាលារៀន និងថ្នាក់រៀន អ្នកចុះពិនិត្យតាមដានវាយតម្លៃ DTMT គប្បីបំពេញទម្រង់ទាំងពីរ(បញ្ជីពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងាររបស់សាលារៀន បញ្ជីពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងាររបស់គ្រូបង្រៀន) តាមរយៈការពិនិត្យឯកសារនានា សង្កេតសកម្មភាពជាក់ស្តែង និងធ្វើការសម្ភាសន៍សាកសួរព័ត៌មានតាមចំណុចនីមួយៗ ដូចខាងក្រោមៈ

**ផ្នែកក្បាល**

១. សម្រាប់បញ្ជីពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលរបស់សាលារៀន ត្រូវៈ

- សរសេរឈ្មោះរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ភូមិ កម្រងសាលារៀន តាមការជាក់ស្តែង
- ប្រើសញ្ញា √ នៅក្នុងប្រអប់ □ ប្រសិនបើពិត តែបើមិនពិតត្រូវទុកចោល (មិនបាច់បំពេញទេ)
- ចុះលេខកូដ (ត្រឹមត្រូវ) របស់សាលារៀន ដែលមាននៅក្នុងឯកសារ EMIS ប្រសិនបើសាលារៀននោះត្រូវបានទទួលស្គាល់ជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡារួចហើយ
- ចុះកាលបរិច្ឆេទជាក់ស្តែងក្នុងអំឡុងពេលដែលអ្នកចុះពិនិត្យតាមដានវាយតម្លៃបំពេញការងារ
- ចុះភាគរយសិស្សចូលរៀនថ្មី(ថ្នាក់ទី៧) ដោយធៀបចំនួនសិស្សដែលបានចុះឈ្មោះចូលរៀនជាក់ស្តែងទៅនឹងចំនួនសិស្សត្រូវចូលរៀនថ្នាក់ទី៧ តាមបញ្ជីដែលការិ. អយក ក្រុង/ស្រុក/ខណ្ឌ បានផ្ញើឱ្យ
- ចុះភាគរយ (%)សិស្សជាប់មធ្យមភាគ (%) សិស្សធ្លាក់មធ្យមភាគ (%)សិស្សបោះបង់ការ

សិក្សា (ប្រចាំខែ ឬឆមាស ដោយធៀបទៅនឹងចំនួនសិស្សដើមឆ្នាំសិក្សា មកត្រឹមពេល (ខែ ឬឆមាស) ចុះពិនិត្យតាមដាន និងវាយតម្លៃ។

២. សម្រាប់បញ្ជីពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងាររបស់គ្រូបង្រៀន ត្រូវ ៖

- បំពេញដូចសាលារៀនដែរ (ខេត្ត-ក្រុងរហូតដល់សាលារៀន)
- សរសេរឈ្មោះពេញរបស់គ្រូបង្រៀន ភេទ និងថ្នាក់ដែលគាត់បង្រៀន
- ចុះកាលបរិច្ឆេទក្នុងអំឡុងពេលដែលក្រុមចុះពិនិត្យតាមដានវាយតម្លៃកំពុងបំពេញការងារ
- ចុះមុខវិជ្ជាដែលគ្រូបានបង្រៀន ចំនួនសិស្សសរុប និងចំនួនសិស្សអវត្តមានដែលបានរកឃើញជាក់ស្តែងក្នុងម៉ោងសិក្សា។

## ផ្នែកតារាង

១. ក្នុងខ្ទង់ស្ថានភាព ត្រូវ៖

សរសេរ **ម**=មាន **គ្ម**=គ្មាន និង **ម.អ**=មិនអនុវត្ត ដែលស្របទៅនឹងរបាយការណ៍សកម្មភាពជាក់ស្តែង ឬការសម្ភាសន៍សាកសួរព័ត៌មានពីអ្នកពាក់ព័ន្ធនានា។ បន្ទាប់មកត្រូវកំណត់តម្លៃសូចនាករទាំងនោះ ដោយដាក់ពិន្ទុពី ០ ទៅ ៣ ទៅតាមអ្វីដែលសាលាធ្វើបាន។

**១.១.កំណត់តម្លៃសូចនាករ**

**ក.ស្ថានភាពសូចនាករបានអនុវត្ត " មាន "** សំដៅលើចំណុច (សកម្មភាព ឬការងារ) ណាមួយនៅក្នុងខ្លឹមសារលទ្ធផល ដែលអ្នកចុះពិនិត្យតាមដានវាយតម្លៃបានរកឃើញថាមុខសញ្ញាមាន ឬបានធ្វើ ឬកំពុងធ្វើ ឬធ្វើរួចហើយ។ បន្ទាប់មកវិនិច្ឆ័យលើសូចនាករនេះ ដោយដាក់ពិន្ទុ ៣ ប្រសិនបើល្អ ឬពិន្ទុ ២ ប្រសិនបើល្អបង្គួរ ឬពិន្ទុ ១ ប្រសិនបើ មធ្យម ឬពិន្ទុ ០ ប្រសិនបើមិនបានធ្វើ (គ្មាន)។

**ខ.ស្ថានភាពសូចនាករមិនបានអនុវត្ត " គ្មាន "** សំដៅលើចំណុច (សកម្មភាព ឬការងារ) ណាមួយនៅក្នុងខ្ទង់ខ្លឹមសារលទ្ធផល ដែលអ្នកចុះពិនិត្យតាមដានវាយតម្លៃបានរកឃើញថាមុខសញ្ញាមិនមាន ឬមិនបានធ្វើ ឬមិនទាន់ធ្វើនៅឡើយ ។ ក្នុងករណីនេះ សូចនាករបានពិន្ទុ ០ (គ្មាន) ។

**គ.ស្ថានភាពសូចនាករដែលមិនអនុវត្តនៅមធ្យមសិក្សា "មិនអនុវត្ត"** សំដៅលើចំណុច (សកម្មភាពឬការងារ)ណាមួយនៅក្នុងខ្លឹមសារលទ្ធផល ដែលសកម្មភាពនេះមិនសមស្រប សម្រាប់អនុវត្តនៅមធ្យមសិក្សាបឋមភូមិទេ។ សូចនាករនេះមិនត្រូវដាក់ពិន្ទុ ហើយក៏មិនត្រូវបូកជាមួយសូចនាករផ្សេងទៀតឡើយ ។

**១.២. កំណត់តម្លៃសូចនាករ**

សូចនាករនីមួយៗត្រូវបានកំណត់ពិន្ទុដូចខាងក្រោម ៖

| | |
|---|---|
| ល្អ | : ពិន្ទុ ៣ |
| ល្អបង្គួរ | : ពិន្ទុ ២ |
| មធ្យម | : ពិន្ទុ ១ |
| ក្រោមមធ្យម | : ពិន្ទុ ០ |

**២. ការកំណត់កម្រិតសាលាកុមារមេត្រី**

ដើម្បីកំណត់កម្រិតសាលាកុមារមេត្រី យើងត្រូវកំណត់ពិន្ទុលទ្ធផលនីមួយៗ បន្ទាប់មកកំណត់ពិន្ទុសមិទ្ធផលនៃសមាសភាគនីមួយៗ និងចុងបញ្ចប់កំណត់កម្រិតសាលាកុមារមេត្រីសម្រាប់សាលារៀន ។

២.១. ដើម្បីកំណត់ពិន្ទុលទ្ធផលនីមួយៗ យើងត្រូវកំណត់តម្លៃសូចនាករនីមួយៗទៅតាមការកំណត់ពិន្ទុខាងលើ រួចបូកសរុបពិន្ទុទាំងនោះ បន្ទាប់មកចែកចំនួនសូចនាករដែលមាន លើកលែងតែ "មិនអនុវត្ត" ចេញ(អត់ចែក)។ ពិន្ទុលទ្ធផលនីមួយៗអាចកំណត់បាន ដោយអត្រាដូចខាងក្រោម៖

+ ប្រសិនបើផលចែក**ក្រោម១** លទ្ធផលនោះគឺ **ក្រោមមធ្យម**
+ ប្រសិនបើផលចែកចន្លោះ**ពី១ ដល់ ១.៧០** លទ្ធផលនោះគឺ **មធ្យម**
+ ប្រសិនបើផលចែកចន្លោះពី**១.៧១ ដល់ ២.៤០** លទ្ធផលនោះគឺ **ល្អបង្គួរ**
+ ប្រសិនបើផលចែក ចាប់ពី **២.៤១ ដល់ ៣** លទ្ធផលនោះគឺ **ល្អ**

**ឧទាហរណ៍៖** ដើម្បីកំណត់ពិន្ទុលទ្ធផលមួយ នៅក្នុងបញ្ជីពិនិត្យតាមដានសាលារៀន (សូមមើលឧទាហរណ៍នៅក្នុងបញ្ជីពិនិត្យតាមដានទំព័រ៨១ ) យើងត្រូវរកតម្លៃមធ្យមភាគនៃសូចនាករទាំងអស់ដោយយកតម្លៃសូចនាករនីមួយៗបូកបញ្ចូលគ្នា ហើយចែកនឹងចំនួនសូចនាករ (៣សូចនាករ ព្រោះសូចនាករមួយមិនអនុវត្ត)។ តម្លៃមធ្យមភាគនៃសូចនាករទាំងនោះ (ស្មើ ២) គឺជាពិន្ទុនៃលទ្ធផលមួយក្នុងសមាសភាគទី១។ នេះមានន័យថា លទ្ធផល ២ ស្ថិតក្នុងកម្រិត (ល្អបង្គួរ) ។

២.២. ការកំណត់ពិន្ទុសមិទ្ធផលនៃសមាសភាគនីមួយៗគឺស្មើនឹងមធ្យមភាគនៃលទ្ធផលក្នុងសមិទ្ធផលនោះ។ ឧទាហរណ៍ ៖ សមិទ្ធផលទី១នៃបញ្ជីពិនិត្យតាមដាន និងវាយតម្លៃសាលារៀនដែលមានលទ្ធផលចំនួន ៤ ត្រូវបានគណនាដូចខាងក្រោម៖

$$\underline{\text{សមិទ្ធផលនៃសមាសភាគទី១}} = \frac{\text{ផលបូកពិន្ទុលទ្ធផលទី១ ដល់ទី៤}}{\text{ចំនួនលទ្ធផល(ចំនួន៤)}}$$

២.៣. ការកំណត់កម្រិតសាលាកុមារមេត្រី គឺត្រូវបានគណនាដោយបូកពិន្ទុសមិទ្ធផលនៃសមាសភាគទាំងអស់របស់សាលាកុមារមេត្រី ហើយចែកនឹង ៦។ ផលចែកដែលទទួលបាននេះចង្អុលបង្ហាញពីកម្រិតសាលាកុមារមេត្រី (មូលដ្ឋាន មធ្យម អភិវឌ្ឍន៍ និងអភិវឌ្ឍន៍កម្រិតខ្ពស់) ទៅតាមគោលការណ៍វាយតម្លៃសាលាកុមារមេត្រីនៅទំព័រ ៦៨ ។

**ផ្នែកបញ្ចប់** (ទំព័រចុងក្រោយ)

**អ្នកពិនិត្យតាមដាន និងវាយតម្លៃម្នាក់ៗត្រូវអនុវត្តដូចតទៅ ៖**

- ធ្វើការសន្និដ្ឋានរួមលើលទ្ធផលនៃការបំពេញការងារ ដោយផ្អែកលើនិទ្ទេសសរុបតាមជួរឈរ និងវិភាគលើបញ្ហា មូលហេតុ គុណសម្បត្តិ និងគុណវិបត្តិដែលបានមកពីការសម្ភាសន៍ ប្រមូលព័ត៌មាននានាពីអ្នកពាក់ព័ន្ធទាក់ទងនឹងដំណើរការអនុវត្ត នៃសាមីអង្គភាព ឬបុគ្គលនាពេលកន្លងមកឱ្យបានត្រឹមត្រូវ ដោយធ្វើយ៉ាងណាឱ្យមុខសញ្ញាអាច

ទទួលយកបាន ដោយពេញចិត្ត

- ចុះឈ្មោះទីកន្លែង (សាលារៀន) និងថ្ងៃខែ ឆ្នាំ ដែលបានពិនិត្យជាក់ស្តែង (កំពុងបំពេញការងារ)
- ចុះហត្ថលេខា និង ដាក់ឈ្មោះផ្ទាល់នៅខាងក្រោម "អ្នកពិនិត្យតាមដាន និងវាយតម្លៃ"
- ឱ្យនាយកសាលារៀន ឬគ្រូបង្រៀនបញ្ជាក់ខាងក្រោម (យោបល់របស់នាយកសាលារៀន ឬយោបល់របស់គ្រូបង្រៀន) តាមអ្វីដែលគាត់យល់ថា " ឯកភាព ឬ មិនឯកភាព " លើចំណុចទាំងឡាយ ដែលអ្នកពិនិត្យតាមដាន និងវាយតម្លៃបានវាយតម្លៃ រួចឱ្យគាត់ចុះហត្ថលេខា និង ដាក់ឈ្មោះនៅខាងក្រោម ។

**កំណត់សម្គាល់**

បញ្ជីតាមដាន និងវាយតម្លៃនេះ អ្នកពិនិត្យតាមដាន និងវាយតម្លៃត្រូវឱ្យមុខសញ្ញា (នាយក ឬគ្រូបង្រៀន) អានដោយផ្ទាល់ ឬអានឱ្យគាត់ស្តាប់ព្រមទាំងសួរបញ្ជាក់ថាតើគាត់" ឯកភាព ឬមិនឯកភាព " ជាមុនសិន ទើបស្នើឱ្យគាត់ចុះហត្ថលេខាជាក្រោយ។ ក្នុងករណីមិនមានការឯកភាពគ្នា អ្នកចុះពិនិត្យតាមដាន និងវាយតម្លៃ ត្រូវពិនិត្យឡើងវិញលើរាល់ចំណុចដែលមុខសញ្ញាបដិសេធ រួចធ្វើការពិភាក្សាគ្នាសាជាថ្មី ក្នុងស្មារតីស្ថាបនា និងយោគយល់គ្នា ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត............**

## បញ្ជីពិនិត្យតាមដាន និងវាយតម្លៃ
## ថ្នាក់រៀន ក្នុងកម្មវិធីសាលាកុមារមេត្រី

ក្រុង ស្រុក ខណ្ឌ..............................ឃុំ សង្កាត់............................ភូមិ ក្រុម........................កម្រងសាលារៀន.........................................សាលារៀន................................

ឈ្មោះគ្រូបង្រៀន...................................................... ភេទ............. **បង្រៀន**ថ្នាក់ទី............ មុខវិជ្ជា.............................................. សិស្សសរុប............នាក់ ស្រី............នាក់

អវត្តមាន............នាក់ ស្រី............នាក់ កាលបរិច្ឆេទ៖ ថ្ងៃទី...... ខែ......... ឆ្នាំ..............ម៉ោង..............។

**កំណត់សម្គាល់៖ មាន=ម គ្មាន=គ្ម មិនអនុវត្ត=ម.អ ល្អ=៣ ល្អបង្គួរ=២ មធ្យម=១ ក្រោមមធ្យម=0**

| លទ្ធផល | សូចនាករ | ស្ថានភាព | ពិន្ទុ | សរុបលទ្ធផល/យោបល់ |
|---|---|---|---|---|
| **១. ការរៀបចំ និងការគ្រប់គ្រងរដ្ឋបាលថ្នាក់** | | | | |
| ១.ការគោរពវិន័យ | ១. ចូលនិងចេញតាមម៉ោងកំណត់ | | | |
| | ២. ដឹកនាំសិស្សបង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀន | | | |
| | ៣. សិស្សគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដែលបានបង្កើត | | | |
| | ៤. សិស្សម្នាក់ៗបង្ហាញពីវិន័យផ្ទាល់ខ្លួនរបស់គេ | | | |
| ២.ការតុបតែងថ្នាក់រៀន និងការដាក់តាំង សម្ភារ: | ១. តុបតែងបាវចនាជាតិ ព្រះឆាយាលក្ខណ៍ | | | |
| | ២. តារាងផ្សេងៗ ពាក្យស្លោក និងរូបភាពតាមមុខវិជ្ជាត្រូវបាន ដាក់តាំងយ៉ាងត្រឹមត្រូវ | | | |
| | ៣. ដាក់តាំងសម្ភារ: កម្រងស្នាដៃសិស្ស | | | |
| | ៤. រៀបចំទុកដាក់ ថែទាំសម្ភារឧបទេស និង គ្រឿងសង្ហារិម | | | |
| | ៥. អនាម័យក្នុង និងក្រៅថ្នាក់រៀន | | | |

| | | | | |
|---|---|---|---|---|
| ៣.ការរៀបចំក្តារខៀន និងតុអង្គុយរបស់សិស្ស | ១. តុសមស្របតាមកម្ពស់ ចំនួនសិស្ស និងងាយចល័តបាន | | | |
| | ២. ក្តារខៀនមានពណ៌ច្បាស់ តម្រូវតាមសកម្មភាពបង្រៀន និងរៀន | | | |
| | ៣. ប្រើប្រាស់ក្តារខៀនចល័ត ដើម្បីសម្រួលដល់ការបង្រៀន និងរៀន | | | |
| ៤.ការប្រើប្រាស់បន្ទប់រៀនពិសេសសម្រាប់សិស្សពិការ | ១. បន្ទប់រៀនមានពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់ | | | |
| | ២. សិស្សទាំងអស់ ទាំងសិស្សពិការអាចធ្វើបំលាស់ទី ក្នុងបន្ទប់ទាំងមូលបាន | | | |
